ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

# របាយការណ៍

# ប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣









## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | | ត្រីមាសទី៤ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|---|---|
| | | (ពាន់រៀល) | (ពាន់រៀល) | (ពាន់រៀល) |
| ទ្រព្យសកម្មសរុប | | ១.៦០២.៨២៤.៩៤០ | ១.៤២៦.១៤៥.៥៩៦ | ១.៤២៧.១៤៩.៦៧០ |
| បំណុលសរុប | | ៦៣០.៧៨០.០៦៤ | ៥៦២.៣៤៤.៦៥០ | ៦៤៣.២៥៥.៥១១ |
| មូលធនសរុប | | ៩៧២.០៤៤.៨៧៦ | ៨៦៣.៨០០.៩៤៦ | ៧៨៣.៨៩៤.១៥៩ |
| លទ្ធផលហិរញ្ញវត្ថុ | | ត្រីមាសទី៤ ឆ្នាំ២០២៣ | ត្រីមាសទី៤ ឆ្នាំ២០២២ | ត្រីមាសទី៤ ឆ្នាំ២០២១ |
| | | (ពាន់រៀល) | (ពាន់រៀល) | (ពាន់រៀល) |
| ចំណូលសរុប | | ១០០.០៧២.៧៨០ | ៧៧.០១២.៨៣៨ | ៨៧.៦៧៦.៩៨១ |
| ចំណេញ/(ខាត)មុនបង់ពន្ធ | | ៨.៩៨០.៧៥៦ | (១២.០៣៨.៥៦០) | ២៨.៨៣៣.១៨៣ |
| ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ | | ៤.០៣២.២២០ | (១៤.០០៥.០៨១) | ២៤.៥០៦.៥៩០ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ៤.០៣២.២២០ | (១៤.០០៥.០៨១) | ២៤.៥០៦.៥៩០ |
| អនុបាតហិរញ្ញវត្ថុ | | ត្រីមាសទី៤ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
| អនុបាតសាធនភាព | | ២,៦៤% | ២៣,០៩% | ២០,៧៧% |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ២,០៩ | ២,៦២ | ២,៣១ |
| | អនុបាតចរន្តលឿន | ១,៨១ | ២,២៥ | ២,០០ |
| | | ត្រីមាសទី៤ ឆ្នាំ២០២៣ | ត្រីមាសទី៤ ឆ្នាំ២០២២ | ត្រីមាសទី៤ ឆ្នាំ២០២១ |
| អនុបាតចំណេញភាព | អនុបាតចំណេញក្នុងមួយឯកតាទ្រព្យសកម្ម | ០,២៥% | (០,៩៨)% | ១,៧២% |
| | អនុបាតចំណេញក្នុងមួយឯកតាមូលធន | ០,៤១% | (១,៦២)% | ៣,១៣% |
| | អនុបាតគម្លាតចំណេញដុល | ២១,៧១% | ១៤,៥២% | ២២,៥៧% |
| | អនុបាតគម្លាតចំណេញភាព | ៤,០៣% | (១៨,១៩)% | ២៧,៩៥% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៤៧,០១ | (១៦៣,២៨) | ២៨៥,៧២ |
| អនុបាតលទ្ធភាពសងការប្រាក់ | | ៥,០០ | (៣,៩០) | ១០,៩៩ |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេបប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣









## ភាគហ៊ុនិករបស់ កសស

| ល.រ | ប្រភេទមូលបត្រកម្មសិទ្ធិ | ភាគហ៊ុនិក | ចំនួនមូលបត្រកាន់កាប់ | ភាគរយ |
|---|---|---|---|---|
| ១ | មូលបត្រកម្មសិទ្ធិគ្មានសិទ្ធបោះឆ្នោតប្រភេទ "ក" | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៣៦៤.៥៣០.៨៦១ | ៨០,៩៥% |
| ២ | មូលបត្រកម្មសិទ្ធិមានសិទ្ធបោះឆ្នោតប្រភេទ "ខ" | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៦៤.៣២៨.៩៧៥ | ១៤,២៩% |
| ៣ | មូលបត្រកម្មសិទ្ធិមានសិទ្ធបោះឆ្នោតប្រភេទ "គ" | ឯកជន | ២១.៤៤២.៩៩២ | ៤,៧៦% |
| សរុប | | | ៤៥០.៣០២.៨២៨ | ១០០% |

## ភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិប្រភេទ "គ" របស់ កសស

| ល.រ | ភាគហ៊ុនិក | ចំនួនមូលបត្រកាន់កាប់ | ភាគរយ |
|---|---|---|---|
| ១ | ESOP | ២.១៤៤.២៩៩ | ១០% |
| ២ | KAMIGUMI CO., LTD | ១១.១៥០.៣២៤ | ៥២% |
| ៣ | KOBE-OSAKA International Port Corporation | ២.១៤៤.៣០០ | ១០% |
| ៤ | ភាគហ៊ុនិកឯកជនដទៃទៀត | ៦.០០៤.០៦៩ | ២៨% |
| សរុប | | ២១.៤៤២.៩៩២ | ១០០% |



មូលបត្រកម្មសិទ្ធិមានសិទ្ធបោះឆ្នោត
២២,៥%
២,៥%
៧៥%
រដ្ឋតំណាងដោយ(ស.ហ.វ)
ESOP
ភាគហ៊ុនិកឯកជន




បំរែបំរួលថ្លៃភាគហ៊ុន និងទំហំជួញដូរ
20,000
16,000
12,000
8,000
4,000
0
ចំនួនភាគហ៊ុន
ថ្លៃ (រៀល)
02/10/2023
08/10/2023
14/10/2023
20/10/2023
26/10/2023
01/11/2023
07/11/2023
13/11/2023
19/11/2023
25/11/2023
01/12/2023
07/12/2023
13/12/2023
19/12/2023
25/12/2023
ចំនួនភាគហ៊ុន
ថ្លៃបិទ

# សមាសភាពក្រុមប្រឹក្សាភិបាល



**ឯកឧត្តម លូ គឹមឈន់**
ប្រធានអគ្គនាយក



**ឯកឧត្តម ស៊ុយ សាន**
តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន



**ឯកឧត្តម ផាន់ ផល្លា**
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



**ឯកឧត្តម សុខ សុភ័ក្រ្ត**
តំណាងក្រសួងពាណិជ្ជកម្ម



**លោក ហ៊ុន មុន្នីវណ្ណ**
អភិបាលឯករាជ្យ



**លោក Hidetoshi KUME**
អភិបាលមិនប្រតិបត្តិ
តំណាងភាគហ៊ុនិកឯកជន



**លោក លូ លីខេង**
តំណាងនិយោជិតកម្មករ
កំពង់ផែស្វយ័តក្រុងព្រះសីហនុ

# សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក



"ជំនួសមុខឱ្យក្រុមប្រឹក្សាភិបាលរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយក្នុងការបង្ហាញជូននូវរបាយការណ៍អាជីវកម្ម និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣ របស់ កសស សម្រាប់ការិយបរិច្ឆេទដែលបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣"។

ដោយមានការគាំទ្រយ៉ាងមុតមាំពីរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងអាណាព្យាបាលទាំងពីរ កសស បានបន្តការវិវឌ្ឍន៍យ៉ាងខ្លាំងក្លា ដើម្បីបម្រើសកម្មភាពធុរកិច្ចរបស់ខ្លួន ជាលទ្ធផលនៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ នេះ កសស ទទួលបានប្រាក់ចំណូលសរុបចំនួន ១០០.០៧២.៧៨០.០០០ រៀល និងបានចំណេញសុទ្ធក្រោយបង់ពន្ធក្នុងការិយបរិច្ឆេទចំនួន ៤.០៣២.២២០.០០០ រៀល។ បើប្រៀបធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២២ ប្រាក់ចំណូលកើនចំនួន ២៣.០៥៩.៩៤២.០០០ រៀល គឺស្មើនឹង ២៩,៩៤% ចំណែកប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធមានការកើនឡើងចំនួន ១៨.០៣៧.៣០១.០០០ រៀល ស្មើនឹង ១២៨,៧៩%។ លទ្ធផលនេះបណ្តាលមកពីបរិមាណកុងតែន័រ និងបរិមាណទំនិញឆ្លងកាត់ កសស មានការកើនឡើង លើសពីនេះក៏មានការថយចុះនៃការខាតនៃអត្រាប្តូររូបិយប័ណ្ណមិនទាន់សម្រេចប្រាក់យ៉េន បានធ្វើអោយចំណេញសុទ្ធក្រោយបង់ពន្ធមានការកើនឡើង ជាលទ្ធផលចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធ មានចំនួន ៤៧,០១ រៀល សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ នេះ។ ហើយក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ កុងតែន័រដែលបានឆ្លងកាត់ កសស មានចំនួន ២០៩.៩១៥ TEUs ពោលគឺ កើនឡើងចំនួន ៥០.៨១១ TEUs ស្មើនឹង ៣១,៩៤% បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២២ ។

កសស នឹងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបំពេញសេវាកម្ម អាជីវកម្មឱ្យកាន់តែល្អប្រសើរ និងសម្រេចបានលទ្ធផលខ្ពស់ជាប្រយោជន៍ដល់ភាគហ៊ុនិករបស់ខ្លួន។ កសស បានពង្រឹងប្រសិទ្ធភាពការងារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការសេវាកម្មរបស់អតិថិជន និងការរីកចម្រើនសេដ្ឋកិច្ចជាតិ។ ដោយសារតែមានការកើនឡើងនូវបរិមាណទំនិញ និងកុងតែន័រឆ្លងកាត់ កសស បានធ្វើការកែសម្រួលផែប្រាំងថ្មី (សាងសង់ឆ្នាំ១៩៦៩, ប្រវែង ៣៥០ ម៉ែត្រ) ទៅជាចំណតផែកុងតែន័រប្រវែង ២៥៣ ម៉ែត្រ ដើម្បីក្លាយជាចំណតកុងតែន័រមួយបន្ថែមទៀត ដែលបច្ចុប្បន្នមានត្រឹមតែពីរចំណតប៉ុណ្ណោះ។ ជាងនេះទៅទៀត កសស បាននឹងកំពុងអនុវត្តគម្រោងអភិវឌ្ឍន៍ផែកុងតែន័រថ្មី (ជំហានទី១) ប្រវែង ៣៥០ ម៉ែត្រ និងមានជម្រៅទឹក ១៤,៥ ម៉ែត្រ រួមបញ្ចូលទាំងការបំពាក់គ្រឿងចក្រលើកដាក់កុងតែន័រទំនើប ប្រភេទ QC ចំនួន ០៣ គ្រឿង និងប្រភេទ RTG ចំនួន ០៩ គ្រឿង រថលើកកុងតែន័រទទេ (Empty Reach Stacker) ចំនួន ០២ គ្រឿង ក្បាលសណ្តោងកុងតែន័រ ចំនួន ១៦ គ្រឿង និងប្រព័ន្ធគ្រប់គ្រងចំណតផែកុងតែន័រស្វ័យប្រវត្តិកម្ម ០១ កំភ្លែ។ សម្រាប់ចំណតផែកុងតែន័រថ្មីនេះ អាចអនុញ្ញាតឱ្យនាវាដឹកជញ្ជូនកុងតែន័រធុនធំក្នុងតំបន់ចូលចតនៅ កសស បាន ដែលនឹងធ្វើឱ្យឧបសគ្គអំពីជម្រៅទឹក សម្រាប់កំពង់ផែត្រូវបានដោះស្រាយ ព្រមទាំងតម្លៃដឹកជញ្ជូនតាមសមុទ្រ

(Ocean Freight Cost) មានតម្លៃប្រហាក់ប្រហែលបណ្តាប្រទេសជិតខាង និងក្នុងតំបន់ ដែលជាការរួមចំណែកដល់ការជួយសម្រួលផ្នែកពាណិជ្ជកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា។ តាមការរំពឹងទុកគម្រោងនេះនឹងគ្រោងបញ្ចប់ការសាងសង់នៅពាក់កណ្តាល ឆ្នាំ២០២៥ ហើយសមត្ថភាពលើកដាក់កុងតែន័រដល់ ១.១៥០.០០០ TEUs ក្នុង ១ឆ្នាំ នៅពេលដែលចំណតផែកុងតែន័រនេះដាក់ឱ្យប្រតិបត្តិការនៅ ឆ្នាំ២០២៥ ខាងមុខ។

➤ **ដើម្បីឆ្លើយតបនឹងការកើនឡើងនៃបរិមាណទំនិញឆ្លងកាត់ ក៏ដូចជាតម្រូវការសេវាកម្ម របស់អតិថិជន កសស មានទិសដៅការងារចម្បងៗដូចខាងក្រោម៖**

- អនុវត្តបន្តការងារតាមផែនការដែលបានគ្រោងទុកសម្រាប់ឆ្នាំ២០២៣
- រក្សានូវឧត្តមភាពនៃភាពប្រកួតប្រជែងរបស់ខ្លួន ដោយធានានូវគុណភាពសេវាកម្ម តម្លៃប្រកួតប្រជែង ប្រសិទ្ធភាពការងារ និងការកសាងទំនុកចិត្តជូនអតិថិជន
- ពង្រឹងសមត្ថភាពបុគ្គលិកលើការគ្រប់គ្រង និងបច្ចេកទេស ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលាចំពោះកំណើនតំរូវការសេវាកម្មរបស់កំពង់ផែ
- ជួសជុល ថែទាំ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែ និងគ្រឿងចក្របន្ថែមទៀត ដើម្បីរក្សាឧត្តមភាពប្រកួតប្រជែង និងលើកកំពស់សមត្ថភាពលើកដាក់ទំនិញរបស់ខ្លួន
- ពង្រឹងកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រជាមួយកំពង់ផែក្នុងប្រទេស និងក្នុងតំបន់
- ពង្រឹងអភិបាលកិច្ចគ្រប់គ្រងតាមរយៈការបង្កើតគណៈកម្មាធិការសំខាន់ៗ
- ចូលរួមក្នុងសកម្មភាពអភិវឌ្ឍសហគមន៍មូលដ្ឋាន និងលើកកំពស់សុខមាលភាពសង្គម

➤ **ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល**

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ នេះ ក្រុមប្រឹក្សាភិបាលបានធ្វើការជួបប្រជុំសាមញ្ញចំនួន ០១ លើក ហើយបានសម្រេចការងារដូចខាងក្រោម៖

**សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី១០ នាថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣**

- ក្រោយពីបានពិនិត្យ និងពិភាក្សា អង្គប្រជុំបានឯកភាព តាមរបាយការណ៍របស់ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ គណៈកម្មាធិការ តែងតាំងនិងលាភការ និងគណៈកម្មាធិការសវនកម្ម និងអនុម័តបំពេញបន្ថែមត្រង់ កថាខណ្ឌទី២ ប្រការ៩ នៃលក្ខន្តិកៈបុគ្គលិក ដោយ កសស អាចបំពេញសិទ្ធិនិយោជិត ដែលមានកម្រិតជំនាញបច្ចេកទេសចាំបាច់ដល់ កសស ត្រឹមរយៈពេលចាប់ពី ៣ខែ ទៅ ៦ខែ ។
- ក្រោយពីបានពិនិត្យ និងពិភាក្សា អង្គប្រជុំបានអនុម័តឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពនៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រ ដែលកំពុងដំណើរការ (១.គម្រោងកែសម្រួលផែទំនិញទូទៅជាផែកុងតែន័រប្រវែង ២៥៣ ម៉ែត្រ និង ២.គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រ ថ្មី-ដំហានទី១, ដំហានទី២ និងដំហានទី៣)។
- ក្រោយពីពិភាក្សា អង្គប្រជុំបានអនុម័តដោយឯកភាពលើ របាយការណ៍ហិរញ្ញវត្ថុត្រីមាសទី៣ ឆ្នាំ២០២៣ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young (Cambodia) Ltd ។
- ក្រោយពីបានពិនិត្យ និងពិភាក្សាអង្គប្រជុំបានអនុម័តឯកភាពគាំទ្រគម្រោងផែនការ អាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ កសស ឆ្នាំ២០២៤ ដូចខាងក្រោម ៖

១) ផែនការ អាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ ៖

ក). បរិមាណផលិតផល ៖

| | | |
|---|---|---|
| - បរិមាណទំនិញឆ្លងកាត់ផែ | ចំនួន ៨.០៦៩.០០០ តោន | និទស្សន៍កំណើន ៤% |
| - បរិមាណប្រេងឆ្លងកាត់ | ចំនួន ២.២៨២.០០០ តោន | និទស្សន៍កំណើន ៤% |
| - បរិមាណតោនលើករៀប | ចំនួន ១៧.៦១២.០០០ តោន | និទស្សន៍កំណើន ៤% |
| - បរិមាណកុងតែន័រឆ្លងកាត់ | ចំនួន ៨២៣.០០០ TEUs | និទស្សន៍កំណើន ៥% |
| - ចំនួននាវាឆ្លងកាត់ | ចំនួន ១.៥៥២ គ្រឿង | និទស្សន៍កំណើន ៣% |
| - ចំណុះផ្ទុកនាវា | ចំនួន ១៩.៤១៧.០០០ តោន | និទស្សន៍កំណើន ៤% |
| ខ). សរុបចំណូលសេវាកម្ម | ៣៧៧.០៩២.០០០ ពាន់រៀល | និទស្សន៍កំណើន ៥% |
| គ). សរុបចំណាយសេវាកម្ម | ៣០៣.១០៧.០០០ ពាន់រៀល | និទស្សន៍កំណើន ១% |
| ឃ). ចំណេញប្រតិបត្តិការ | ៧៣.៩៨៥.០០០ ពាន់រៀល | និទស្សន៍កំណើន ២០% |
| ង). ចំណេញ/ខាតហិរញ្ញវត្ថុសុទ្ធ | (១.១៥១.០០០) ពាន់រៀល | និទស្សន៍ថយចុះ ៤% |
| ច). លទ្ធផលពិតមុនបង់ពន្ធ | ៧២.៨៣៤.០០០ ពាន់រៀល | និទស្សន៍កំណើន ២០% |
| ឆ). ពន្ធលើប្រាក់ចំណេញ | ១៤.៥៦៧.០០០ ពាន់រៀល | និទស្សន៍កំណើន ២០% |
| ជ). ចំណេញពិតក្នុងការិយបរិច្ឆេទ | ៥៨.២៦៧.០០០ ពាន់រៀល | និទស្សន៍កំណើន ២០% |

២) ផែនការវិនិយោគ ៖ គម្រោងវិនិយោគឆ្នាំ ២០២៤ របស់ កសស រួមមាន៖

- ការដ្ឋានប្រើឥណទានកម្ចី ODA ជប៉ុន ២៧៥.៧២៥.១០២ ពាន់រៀល
- ការដ្ឋានប្រើឥណទានកំពង់ផែ ៨៩.៨១១.៥២៥ ពាន់រៀល
  (ចំណាយក្នុងឆ្នាំ២០២៤ = ៤៧.៤៩៩.៥២៥ ព.រ និងបន្តចំណាយក្នុងឆ្នាំ២០២៥ = ៤២.៣១២.០០០ ព.រ)
- បំពាក់ឧបករណ៍ និងមធ្យោបាយគ្រឿងចក្រ ៦៧.៤៥៧.៣០០ ពាន់រៀល
  (ចំណាយក្នុងឆ្នាំ២០២៤ = ១៨.៩៧៤.៨០០ ព.រ និងបន្តចំណាយក្នុងឆ្នាំ២០២៥ = ៤៨.៤៨២.៥០០ ព.រ)
- បំពាក់ឧបករណ៍ការិយាល័យ និងសង្ហារឹម ៣.៣៤៥.៥៩២ ពាន់រៀល

- ក្រោយពីបានពិនិត្យ និងពិភាក្សា អង្គប្រជុំបានឯកភាពទៅលើរបាយការណ៍ និងរក្សាការឯកភាពស្របតាមស្មារតីអង្គប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៩ ដោយអនុញ្ញាតិអោយ កសស ជួលដីទៅអោយ ក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ (Royal Railway Plc) សម្រាប់រយៈពេល ១០ឆ្នាំ បន្តទៀត ក្នុងតម្លៃចាប់ផ្តើមពី ១០០.០០០ ដុល្លារអាមេរិក ក្នុងមួយឆ្នាំ ជាមួយនឹងការកើនឡើង ៥% ជារៀងរាល់ឆ្នាំ ដោយកំណត់ត្រឹមទំហំដីដែលក្រុមហ៊ុនបានកំពុងអភិវឌ្ឍ និងកំពុងធ្វើអាជីវកម្ម ហើយ កសស នឹងធ្វើការអភិវឌ្ឍដីដែលនៅសល់ ដើម្បីបម្រើអោយប្រតិបត្តិការអាជីវកម្ម និងការងារលើកដាក់ កសស ។
- ក្រោយពីបានពិនិត្យ និងពិភាក្សា អង្គប្រជុំបានឯកភាពទៅលើរបាយការណ៍ស្តីពី ករណីក្រុមហ៊ុន ជី.ធី.វី.ស៊ី ស្ពីដប៊ូត (G.T.V.C SPEEDBOAT CAMBODIA) អភិវឌ្ឍន៍ចំណតកំពង់ផែទេសចរណ៍ នៅមុខឃ្លាំងលេខ១ និងឃ្លាំងលេខ២ ដោយ កសស ត្រូវរៀបចំខណ្ឌរបង កំណត់ព្រំប្រទល់រវាង កសស

(តំបន់កំពង់ផែអន្តរជាតិ) និងតំបន់ទេសចរណ៍ក្នុងស្រុក (តំបន់សាធារណៈ) ក្នុងគោលបំណងឱ្យមានអនុលោមភាពស្របតាម ISPS Code និង SOLAS និងត្រូវរក្សាទុកឃ្លាំងលេខ២ និងចន្លោះទីធ្លានៅមុខឃ្លាំង ដើម្បីជានាការបត់ចេញ-ចូលរបស់រថយន្តដឹកកុងតៃន័រ សម្រាប់ការងារអាជីវកម្ម កសស និងបម្រើអោយការនាំចេញផលិតផលកសិ-ឧស្សាហកម្ម ដូចជា អង្ករ និងដំឡូងមីជាដើម ។

- ក្រោយពីបានពិនិត្យ និងពិភាក្សា អង្គប្រជុំបានអនុម័តលើ ការកំណត់កាលបរិច្ឆេទរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី១១ នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៤ ។

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអាណាព្យាបាលទាំងពីរ គឺក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជានិច្ចកាលតែងតែគាំទ្រ និងទុកចិត្តដល់សកម្មភាពការងាររបស់ កសស រៀងរហូតមក ។

ជាចុងក្រោយនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ មន្ត្រី-និយោជិត និងកម្មករ កំពង់ផែស្វយ័តក្រុងព្រះសីហនុទាំងអស់ដែលតែងតែយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួនដោយស្មារតីទទួលខុសត្រូវ ។

ថ្ងៃពុធ ៥ កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តព្រះសីហនុ, ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤

**ប្រធានអគ្គនាយក**

PORT AUTONOME DE SIHANOUKVILLE

**លូ_គីមឈន់**

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប. ....I

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ....II

សមាសភាពក្រុមប្រឹក្សាភិបាល ....V

សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក....VI

**ផ្នែកទី ១ : ព័ត៌មានទូទៅពាក់ព័ន្ធនឹងកំពង់ផែស្វយ័តក្រុងព្រះសីហនុ.... ០១**

ក- អត្តសញ្ញាណកំពង់ផែស្វយ័តក្រុងព្រះសីហនុ ....០២

ខ- លក្ខណៈនៃធុរកិច្ច....០២

គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសទី១ ឆ្នាំ២០២១ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ...០៤

**ផ្នែកទី ២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ....០៥**

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច.... ០៦

ខ- រចនាសម្ព័ន្ធចំណូល .... ១០

**ផ្នែកទី ៣ : របាយការណ៍ហិរញ្ញវត្ថុ ដែលបានត្រួតពិនិត្យឡើងវិញ ដោយសវនករឯករាជ្យ.... ១១**

**ផ្នែកទី ៤ : ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង....៤៧**

ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ .... ៤៨

ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ .... ៥៥

គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល .... ៥៦

ឃ- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ .... ៥៦

ង- ផលប៉ះពាល់នៃអតិផរណា.... ៥៦

ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល.... ៥៦

**ផ្នែកទី ៥ : ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន.... ៥៨**

ហត្ថលេខាអភិបាលរបស់កំពង់ស្វយ័តក្រុងព្រះសីហនុ.... ៦១

# ផ្នែកទី ១

# ព័ត៌មានទូទៅពាក់ព័ន្ធនឹង
# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## ក- អត្តសញ្ញាណកំពង់ផែស្វយ័តក្រុងព្រះសីហនុ

| | | |
|---|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | : | កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) |
| ឈ្មោះក្រុមហ៊ុនជាអក្សរ (ឡាតាំង) | : | PORT AUTONOME DE SIHANOUKVILLE "PAS" |
| ឈ្មោះក្រុមហ៊ុនជាអក្សរ (អង់គ្លេស) | : | SIHANOUKVILLE AUTONOMOUS PORT |
| លេខកូដស្តង់ដារ | : | KH1000060009 |
| អាសយដ្ឋាន | : | តិរៈវិថីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។ |
| លេខទូរស័ព្ទ | : | (៨៥៥) ៣៤ ៩៣៣ ៤១៦ /៩៣៣ ៥១១ |
| ទំនាក់ទំនងវិនិយោគិន | : | (៨៥៥) ៧៨ ៤៩៦ ៧៨៩ |
| គេហទំព័រ | : | www.pas.gov.kh |
| អ៊ីម៉ែល | : | pasinfo@pas.gov.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | : | Co.៤៧៨៤ Et / ២០១៧ កាលបរិច្ឆេទ៖ ២១ កុម្ភៈ ២០១៧ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | : | ០១៥៩ ពណ.ចបព កាលបរិច្ឆេទ៖ ២២ កុម្ភៈ ២០១៧ ដែលចេញដោយក្រសួងពាណិជ្ជកម្ម |

សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខៈ ០៥៨/១៧/គ.ម.ក/ស.ស.រ

| | | |
|---|---|---|
| កាលបរិច្ឆេទ | : | ០៩ ឧសភា ២០១៧ |
| ឈ្មោះតំណាងបុគ្គលបោះផ្សាយ | : | **ឯកឧត្តម លូ គឹមឈន់** |

## ខ- លក្ខណៈនៃធុរកិច្ច

កំពង់ផែស្វយ័តក្រុងព្រះសីហនុ គឺជាកំពង់ផែសមុទ្រអន្តរជាតិទឹកជ្រៅតែមួយគត់ នៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីប្រមាណ ១២៥ ហិកតា។ ដោយស្ថិតនៅតាមបណ្តោយឆ្នេរនៃព្រះរាជាណាចក្រកម្ពុជាក្នុងឈូងសមុទ្រថៃ កសស ទទួលបានភាពអនុគ្រោះពីធម្មជាតិ និងលក្ខខណ្ឌប្រតិបត្តិការយ៉ាងរលូនពេញមួយឆ្នាំ ដោយមានទឹកសមុទ្រស្ងប់ស្ងាត់ល្អ និងពុំមានព្យុះធំៗឡើយ ។

កសស ត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះ។ តាមផ្លូវគោក កសស ត្រូវបានតភ្ជាប់ដោយផ្លូវជាតិសំខាន់ៗពីរ និងផ្លូវល្បឿនលឿនមួយ គឺផ្លូវជាតិលេខ៤ មានប្រវែង ២២៦ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញមកក្រុងព្រះសីហនុ និងផ្លូវជាតិលេខ៣ កាត់តាមទីរួមខេត្តកំពត មានប្រវែង ២៤៤ គីឡូម៉ែត្រ បន្ថែមពីនេះ គឺផ្លូវល្បឿនលឿន ដែលទើបនឹងសាងសង់រួច និងដាក់ឱ្យដំណើរការប្រើប្រាស់កាលពីដើមខែតុលា ឆ្នាំ២០២២ កន្លងមកដែលមានប្រវែង ១៨៧ គីឡូម៉ែត្រ ពីភ្នំពេញ មក ក្រុងព្រះសីហនុ។ កសស ក៏ត្រូវបានតភ្ជាប់ដោយខ្សែរថភ្លើងភាគខាងត្បូង ពីភ្នំពេញកាត់តាមខេត្តកំពត ដែលមានប្រវែង ២៦៤ គីឡូម៉ែត្រ។ ចំណែកតាមផ្លូវអាកាស កសស ត្រូវបានតភ្ជាប់ទៅខេត្តសៀមរាប និងរាជធានីភ្នំពេញដោយអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ។

ក្នុងនាមជាប្រតិបត្តិករផែ កសស ត្រូវបំពេញអាជីវកម្ម និងសេវាកម្មដូចខាងក្រោម៖

- កណ្តាលធារកិច្ច នាំនាវាចេញ-ចូល និងផ្តល់ភស្តុភាដល់នាវា
- លើកដាក់ ផ្ទេរ-ផ្ទុក ទំនិញ
- ស្តុកទំនិញ នៅឃ្លាំង និងទីលាន
- ដឹកជញ្ជូនទំនិញ

- តំបន់សេដ្ឋកិច្ចពិសេស

**កសស មានចំណតផែសរុបប្រវែង ១.៨៦០ ម៉ែត្រ ដោយចែកជា ១៣ ចំណតដូចខាងក្រោម៖**

| ល.រ | ឈ្មោះស្ថានីយ៍ | ប្រភេទទំនិញ | បណ្តោយ (ម៉ែត្រ) | ទទឹង (ម៉ែត្រ) | ចំណត |
|---|---|---|---|---|---|
| ១ | ស្ថានីយ៍ផែអ្នកដំណើរ (ចំណតផែចាស់) | អ្នកដំណើរ និងទំនិញរាយ | ២៩០ | ២៨ | លេខ១ និងលេខ៣៖ ជម្រៅ ៩ ម៉ែត្រ ដល់ ១៣ ម៉ែត្រ សម្រាប់នាវា ដែលមានជម្រៅបាត ៨,៥ ម៉ែត្រ ចូលចតបាន។ លេខ២ និងលេខ៤ជម្រៅ ៦,៥ ម៉ែត្រ ដល់ ៨ ម៉ែត្រ សម្រាប់នាវា ដែលមានជម្រៅបាត ៧ ម៉ែត្រ ចូលចតបាន។ |
| ២ | ស្ថានីយ៍ផែថ្មី | កុងតែន័រ | ៣៥០ | ៥០០ | លេខ៥ (ផ្នែកខាងលិច) និងលេខ៦ (ផ្នែកខាងកើត)៖ ជម្រៅ ១០ ម៉ែត្រ សម្រាប់នាវាដែលមានជម្រៅបាត ក្រោម ៨,៥ ម៉ែត្រ ចូលចតបាន។ |
| ៣ | ស្ថានីយ៍ផែកុងតែន័រ | កុងតែន័រ | ៤០០ | ៣៥០ | លេខ៧ និងលេខ៨៖ ជម្រៅ ១១,៥ ម៉ែត្រ សម្រាប់នាវាដែលមានជម្រៅបាត ក្រោម ៨,៥ ម៉ែត្រ ចូលចតបាន។ |
| ៤ | ស្ថានីយ៍ផែពហុបំណង | អ្នកដំណើរ ទំនិញរាយ និងរុករកប្រេង | ៣៣០ | ២០០ | ផែពហុបំណង មានប្រវែង ៣៣០ ម៉ែត្រ និងជម្រៅទឹក ១៣,៥ ម៉ែត្រ សម្រាប់ ប្រតិបត្តិការលើកដាក់ទំនិញរាយ និងទំនិញទូទៅ ដែលអាចអនុញ្ញាតឱ្យ នាវាចំណុះ ៥០.០០០ DWT ចូលចតបាន និងចំណតផែមូលដ្ឋាន ផ្គត់ផ្គង់ការរុករករ៉ែប្រេងក្នុងដែនសមុទ្រ មានប្រវែង ២០០ ម៉ែត្រ និងជម្រៅទឹក ៧,៥ ម៉ែត្រ ដើម្បីបម្រើសេវាភស្តុភារកម្មសម្រាប់ ការរុករកប្រេងក្នុងដែនសមុទ្រកម្ពុជា។ |
| ៥ | ស្ថានីយ៍ផែថ្ម | ដឹកប្រេង | ៥៣ | ៥ | ចំណតផែប្រេង៖ ជម្រៅ ៤,៥ ម៉ែត្រ ហើយមានប្រវែងសរុបក្រោម ៨០ ម៉ែត្រ។ ឧបករណ៍ទាក់ពួរកៃច្នៃ ត្រូវបានរៀបចំសម្រាប់នាវាប្រេង ដែលមានជម្រៅ បាតក្រោម ៦ ម៉ែត្រ និងប្រវែងក្រោម ១១០ ម៉ែត្រ ធ្វើការចូលចតបាន។ |

- **ស្ថានីយ៍រថភ្លើងដឹកកុងតែន័រ**

ក្រៅពីចំណតផែខាងលើ ដោយសហការជាមួយក្រុមហ៊ុន Royal Railway Co., Ltd កសស ក៏មានប្រតិបត្តិការប្រព័ន្ធផ្លូវដែក និងទីលានផ្ទុកទំនិញកុងតែន័រក្នុងបរិវេណកំពង់ផែដើម្បីឱ្យអតិថិជន ឬម្ចាស់ទំនិញអាចដឹកជញ្ជូនទៅវិញទៅមកពី កសស ទៅភ្នំពេញ។ កសស បានជួលដីបរិវេណនេះទៅឱ្យក្រុមហ៊ុន Royal Railway Co., Ltd ហើយផ្តល់សេវាកម្មលើកដាក់កុងតែន័រទៅលើ និងចុះពីរថភ្លើង ។

- **តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ**

ក្រៅពីអាជីវកម្ម សេវាកម្មខាងលើ កសស ក៏មានប្រតិបត្តិដំណើរការតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុដែលមានទំហំផ្ទៃដីប្រមាណ ៦៤ ហិកតា បានកសាងឡើងតាមបទដ្ឋានប្រទេសជប៉ុន។

## គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ នេះ កសស មានព្រឹត្តិការសំខាន់មួយដូចខាងក្រោម៖

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣ កំពង់ផែស្វយ័តក្រុងព្រះសីហនុ បានសម្ពោធបើកការដ្ឋានសាងសង់ចំណតផែកុងតែន័រទឹកជ្រៅជំហានទី១ មានប្រវែង ៣៥០ ម៉ែត្រ និងជំរៅទឹក ១៤,៥ ម៉ែត្រ និងបានទទួលរថលើកដាក់ចល័តនៅគែមផែ (Mobile Harbor Cranes) ចំនួន ០២ គ្រឿង ដែលមានសមត្ថភាពអាចលើកដាក់ទំនិញទូទៅជាអតិបរមា ១០០ តោន និងលើកកុងតែន័រជាមធ្យម ១៥ កុងតែន័រ/ម៉ោង ក្រោមសម្បទាន មានតម្លៃសរុបប្រហែល ចំនួន ១៣,៩ លានដុល្លារអាមេរិក ដែលជាជំនួយឥតសំណងពីរដ្ឋាភិបាល នៃប្រទេសជប៉ុន ហើយបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃដដែល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីសម្ពោធបើកការដ្ឋានសាងសង់ចំណតផែកុងតែន័រទឹកជ្រៅជំហានទី១ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការគ្រឿងចក្រលើកដាក់ចល័តនៅគែមផែ ចំនួន ០២ គ្រឿង ដែលប្រារព្ធនៅតំបន់សេដ្ឋកិច្ចពិសេស កំពង់ផែស្វយ័តក្រុងព្រះសីហនុ។

# ផ្នែកទី ២
# ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក-  លទ្ធផលប្រតិបត្តិការធុរកិច្ច

| បរិយាយ | ឯកត្តា | ផែនការ ឆ្នាំ២០២៣ | ត្រីមាសទី៤ ឆ្នាំ២០២៣ | ត្រីមាសទី៤ ឆ្នាំ២០២២ | ត្រីមាសទី៤ ឆ្នាំ២០២១ | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | (២-៣)/៣ | (២-៤)/៤ |
| **បរិមាណទំនិញឆ្លងកាត់** | តោន | **៧.២៨២.០០០** | **២.០៧៤.៣១៣** | **១.៥៩៥.៥២៥** | **១.៧៤២.២២៥** | **៣០,០១%** | **១៩,០៦%** |
| ជាកុងតែន័រ | _ | | ១.៥៤៣.០៦៩ | ១.១៤៥.៧២៥ | ១.២៩៥.៨៥៧ | ៣៤,៦៨% | ១៩,០៨% |
| ទំនិញរាយ | _ | | ៩៩.០៦៧ | ២៤.៦៤០ | ៥២.៦៨១ | ៣០២,០៦% | ៨៨,០៥% |
| ជាប្រេង | _ | | ៤០១.២៧១ | ៣៩៤.១៣៩ | ៣៧៩.៥៨០ | ១,៨១% | ៥,៧១% |
| ហ្គាស | _ | | ៣០.៩០៦ | ៣១.០២១ | ១៤.១០៧ | -០,៣៧% | ១១៩,០៨% |
| **បរិមាណទំនិញនាំចូល** | _ | **៥.៤៣៦.០០០** | **១.៤៧៧.១០០** | **១.១៧៨.៣២៣** | **១.២៦៧.៥៧០** | **២៥,៣៦%** | **១៦,៥៣%** |
| ជាកុងតែន័រ | _ | | ៩៥៣.៨៧៩ | ៧២៨.៨៧៨ | ៨២១.២០១ | ៣០,៨៧% | ១៦,១៦% |
| ទំនិញរាយ | _ | | ៥២៣.២២០ | ៤៤៩.៤៤៥ | ៤៤៦.៣៦៩ | ១៦,៤១% | ១៧,២២% |
| **បរិមាណទំនិញនាំចេញ** | _ | **១.៨៤៦.០០០** | **៥៩៧.២១៣** | **៤១៧.២០១** | **៤៧៤.៦៥៧** | **៤៣,១៥%** | **២៥,៨២%** |
| ជាកុងតែន័រ | _ | | ៥៨៩.១៩០ | ៤១៦.៨៤៧ | ៤៧៤.៦៥៧ | ៤១,៣៤% | ២៤,១៣% |
| ទំនិញរាយ | _ | | ៨.០២៣ | ៣៥៥ | ០ | ២១៦១,៦៣% | ១០០,០០% |
| **បរិមាណទំនិញលើករៀប** | _ | **១៥.៨៥២.៤០០** | **៤.៤៦០.៦២៣** | **២.៥៥២.២២០** | **២.៦៥០.២៥៤** | **៧៤,៧៧%** | **៦៨,៣១%** |
| ប្រគល់ផ្ទាល់ | _ | ១៤០.០០០ | ៨៥.៧២១ | ១៨.៨១៩ | ៤៦.៨២៤ | ៣៥៥,៥១% | ៨៣,០៧% |
| ឆ្លងកាត់ឃ្លាំង និងទីលាន | _ | ១៥.៧១២.៤០០ | ៤.៣៧៤.៩០២ | ២.៥៣៣.៤០១ | ២.៦០៣.៤៣០ | ៧២,៦៩% | ៦៨,០៤% |
| **បរិមាណកុងតែន័រឆ្លងកាត់** | TEUs | **៨០០.០០០** | **២០៩.៩១៥** | **១៥៩.១០៤** | **១៨៥.៨០៨** | **៣១,៩៤%** | **១២,៩៧%** |
| **នាំចូល** | _ | | **១០៥.៨៤៦** | **៨២.៧៦១** | **៩៧.៥២៩** | **២៧,៨៩%** | **៨,៥៣%** |
| មានទំនិញ | _ | | ៩៣.៩៩៦ | ៧៥.២៧៧ | ៨៤.៥៨៦ | ២៤,៨៧% | ១១,១២% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ្មានទំនិញ | _ | | ១១.៨៥០ | ៧.៤៨៤ | ១២.៩៤៣ | ៥៨,៣៤% | -៨,៤៤% |
| **នាំចេញ** | **_** | | **១០៤.០៦៩** | **៧៦.៣៤៣** | **៨៨.២៧៩** | **៣៦,៣២%** | **១៧,៨៩%** |
| មានទំនិញ | _ | | ៦៣.៩៥៨ | ៤៩.១២៥ | ៥៥.១១៧ | ៣០,១៩% | ១៦,០៤% |
| គ្មានទំនិញ | _ | | ៤០.១១១ | ២៧.២១៨ | ៣៣.១៦២ | ៤៧,៣៧% | ២០,៩៥% |
| **ចំនួននាវាចូលចត** | **គ្រឿង** | **១.៤៥៨** | **៣៧៦** | **៣៤០** | **៣៨២** | **១០,៥៩%** | **-១,៥៧%** |
| **ចំណុះផ្ទុកនាវា** | **តោន** | **១៤.៤០៤.០០០** | **៥.១៥០.៣៧៨** | **៣.៤១៧.៤៥៦** | **៣.០៧៨.៨៨១** | **៥០,៧១%** | **៦៧,២៨%** |
| នាវាដឹកកុងតែន័រ | គ្រឿង | | ២០៦ | ១៧១ | ១៦០ | ២០,៤៧% | ២៨,៧៥% |
| ចំណុះនាវាដឹកកុងតែន័រ | តោន | | ៣.៤៩៧.៧១៥ | ២.៣៨១.០៩៤ | ២.១១០.៤៦០ | ៤៦,៩០% | ៦៥,៧៣% |
| នាវាដឹកប្រេង និងហ្គាស | គ្រឿង | | ១២២ | ១១៤ | ១២៩ | ៧,០២% | -៥,៤៣% |
| ចំណុះនាវាដឹកប្រេង និងហ្គាស | តោន | | ៥៥៥.៩៦១ | ៤៩៩.០១៧ | ៤៨៦.៤១៧ | ១១,៤១% | ១៤,៣០% |
| នាវាដឹកទំនិញទូទៅ | គ្រឿង | | ៤០ | ៥៤ | ៩៣ | -២៥,៩៣% | -៥៦,៩៩% |
| ចំណុះនាវាដឹកទំនិញទូទៅ | តោន | | ៦៧១.៨៨៥ | ៤៩៥.៤៨០ | ៤៨២.០០៤ | ៣៥,៦០% | ៣៩,៣៩% |
| នាវាទេសចរណ៍ | គ្រឿង | | ៨ | ១ | ០ | ៧០០,០០% | ១០០,០០% |
| នាវាទេសចរណ៍ | តោន | | ៤២៤.៨១៧ | ៤១.៨៦៥ | ០ | ៩១៤,៧៣% | ១០០,០០% |
| ចំនួនទេសចរ | នាក់ | | ៦.២១២ | ២៣១ | ០ | ២៥៨៩,១៨% | ១០០,០០% |


បរិមាណទំនិញឆ្លងកាត់ កសស(តោន)
២,៥០០,០០០
២,០០០,០០០
១,៥០០,០០០
១,០០០,០០០
៥០០,០០០
0
២.០៧៤.៣១៣
១.៥៩៥.៥២៥
១.៧៤២.២២៥
ត្រីមាសទី៤ ឆ្នាំ២០២៣
ត្រីមាសទី៤ ឆ្នាំ២០២២
ត្រីមាសទី៤ឆ្នាំ២០២១


បរិមាណកុងតែន័រឆ្លងកាត់ កសស
TEUs
១០០,០០០
៩០,០០០
៨០,០០០
៧០,០០០
៦០,០០០
៥០,០០០
៤០,០០០
៣០,០០០
២០,០០០
១០,០០០
0
៩៣.៩៩៦
៧៥.២៧៧
៨៤.៥៨៦
៦៣.៩៥៨
៤៩.១២៥
៥៥.១១៧
៤០.១១១
២៧.២១៨
៣៣.១៦២
១១.៨៥០
៧.៤៨៤
១២.៩៤៣
ត្រីមាសទី៤ ឆ្នាំ២០២៣
ត្រីមាសទី៤ ឆ្នាំ២០២២
ត្រីមាសទី៤ ឆ្នាំ២០២១
នាំចូលមានទំនិញ
នាំចូលគ្មានទំនិញ
នាំចេញមានទំនិញ
នាំចេញគ្មានទំនិញ


ប្រទេសនាំចេញ និងនាំចូលកុងតែន័រ ត្រីមាសទី៤ ឆ្នាំ២០២៣
80.00%
60.00%
40.00%
20.00%
0.00%
66.10%
9.61%
2.91%
25.74%
4.09%
36.79%
20.28%
10.67%
0.01%
6.22%
3.12%
2.24%
3.48%
8.74%
ចិន
អឺរ៉ុប
អាមេរិក
អាស៊ី
អង់គ្លេស
ជប៉ុន
ផ្សេងៗ
នាំចូល
នាំចេញ

...


ចំណុះផ្ទុកនាវាចូលចត កសស
៤,០០០,០០០
៣,០០០,០០០
២,០០០,០០០
១,០០០,០០០
0
៣.៤៩៧.៧១៥
២.៣៨១.០៩៤
២.១១០.៤៦០
៥៥៥.៩៦១
៤៩៩.០១៧
៤៨៦.៤១៧
៦៧១.៨៨៥
៤៩៥.៤៨០
៤៨២.០០៤
៤២៤.៨១៧
៤១.៨៦៥
0
នាវាកុងតែន័រ
នាវាប្រេង និងហ្គាស
នាវាទំនិញទូទៅ
នាវាទេសចរណ៍
ត្រីមាសទី៤ ឆ្នាំ២០២៣
ត្រីមាសទី៤ ឆ្នាំ២០២២
ត្រីមាសទី៤ ឆ្នាំ២០២១


ចំនួននាវាចូលចត កសស
២៥០
២០០
១៥០
១០០
៥០
0
២០៦
១៧១
១៦០
១២២
១១៤
១២៩
៤០
៥៤
៩៣
៨
១
0
នាវាកុងតែន័រ
នាវាប្រេង និងហ្គាស
នាវាទំនិញទូទៅ
នាវាទេសចរណ៍
ត្រីមាសទី៤ ឆ្នាំ២០២៣
ត្រីមាសទី៤ ឆ្នាំ២០២២
ត្រីមាសទី៤ ឆ្នាំ២០២១

## ខ- រចនាសម្ព័ន្ធចំណូល

| បរិយាយ | ការិយបរិច្ឆេទបញ្ចប់ត្រឹម ត្រីមាសទី៤ ឆ្នាំ២០២៣ | | ការិយបរិច្ឆេទបញ្ចប់ត្រឹម ត្រីមាសទី៤ ឆ្នាំ២០២២ | | ការិយបរិច្ឆេទបញ្ចប់ត្រឹម ត្រីមាសទី៤ ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|
| | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) | ៤៩.៤៨៩.៥៩២ | ៤៩,៤៥% | ៣៦.៨២៤.១៣២ | ៤៧,៨២% | ៤២.១៨១.៨៧៧ | ៤៨,១១% |
| ចំណូលលើកដាក់លើទីលាន (LOLO) | ២៤.២៦៥.៧៩៣ | ២៤,២៥% | ២០.៤៨៤.៩៤៥ | ២៦,៦០% | ២៥.១៣១.៨៥៧ | ២៨,៦៦% |
| ចំណូលពីសេវាកម្មនាវាចរ | ២០.៣០២.៤៧៩ | ២០,២៩% | ១៥.៣២៩.១៦៥ | ១៩,៩០% | ១៥.៤៥៧.៧៣៨ | ១៧,៦៣% |
| ចំណូលស្តុក ឃ្លាំង និងទីលាន | ៤.០១៧.០២៧ | ៤,០១% | ៣.២៨២.១២២ | ៤,២៦% | ៤.១០៩.៨១៩ | ៤,៦៩% |
| ចំណូលដឹកជញ្ជូន | ២៧.៩៥៧ | ០,០៣% | ៧.៥៦៦ | ០,០១% | ២៦.៨៨៥ | ០,០៣% |
| ចំណូលនាវាទេសចរណ៍ | ១០១.២៧៩ | ០,១០% | ០ | ០,០០% | ០ | ០,០០% |
| ចំណូលពីតំបន់សេដ្ឋកិច្ចពិសេស | ៧១១.៣៨២ | ០,៧១% | ៦២៣.២៩៥ | ០,៨១% | ៤៩៣.៨៦៤ | ០,៥៦% |
| ចំណូលជួលទីតាំង | ៦៩៧.៣៦២ | ០,៧០% | ៣៧៨.០៣៨ | ០,៤៩% | ២០៥.៧១២ | ០,២៣% |
| ចំណូលផ្សេងៗទៀត | ៤៥៩.៩១០ | ០,៤៦% | ៨៣.៩៧៥ | ០,១១% | ៦៩.២៣០ | ០,០៨% |
| **ចំណូលសរុប** | **១០០.០៧២.៧៨០** | **១០០,០០%** | **៧៧.០១២.៨៣៨** | **១០០,០០%** | **៨៧.៦៧៦.៩៨១** | **១០០,០០%** |

# ផ្នែកទី ៣

# របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ

EY
Building a better working world

Ernst & Young (Cambodia) Ltd.
5th Floor, Emerald Building
#64 Preah Norodom Boulevard
Corner Street 178, Sangkat Chey Chumneah
Khan Daun Penh, Phnom Penh, Kingdom of Cambodia

Tel: +855 23 860 450/451
Fax: +855 23 217 805
ey.com

យោង៖ ៦១៨០៣៧៦២/៦៧៣៥៧៣៥៨

# របាយការណ៍ត្រួតពិនិត្យរបស់សវនករឯករាជ្យ

**ជូនចំពោះ៖ ភាគទុនិក នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ**

## *សេចក្តីផ្តើម*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលដែលភ្ជាប់ជាមួយនេះ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេលនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ របាយការណ៍លទ្ធផលពេញលេញសង្ខេបចន្លោះពេលសម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងរបាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល ព្រមទាំងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល សម្រាប់ការិយបរិច្ឆេទដប់ពីរខែបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងពត៌មានគោលនយោបាយគណនេយ្យសារវន្ត និងកំណត់សម្គាល់ពន្យល់ផ្សេងៗ។ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិ នៃកម្ពុជា លេខ៣៤ ស្តីពី *"របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"*។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបញ្ចេញសេចក្តីសន្និដ្ឋានចំពោះព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយផ្អែកទៅតាមការត្រួតពិនិត្យរបស់យើងខ្ញុំ។

## *វិសាលភាពនៃការត្រួតពិនិត្យ*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យដោយអនុលោមទៅតាមស្តង់ដាអន្តរជាតិ នៃកម្ពុជា ស្តីពីការងារត្រួតពិនិត្យលេខ ២៤១០ *"ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលដោយសវនករឯករាជ្យរបស់អង្គភាព"*។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរួមមាន ការសាកសួរដែលជាចម្បងទៅបុគ្គលទទួលខុសត្រូវលើបញ្ហាហិរញ្ញវត្ថុ និងគណនេយ្យ និងការអនុវត្តនីតិវិធីវិភាគ និងការត្រួតពិនិត្យផ្សេងទៀត។ ការត្រួតពិនិត្យ មានវិសាលភាពតិចជាង ការធ្វើសវនកម្មដែលអនុលោមតាមស្តង់ដាអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា។ ជាលទ្ធផល ការត្រួតពិនិត្យនេះមិនអាចឲ្យយើងខ្ញុំទទួលបានការធានាអះអាងថា យើងខ្ញុំនឹងដឹងរាល់បញ្ហាសំខាន់ៗទាំងឡាយដែលនឹងអាចត្រូវបានរកឃើញដូចនៅក្នុងការងារសវនកម្មនោះទេ។ ហេតុដូច្នេះហើយ យើងខ្ញុំមិនបញ្ចេញមតិយោបល់សវនកម្មនោះទេ។

**EY**
Building a better working world

***សេចក្តីសន្និដ្ឋាន***

ដោយផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ ពុំមានអ្វីដែលជាការចាប់អារម្មណ៍របស់យើងខ្ញុំ ដែលបណ្តាលឲ្យយើងខ្ញុំជឿជាក់ថាព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលដែលភ្ជាប់មកជាមួយនេះ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ មិនត្រូវបានរៀបចំឡើង (គ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់) ដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិ នៃកម្ពុជា លេខ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* នោះទេ។

ឡុន ស៊ីនរតនា
ដៃគូសវនករ

**អឺនស្ទ អេីន យ៉ាំង (ខេមបូឌា)**
ក្រុមហ៊ុនគណនេយ្យករជំនាញ
សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | *កំណត់សម្គាល់* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
|---|---|---|---|
| | | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | | *ពាន់រៀល* | *ពាន់រៀល* |
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យ និងបរិក្ខារ | ៦ | ១.០៩៣.៩៤៦.៣២២ | ៩៦៣.៧១២.៧៨១ |
| ទ្រព្យវិនិយោគ | ៧ | ២៩៥.២៧៤.៩៩៧ | ២៩៨.២៩៦.៧០៥ |
| ទ្រព្យសកម្មអរូបិយ | ៨ | ២.៨៣៧.៩៨៧ | ៤.០១៩.០៩១ |
| | | **១.៣៩១.៥៥៨.៨០៦** | **១.២១៦.០២៨.៥៧៧** |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | ៩ | ៣៤.៩៦៤.៣៣១ | ២៩.០៨៣.៣៦៤ |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | ១០ | ៤៨.០៧៣.១១៧ | ៣៧.៩៥៦.៨៦២ |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | | ១៥៩.៣៨៦.៨៧២ | ១០២.៩០៨.២៦៤ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | | ១៩.៣៩១.៨១៤ | ២៣.៥៨៦.៣៦៨ |
| | | **២៦១.២៦៦.១៣៤** | **១៩៣.៥៣៤.៨៥៨** |
| ទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់ | ១១ | - | ១៦.៥៨២.១៦១ |
| | | **២៦១.២៦៦.១៣៤** | **២១០.១១៧.០១៩** |
| **ទ្រព្យសកម្មសរុប** | | **១.៦០២.៨២៤.៩៤០** | **១.៤២៦.១៤៥.៥៩៦** |

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | *កំណត់សម្គាល់* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
|---|---|---|---|
| | | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | | *ពាន់រៀល* | *ពាន់រៀល* |
| **មូលធន និងបំណុល** | | | |
| **មូលធន** | | | |
| ដើមទុនបានបោះផ្សាយ | ១២ | ៨៥០.៣០២.៨២៨ | ៨៥០.៣០២.៨២៨ |
| បុព្វលាភភាគហ៊ុន | ១២ | ៦៧.៧១៥.២៣៥ | ៦៧.៧១៥.២៣៥ |
| ទុនបម្រុងផ្សេងៗ | ១៣ | ៩៩.៥០៦.០៩៤ | ៩១.០៩០.៥៧២ |
| ប្រាក់ចំណេញរក្សាទុក | | ៨០៤.៥២០.៧១៩ | ៣០៤.៦៩២.៣១១ |
| **មូលធនសរុប** | | **៩៧២.០៩៤.៨៧៦** | **៨៦៣.៨០០.៩៤៦** |
| **បំណុល** | | | |
| **បំណុលរយៈពេលវែង** | | | |
| ឥណទាន និងប្រាក់កម្ចី | ១៤ | ៣២៨.០៥៩.៦១០ | ៣៦៨.៦៧៧.០៨៧ |
| ប្រាក់កក់ពីភតិកៈ | | ១.០២១.២៥០ | ១.០២៩.២៥០ |
| កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ | ១៥ | ៧២.៨២២.១៦១ | ៦៩.៨២៨.០៥៣ |
| កាតព្វកិច្ចលើប្រាក់បំណាច់អតីតភាពការងារ | | ១.១០៧.៦៩៣ | ១.៣១៦.៧១៦ |
| ចំណូលពន្យារ | | ១៤.៣៨៦.៩២៩ | ១២.២០៣.២០០ |
| សម្បទានពីរាជរដ្ឋាភិបាល | ១៦ | ៤៧.១១១.៧០៤ | - |
| បំណុលពន្ធពន្យារ | | ៤១.០១០.៧៩៣ | ៣៣.០០៣.៣៥៤ |
| | | **៥០៥.៥៨០.១៩០** | **៥៨២.០៥៣.៦៦០** |
| **បំណុលរយៈពេលខ្លី** | | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | | ៣៦.៩៨៣.១០១ | ៣៥.០៦៦.០៧៣ |
| ឥណទាន និងប្រាក់កម្ចី | ១៤ | ៥៩.០៣៥.២២៥ | ៣០.៨៣៣.៩៨០ |
| កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ | ១៥ | ៥.០៦៨.៧៦៤ | ៦.២១៤.៣៦៣ |
| កាតព្វកិច្ចលើប្រាក់បំណាច់អតីតភាពការងារ | | ១២៧.៥៨៩ | ១២៧.៧៣៩ |
| ចំណូលពន្យារ | | ១៧០.៣៥៥ | ១៧១.៦៧៩ |
| សម្បទានពីរាជរដ្ឋាភិបាល | ១៦ | ៣.២១៤.៩៣០ | - |
| បំណុលពន្ធលើប្រាក់ចំណូល | | ២០.៧៤០.០៧០ | ៨.២៧៧.៦៤៦ |
| | | **១២៥.២៩៩.៩២៤** | **៨០.២៩០.៩៥០** |
| **បំណុលសរុប** | | **៦៣០.៧៨០.០៦៤** | **៥៦២.៣៨៤.៦៥០** |
| **មូលធន និងបំណុលសរុប** | | **១.៦០២.៨២៤.៩៤០** | **១.៨២៦.១៨៥.៥៩៦** |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីលេខ ១ ដល់លេខ ២៨ ជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។*

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍លទ្ធផលពេញលេញសង្ខេបចន្លោះពេល

សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | *កំណត់សម្គាល់* | *ការិយបរិច្ឆេទបីខែបញ្ចប់* | | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|---|---|
| | | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *បានធ្វើសវនកម្ម ពាន់រៀល* |
| **ចំណូល** | | | | | |
| ចំណូលពីកិច្ចសន្យាជាមួយអតិថិជន | ១៧ | ៩៨.៩៧១.៨៥៩ | ៧៦.៣៨៩.៥៤៣ | ៣៦១.៨៦៧.៦៧៧ | ៣៤១.៣៦៨.៨៤៩ |
| ចំណូលពីការជួល | ៧ | ៧១១.៣៨២ | ៦២៣.២៩៥ | ២.២៩៧.៦១៦ | ២.៣៧៤.៦៩៦ |
| ចំណូលសម្បទានពីរាជរដ្ឋាភិបាល | ១៦ | ៣៨៩.៥៣៩ | - | ៤៧៥.៤៧៨ | - |
| | | **១០០.០៧២.៧៨០** | **៧៧.០១២.៨៣៨** | **៣៦៤.៦៤០.៧៧១** | **៣៤៣.៧៤៣.៥៤៥** |
| **ចំណាយ** | | | | | |
| (ខាត)/ចំណេញផ្សេងៗ - សុទ្ធ | | (១.៨៦៤.៤១៨) | (៤១០.៧៨៧) | ៨៦.៣២១.២៦១ | ៤៤៩.៥៨៥ |
| ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | ១៨ | (៣១.០១៩.៥៣៥) | (២២.២៦១.៨០៦) | (១១៤.២៩០.៦៣៤) | (១០៥.៦៧២.០៩៧) |
| សម្ភារៈផ្គត់ផ្គង់ការប្រើប្រាស់ | ១៩ | (២៧.៦១៧.៩៩៧) | (២៦.១៤០.៩៥០) | (១១២.៦១០.០៧៥) | (១០៦.៣៦៤.៨៦១) |
| ចំណាយរំលស់ទ្រព្យសកម្មរូបិយ និងអរូបិយ | ២០ | (១២.៦៣៤.១៤២) | (១១.៦៩៣.០១៣) | (៤៧.៨៥១.៧៧៨) | (៤៥.៦៩៧.៧៤៨) |
| ការជួសជុល និងថែទាំ | | (៥១៩.១១៤) | (១.០៥១.៩៧២) | (២.១៩៤.៨៧៣) | (២.២៨៨.១១៦) |
| ចំណាយផ្សេងៗ | | (៤.៦៩៦.០៤០) | (៤.២៧៥.៤៧៤) | (៣៣.៤៥៦.៦៤៧) | (២៧.១២៦.៨៩៩) |
| | | **(៧៨.៣៥១.២៤៦)** | **(៦៥.៨៣៤.០០២)** | **(២២៤.០៨២.៧៤៦)** | **(២៨៦.៧០០.១៣៦)** |
| **ចំណេញប្រតិបត្តិការ** | | **២១.៧២១.៥៣៤** | **១១.១៧៨.៨៣៦** | **១៤០.៥៥៨.០២៥** | **៥៧.០៤៣.៤០៩** |
| (ចំណាយ)/ចំណូលហិរញ្ញវត្ថុ - សុទ្ធ | ២១ | (១២.៧៤០.៧៧៨) | (២៣.២១៧.៣៩៦) | ១៣.៨៣៤.៥១៩ | ៤០.៨៥៣.៦៧១ |
| **ចំណេញ/(ខាត) មុនគិតពន្ធលើប្រាក់ចំណូល** | | **៨.៩៨០.៧៥៦** | **(១២.០៣៨.៥៦០)** | **១៥៤.៣៩២.៥៤៤** | **៩៧.៨៩៧.០៨០** |
| ចំណាយពន្ធលើប្រាក់ចំណូល | ២២ | (៤.៩៤៨.៥៣៦) | (១.៩៦៦.៥២១) | (៣២.៤២៧.០៥៤) | (១៣.៧៤១.៨៦៥) |
| **ប្រាក់ចំណេញ/(ខាត) ក្នុងគ្រា** | | **៤.០៣២.២២០** | **(១៤.០០៥.០៨១)** | **១២១.៩៦៥.៤៩០** | **៨៤.១៥៥.២១៥** |
| **ប្រាក់ចំណេញ/(ខាត) ក្នុងគ្រារបស់ភាគហ៊ុនិក** | | **៤.០៣២.២២០** | **(១៤.០០៥.០៨១)** | **១២១.៩៦៥.៤៩០** | **៨៤.១៥៥.២១៥** |
| ចំណេញពីការវាស់វែងឡើងវិញលើការកំណត់កាតព្វកិច្ចអត្ថប្រយោជន៍ | ១៥. ២២ | - | - | - | ១១.៨៥៨.៨៤០ |
| **ប្រាក់ចំណេញ/(ខាត) ពេញលេញសរុបក្នុងគ្រារបស់ភាគហ៊ុនិក** | | **៤.០៣២.២២០** | **(១៤.០០៥.០៨១)** | **១២១.៩៦៥.៤៩០** | **៩៦.០១៤.០៥៥** |

ចំណេញ/(ខាត) ក្នុងមួយភាគហ៊ុនរបស់ភាគហ៊ុនិកនៃ ក.ស.ស ក្នុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| **ចំណេញ/(ខាត) មូលដ្ឋានក្នុងមួយភាគហ៊ុន** *(រៀល)* | ២៣ | **៤៧,០១** | **(១៦៣,២៨)** | **១.៤២១,៩៧** | **៩៨១,១៥** |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីលេខ ១ ដល់លេខ ២៨ ជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។*

## របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល

សម្រាប់ការិយបរិច្ឆេទដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | *កំណត់សម្គាល់* | *ដើមទុនបានបោះផ្សាយ (កំណត់សម្គាល់លេខ ១២)* | *បុព្វលាភភាគហ៊ុន (កំណត់សម្គាល់លេខ ១២)* | *ទុនបម្រុង (កំណត់សម្គាល់លេខ ១៣)* | *ប្រាក់ចំណេញរក្សាទុក* | *សរុប* |
|---|---|---|---|---|---|---|
| | | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** *(បានធ្វើសវនកម្ម)* | | **៤៥០.៣០២.៨២៨** | **៦៧.៧១៥.២៣៥** | **៩១.០៩០.៥៧២** | **៣០៤.៦៩២.៣១១** | **៨៦៣.៨០០.៩៤៦** |
| ប្រាក់ចំណេញក្នុងគ្រា | | - | - | - | ១២១.៩៦៥.៤៩០ | ១២១.៩៦៥.៤៩០ |
| ការផ្ទេរទៅទុនបម្រុង | ១៣ | - | - | ៨.៤១៥.៥២២ | (៨.៤១៥.៥២២) | - |
| ភាគលាភដែលបានប្រកាស និងបានបង់ | ២៤ | - | - | - | (១៣.៧២១.៥៦០) | (១៣.៧២១.៥៦០) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** *(មិនបានធ្វើសវនកម្ម)* | | **៤៥០.៣០២.៨២៨** | **៦៧.៧១៥.២៣៥** | **៩៩.៥០៦.០៩៤** | **៤០៤.៥២០.៧១៩** | **៩៧២.០៤៤.៨៧៦** |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ *(បានធ្វើសវនកម្ម)* | | **៤៥០.៣០២.៨២៨** | **៦៧.៧១៥.២៣៥** | **៣១.៧១៩.៨៣២** | **២៣៤.១៥៦.២៦៤** | **៧៨៣.៨៩៤.១៥៩** |
| ប្រាក់ចំណេញក្នុងគ្រា | | - | - | - | ៨៤.១៥៥.២១៥ | ៨៤.១៥៥.២១៥ |
| ចំណេញពីការវាយតម្លៃឡើងវិញលើការកំណត់កាតព្វកិច្ចអត្ថប្រយោជន៍ | | | - | - | ១១.៨៥៨.៨៤០ | ១១.៨៥៨.៨៤០ |
| **ប្រាក់ចំណេញពេញលេញសរុបក្នុងគ្រា** | | - | - | - | **៩៦.០១៤.០៥៥** | **៩៦.០១៤.០៥៥** |
| ផ្ទេរទៅទុនបម្រុង | ១៣ | - | - | ៩.៣៧០.៧៤០ | (៩.៣៧០.៧៤០) | - |
| ភាគលាភដែលបានប្រកាស និងបានបង់ | ២៤ | - | - | - | (១៦.១០៧.២៦៨) | (១៦.១០៧.២៦៨) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** *(បានធ្វើសវនកម្ម)* | | **៤៥០.៣០២.៨២៨** | **៦៧.៧១៥.២៣៥** | **៩១.០៩០.៥៧២** | **៣០៤.៦៩២.៣១១** | **៨៦៣.៨០០.៩៤៦** |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីលេខ ១ ដល់លេខ ២៨ ជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។*

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល
សម្រាប់ការិយបរិច្ឆេទដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | *កំណត់សម្គាល់* | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|
| | | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | | *ពាន់រៀល* | *ពាន់រៀល* |
| **សកម្មភាពប្រតិបត្តិការ** | | | |
| សាច់ប្រាក់បានពីប្រតិបត្តិការ | ២៥ | ៩២.៩៤២.៣៨០ | ៩៨.៥១៥.៣៣៥ |
| ពន្ធលើប្រាក់ចំណូលបានបង់ | | (១១.៩៥៧.១៩១) | (១០.៧៧៩.៨៩៥) |
| **លំហូរសាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ** | | **៨០.៩៨៥.១៨៩** | **៨៧.៧៣៥.៩៤០** |
| **សកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យ និងបរិក្ខារ | ៦ | (១១៨.៦៩៥.៣៦៩) | (៣៩.៣៨២.៨២៦) |
| ការទិញទ្រព្យវិនិយោគ | ៧ | (៣.៦២៨.៦៦១) | (១.២៧៧.៦៩៥) |
| ការដកប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ | | ១០៦.៨៩៨.៩៨៩ | ៩៩.៦៣៨.៩៩៤ |
| ការដាក់ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ | | (១៦០.៤២៥.៩៧៩) | (១០០.៨៥២.៥៩០) |
| ការទិញទ្រព្យអរូបិយ | | - | (២៥១.២៩៨) |
| ការប្រាក់បានទទួល | | ៥.០២៦.៦១៧ | ៣.៨៧០.៩៣៣ |
| ប្រាក់ទទួលបានពីការលក់ទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់ | | ៩៨.៧៩៧.៧៦៧ | - |
| ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | | - | ៥២៦.៥៣៨ |
| **លំហូរសាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(៧១.៩៧៧.៣៣៦)** | **(៣២.៧២៨.៩៤៩)** |
| **សកម្មភាពហិរញ្ញប្បទាន** | | | |
| ភាគលាភបានបង់ | | (១៣.៧២១.៥៦០) | (១៦.១០៧.២៦៨) |
| ការសងប្រាក់កម្ចី | | (២៧.២៩៧.៨២៨) | (២៨.៩៩០.៩៥២) |
| ការប្រាក់បានបង់ | | (៩.៤៣៣.៣៩៩) | (១០.៦៣៧.៩១៩) |
| សាច់ប្រាក់ពីប្រាក់កម្ចី | | ៧.០៩៧.២០៥ | ១.៧៩៦.០៨២ |
| សាច់ប្រាក់ពីឥណទានវិបារូបន៍ | | ៣០.១០៣.១២៥ | - |
| **លំហូរសាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន** | | **(១៣.២៥២.៤០៧)** | **(៥៣.៨៨៩.៥៥៧)** |
| **(តំហយ)/កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | **(៤.២៤៤.៥៥៤)** | **១.១១៧.៤៣៩** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមគ្រា | | ២៣.៥៨៦.៣៦៨ | ២២.៤៦៨.៩២៩ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងគ្រា** | | **១៩.៣៤១.៨១៤** | **២៣.៥៨៦.៣៦៨** |

*កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីលេខ ១ ដល់លេខ ២៨ ជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។*

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល

សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ១. ព័ត៌មានទូទៅ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស") គឺជាគ្រឹះស្ថានស្វយ័តសាធារណៈ ដែលស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថិតក្រោមការត្រួតពិនិត្យលើផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការិយាល័យកណ្តាលរបស់ខ្លួននៅក្នុងខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

ក.ស.ស គឺជានីតិបុគ្គលដែលមានលក្ខណៈស្វយ័តទាំងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមអនុក្រឹតលេខ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដែលបានផ្តល់ស្ថានភាពទូទៅឲ្យ ក.ស.ស ជាស្ថាប័នស្វយ័តសាធារណៈ។

ក.ស.ស បានចុះបញ្ជីជាសហគ្រាសសាធារណៈគ្រប់គ្រងដោយរដ្ឋ នៅក្រសួងពាណិជ្ជកម្ម និងទទួលបានវិញ្ញាបនបត្រចុះបញ្ជីលេខ Co.៩៧៨៩ET/២០១៧ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។ ភាគហ៊ុនប្រភេទ "គ" របស់ ក.ស.ស ត្រូវបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា "ផមក") នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៧។

បច្ចុប្បន្ន ក.ស.ស គឺជាកំពង់ផែសមុទ្រអន្តរជាតិ និងជាកំពង់ផែសមុទ្រជ្រៅពាណិជ្ជកម្មតែមួយគត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុលោមទៅតាមអនុក្រឹត្យស្តីពី បេសកកម្មរបស់ ក.ស.ស គឺផ្តល់សេវាកំពង់ផែសមុទ្រ និងសកម្មភាពផ្សេងៗដែលពាក់ព័ន្ធនឹងសេវាកំពង់ផែសមុទ្រដូចខាងក្រោម៖

- កណ្តាធារកិច្ចនាំនាវាចេញ - ចូល និងផ្តល់ភស្តុភាដល់នាវា ធ្វើបែបបទនាវា ចេញ ចូល
- លើកដាក់ ផ្ទេរចេញ និងដឹកជញ្ជូនទំនិញ
- រក្សា ស្តុកទំនិញ ឃ្លាំង - ទីលាន
- ការងារអភិវឌ្ឍន៍ ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរបស់ ក.ស.ស ដែលមានស្រាប់
- ទទួលខុសត្រូវ លើសុខមាលភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់ក្នុងតំបន់គ្រប់គ្រង និង
- ប្តេជ្ញាធ្វើការគ្រប់គ្រង និងចាត់ចែងសកម្មភាពប្រតិបត្តិការឲ្យមានប្រសិទ្ធភាព និងមានការរីកចម្រើន។

ក្នុងនាមជាស្ថាប័នស្វយ័តសាធារណៈ ក.ស.ស ទទួលអំណាច និងកាតព្វកិច្ចទាំងឡាយពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុទាំងនេះ។

ការិយាល័យចុះបញ្ជីរបស់ ក.ស.ស មានអាសយដ្ឋាននៅតិរៈវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នៃព្រះរាជាណាចក្រកម្ពុជា។

ក្រុមប្រឹក្សាភិបាលបានអនុម័តឲ្យចេញផ្សាយព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤។

## ២. មូលដ្ឋាននៃការរៀបចំ និងបម្រែបម្រួលនៃគោលការណ៍របស់ ក.ស.ស

### *២.១ មូលដ្ឋានក្នុងការរៀបចំ*

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលសម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិ នៃកម្ពុជាលេខ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* ("CIAS ៣៤")។ ក.ស.ស បានរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយផ្អែកលើមូលដ្ឋានដែល ក.ស.ស នឹងបន្តប្រតិបត្តិការជានិរន្តភាព។ ក្រុមប្រឹក្សាភិបាលសន្មតថា មិនមានភាពមិនប្រាកដប្រជា ជាសារវន្តណាមួយ ដែលនាំឲ្យមានការសង្ស័យលើការសន្មតរបស់ក្រុមប្រឹក្សាភិបាលនោះទេ។ ក្រុមប្រឹក្សាភិបាលធ្វើការវិនិច្ឆ័យថា មានការរំពឹងទុកសមស្របដែល ក.ស.ស មានធនធានគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការនាពេលអនាគត និងមិនតិចជាង១២ខែ គិតពីការិយបរិច្ឆេទបញ្ចប់ នៃរបាយការណ៍។

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ មិនរួមបញ្ចូលនូវរាល់ព័ត៌មាន និងកំណត់សម្គាល់ដែលបានតម្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មប្រចាំឆ្នាំទេ និងគួរត្រូវបានអានភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ ក.ស.ស សម្រាប់ការិយបរិច្ឆេទបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែលត្រូវបានរៀបចំឡើង ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ("CIFRSs")។

គោលនយោបាយគណនេយ្យខាងក្រោមត្រូវបានប្រើដោយ ក.ស.ស ក្នុងអំឡុងការិយបរិច្ឆេទ៖

*សម្បទានពីរាជរដ្ឋាភិបាល*

សម្បទានពីរាជរដ្ឋាភិបាល ត្រូវបានទទួលស្គាល់នៅពេល ដែលមានការធានាសមហេតុផលថា សម្បទាននឹងត្រូវបានទទួល ហើយលក្ខខណ្ឌដែលបានភ្ជាប់ជាមួយទាំងអស់នឹងត្រូវបានអនុលោមតាម។ នៅពេលដែលសម្បទានទាក់ទងនឹងធាតុចំណាយ សម្បទានពីរាជរដ្ឋាភិបាលត្រូវបានទទួលស្គាល់ជាចំណូលតាមមូលដ្ឋានជាប្រព័ន្ធក្នុងអំឡុងពេលដែលថ្លៃដើមពាក់ព័ន្ធនោះ (ដែលសម្បទានពីរាជរដ្ឋាភិបាលមានបំណងដើម្បីទូទាត់) ត្រូវបានទទួលស្គាល់ជាចំណាយ។ នៅពេលដែលសម្បទានទាក់ទងនឹងទ្រព្យសកម្ម សម្បទាននោះត្រូវបានទទួលស្គាល់ជាចំណូលក្នុងចំនួនស្មើគ្នាក្នុងអំឡុងពេលនៃការរំពឹងទុកអាយុកាលទ្រព្យសកម្មដែលពាក់ព័ន្ធ។

នៅពេលដែល ក.ស.ស ទទួលបានសម្បទានជាទ្រព្យសកម្មដែលមិនមែនជារូបិយប័ណ្ណ ទ្រព្យសកម្ម និងសម្បទានត្រូវបានកត់ត្រាក្នុងតម្លៃចម្ងតា និងទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬខាតក្នុងអំឡុង ពេលនៃការរំពឹងទុកនៃអាយុកាលទ្រព្យសកម្ម ដោយផ្អែកលើគំរូនៃការប្រើប្រាស់នៃអត្ថប្រយោជន៍ នៃទ្រព្យសកម្មដែលមាន ដោយការទទួលស្គាល់បណ្តាក់ស្មើគ្នាប្រចាំឆ្នាំ។

## ២. **មូលដ្ឋាននៃការរៀបចំ និងបម្រែបម្រួលនៃគោលការណ៍របស់ ក.ស.ស** (តពីទំព័រមុន)

### *២.២ ស្តង់ដាគណនេយ្យថ្មី ការបកស្រាយ និងការធ្វើវិសោធនកម្ម ដែលបានអនុវត្តដោយ ក.ស.ស*

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានប្រើក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ គឺដូចទៅនឹងគោលការណ៍គណនេយ្យសំខាន់ៗ ដែលបានប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ លើកលែងស្តង់ដាគណនេយ្យថ្មី ដែលនឹងមានប្រសិទ្ធភាពនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣។ ក.ស.ស មិនទាន់បានអនុវត្តមុនពេលកំណត់លើស្តង់ដា ការបកស្រាយ ឬ វិសោធនកម្មណាមួយ ដែលត្រូវបានបោះផ្សាយ តែមិនទាន់មានប្រសិទ្ធភាពទេ។

ស្តង់ដាគណនេយ្យដែលបានធ្វើវិសោធនកម្ម ដូចបានសង្ខេបខាងក្រោមនឹងអនុវត្តលើកទីមួយនៅក្នុងឆ្នាំ២០២៣ តែមិនប៉ះពាល់ដល់របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ ក.ស.ស។

- CIFRS ១៧ - *កិច្ចសន្យាធានារ៉ាប់រង*
- និយមន័យនៃការប៉ាន់ស្មានគណនេយ្យ - ការធ្វើវិសោធនកម្មលើ CIAS ៨
- ការលាតត្រដាងព័ត៌មានគោលនយោបាយគណនេយ្យ - ការធ្វើវិសោធនកម្មលើ CIAS ១ និង CIFRS សេចក្តីថ្លែងការណ៍អនុវត្តន៍ ២
- ពន្ធពន្យាពាក់ព័ន្ធនឹងទ្រព្យសកម្ម និងបំណុលដែលកើតចេញពីប្រតិបត្តិការតែមួយ - ការធ្វើវិសោធនកម្មលើ CIAS ១២។

## ៣. **ការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតរបស់គណៈគ្រប់គ្រង**

ការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល តម្រូវឲ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តគោលការណ៍គណនេយ្យ និងចំនួនដែលបានរាយការណ៍របស់ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ។ លទ្ធផលជាក់ស្តែងអាចនឹងខុសពីការប៉ាន់ស្មានទាំងនេះ។

ក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ការវិនិច្ឆ័យសំខាន់ដែលគណៈគ្រប់គ្រងបានធ្វើឡើងក្នុងការអនុវត្តគោលការណ៍គណនេយ្យរបស់ ក.ស.ស និងប្រភពសំខាន់ៗក្នុងការប៉ាន់ស្មានភាពច្បាស់លាស់ គឺដូចគ្នាទៅនឹងការវិនិច្ឆ័យដែលបានអនុវត្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

## ៤. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ**

### *៤.១ កត្តាហានិភ័យហិរញ្ញវត្ថុ*

ក.ស.ស ត្រូវប្រឈមមុខនឹងហានិភ័យផ្សេងៗដូចជាៈ ហានិភ័យទីផ្សារ (រួមមាន ហានិភ័យការប្តូររូបិយប័ណ្ណ និងហានិភ័យអត្រាការប្រាក់) ហានិភ័យឥណទាន និងហានិភ័យសាច់ប្រាក់ងាយស្រួល។

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៤. **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (តពីទំព័រមុន)

### ៤.១ *កត្តាហានិភ័យហិរញ្ញវត្ថុ* (តពីទំព័រមុន)

ការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនតម្រូវឲ្យរួមបញ្ចូលនូវព័ត៌មាន និងការលាតត្រដាងហានិភ័យហិរញ្ញវត្ថុទាំងអស់ដូចការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំទេ ហើយគួរអានភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

### ៤.២ *តម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់វែងតាមរំលស់ថ្លៃដើម*

វិធីសាស្ត្រ និងការសន្មត ដែលបានប្រើក្នុងការប៉ាន់ស្មានតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

(ក) *សាច់ប្រាក់ និងសាច់ប្រាក់សមមូល និងប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី* - តម្លៃយោងនៃគណនីទាំងនេះ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប ដោយសារវាមានរយៈពេលខ្លី។

(ខ) *គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ* - តម្លៃយោងដកសំវិធានធនលើអ៊ឹមភែរមិនមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប ដោយសារគណនីទាំងនេះស្ថិតនៅក្រោមលក្ខខណ្ឌឥណទានធម្មតា និងមានរយៈពេលខ្លី។

(គ) *គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ* - តម្លៃយោងនៃគណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ គឺត្រូវបានចាត់ទុកថាមានតម្លៃដូចគ្នាជាមួយតម្លៃសមស្រប ដោយសារគណនីទាំងនេះមានរយៈពេលខ្លី។

(ឃ) *ឥណទាន និងប្រាក់កម្ចី* - តម្លៃសមស្របនៃប្រាក់កម្ចី ត្រូវបានប៉ាន់ស្មានដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់ចេញក្នុងកិច្ចសន្យានាពេលអនាគត ដោយប្រើអត្រាប្រាក់កម្ចីនាពេលបច្ចុប្បន្ន។

ក្នុងអំឡុងការិយបរិច្ឆេទ ក.ស.ស មិនបានផ្លាស់ប្តូរវិធីសាស្ត្រ និងការសន្មត ដែលត្រូវបានប្រើប្រាស់ដើម្បីប៉ាន់ស្មានតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុទេ ហើយក៏មិនមានការផ្ទេរនៅក្នុងឋានានុក្រមនៃតម្លៃសមស្របដែរ។

## ៥. **ព័ត៌មានប្រតិបត្តិការតាមផ្នែក**

ក.ស.ស មានការរាយការណ៍តាមផ្នែកដែលមាននូវសេវារបស់កំពង់ផែដូចខាងក្រោម៖

- ការលើកដាក់ពីនាវា
- ការលើកដាក់លើទីលាន (LO-LO)
- សេវាកម្មផែ
- ការរក្សាទុកកុងតឺន័រ។

មិនមានប្រតិបត្តិការតាមផ្នែក ដែលត្រូវបានប្រមូលផ្តុំដើម្បីបង្កើតជាផ្នែកអាជីវកម្មប្រតិបត្តិការតាមផ្នែកដែលអាចរាយការណ៍បានខាងលើ។

## ៥. ព័ត៌មានប្រតិបត្តិការតាមផ្នែក (តពីទំព័រមុន)

ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ ("CODM") (ក្រុមគណៈគ្រប់គ្រង) ពិនិត្យរបាយការណ៍គ្រប់គ្រងផ្ទៃក្នុង ដែលបានរាយការណ៍អំពីលទ្ធផល នៃសេវាតាមផ្នែករបស់កំពង់ផែទាំងមូល ដើម្បីវាយតម្លៃអំពីលទ្ធផល និងការបែងចែកធនធាន។ ក្រុមគណៈគ្រប់គ្រងវាយតម្លៃអំពីលទ្ធផលនៃប្រតិបត្តិការតាមផ្នែក ដោយផ្អែកការវាស់វែងចំណូលដុល *(កំណត់សម្គាល់លេខ ១៧)*។ ក្រុមគណៈគ្រប់គ្រងក៏ពិនិត្យឡើងវិញលើចំណេញមុនគិតពន្ធ និងចំណេញសុទ្ធទាំងមូល ធៀបនឹងការិយបរិច្ឆេទមុនៗ។ លើសពីនេះ ក.ស.ស ក៏មានការវិនិយោគទ្រព្យសកម្មនៅតំបន់សេដ្ឋកិច្ចពិសេស ដែលមានធ្វើប្រតិបត្តិការជាភាគីម្ចាស់ទ្រព្យជួល និងទទួលបានចំណូលពីការជួលផងដែរ *(កំណត់សម្គាល់លេខ ៧)*។

ប្រាក់ចំណូលសំខាន់របស់ក.ស.ស ទទួលបានមកពីអតិថិជនខាងក្រៅ។ ក.ស.ស មានទីតាំងស្ថិតនៅក្នុងខេត្តព្រះសីហនុ ហើយប្រាក់ចំណូលភាគច្រើន មានប្រភពចេញពីខេត្តព្រះសីហនុ និងតំបន់ជុំវិញ។

ចំណូល ចំនួន ២៥.៣២៥.០៨២ ពាន់រៀល និង ៩៣.៣៩០.៦៥១ ពាន់រៀល ត្រូវបានទទួលពីអតិថិជនធំៗ របស់ ក.ស.ស ដែលរួមចំណែកយ៉ាងហោចណាស់ ១០ភាគរយ នៃចំណូលតាមផ្នែកដែលបាន រាយការណ៍សរុបសម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ (រៀងគ្នា)។

### *ប្រតិបត្តិការតាមរដូវកាល*

ផ្នែក 'សេវាកម្មកំពង់ផែ' គឺពឹងផ្អែកជាចម្បងលើកម្រិតនៃការនាំចូល និងនាំចេញទំនិញឆ្លងកាត់ដែលត្រូវបានជះឥទ្ធិពលដោយផ្ទាល់ ដោយតម្រូវការរបស់អតិថិជនចុងក្រោយសម្រាប់ទំនិញ។ ដោយសារលក្ខណៈតាមរដូវកាលនៃផ្នែកនេះ ប្រាក់ចំណូលដែលនឹងខ្ពស់ជាងមុនជាធម្មតាត្រូវបានរំពឹងទុកនៅក្នុងឆមាសទីពីរនៃឆ្នាំ។ ចំណូលខ្ពស់ក្នុងអំឡុងពេល ខែកក្កដា ដល់ ខែវិច្ឆិកា ភាគច្រើនបណ្តាលមកពីការកើនឡើងនៃកម្រិតទំនិញឆ្លងកាត់ ដោយសារតែតម្រូវការ និងឥរិយាបថចំណាយរបស់អតិថិជន ក្នុងអំឡុងរដូវកាលវិស្សមកាល។

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៦. ទ្រព្យ និងបរិក្ខារ

**២០២៣** *(មិនបានធ្វើសវនកម្ម)*

| | *ដីធ្លី* | *ការកែលម្អដីធ្លី* | *អគារ** | *បរិក្ខារ បច្ចេកទេស* | *គ្រឿងសង្ហារឹម និងគ្រឿងបំពាក់* | *កុំព្យូទ័រ និងបរិក្ខារ ការិយាល័យ* | *យានយន្ត* | *បរិក្ខារ កំពង់ផែសមុទ្រ** | *សំណង់កំពុង សាងសង់* | *ប៉ាំឡែត* | *សរុប* |
|---|---|---|---|---|---|---|---|---|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ *(បានធ្វើសវនកម្ម)* | ២៩៦.៧៣៥.៤០៩ | ៦០.៣៦៨.២២៨ | ៣៤៩.២៥៨.០៥៨ | ៣៩.៧៤២.៣១៧ | ២.៨៥៧.១០៩ | ១៣.១៨៧.២៧៨ | ៦០.៣០៨.៥៩៤ | ២៧៧.៥៥៤.៣៧៧ | ៤១.៤៤៥.៩៣៨ | ១.១១៦.៨៥៥ | ១.១៤២.៥៧៤.១៦៣ |
| ការទិញបន្ថែម* | - | ២.៩៨២.៣១២ | ៨.០៨៥.៨៣២ | ២.៨៥៦.៤១៣ | ៨៦១.៣២៤ | ៩៣៨.៦៨៦ | ២១.៩៧២.៨១៥ | ៥៣.៨២៩.៤៨៧ | ៧៨.១៣៨.៨៩៣ | - | ១៦៩.៦៦៥.៧៦២ |
| ការលុបចោល | - | - | - | - | (៩៤០.៩០៧) | (៦.០០០.៦៥៦) | - | - | - | - | (៦.៩៤១.៥៦៣) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | **២៩៦.៧៣៥.៤០៩** | **៦៣.៣៥០.៥៤០** | **៣៥៧.៣៤៣.៨៩០** | **៤២.៥៩៨.៧៣០** | **២.៧៧៧.៥២៦** | **៨.១២៥.៣០៨** | **៨២.២៨១.៤០៩** | **៣៣១.៣៨៣.៨៦៤** | **១១៩.៥៨៤.៨៣១** | **១.១១៦.៨៥៥** | **១.៣០៥.២៩៨.៣៦២** |
| **រំលស់បង្គរ** | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ *(បានធ្វើសវនកម្ម)* | - | (១០.២៨៤.៨៥៨) | (៤៩.៦៣៣.១៣៩) | (១៧.៩៣០.០២៤) | (២.២៣៣.៧២០) | (១០.៤៥៤.៩៦៥) | (១៧.១៩២.២៩១) | (៧០.០៩៥.៤៦៨) | - | (១.០៣៦.៩១៧) | (១៧៨.៨៦១.៣៨២) |
| រំលស់ | - | (២.៩៦៤.៨១០) | (១០.២៤៧.៤៣៥) | (៤.៣១៩.៦៧៥) | (៤៥៩.០០៨) | (១.៦៩៦.៨២២) | (៥.៦៦៦.៣១៨) | (១៤.៥៥៧.៩៨៨) | - | (១៨.៨១៩) | (៣៩.៩៣០.៨៧៥) |
| ការលុបចោល | - | - | - | - | ៩៤០.៩០៧ | ៥.៩៩៩.៣១០ | - | - | - | - | ៦.៩៤០.២១៧ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | **-** | **(១៣.២៤៩.៦៦៨)** | **(៥៩.៨៨០.៥៧៤)** | **(២២.២៤៩.៦៩៩)** | **(១.៧៥១.៨២១)** | **(៦.១៥២.៤៧៧)** | **(២២.៨៥៨.៦០៩)** | **(៨៤.៦៥៣.៤៥៦)** | **-** | **(១.០៥៥.៧៣៦)** | **(២១១.៨៥២.០៤០)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ** | | | | | | | | | | | |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | **២៩៦.៧៣៥.៤០៩** | **៥០.១០០.៨៧២** | **២៩៧.៤៦៣.៣១៦** | **២០.៣៤៩.០៣១** | **១.០២៥.៧០៥** | **១.៩៧២.៨៣១** | **៥៩.៤២២.៨០០** | **២៤៦.៧៣០.៤០៨** | **១១៩.៥៨៤.៨៣១** | **៦១.១១៩** | **១.០៩៣.៤៤៦.៣២២** |

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៦. ទ្រព្យ និងបរិក្ខារ (តពីទំព័រមុន)

**២០២២** *(បានធ្វើសវនកម្ម)*

| | *ដីធ្លី* | *ការកែលម្អដីធ្លី* | *អគារ* | *បរិក្ខារ បច្ចេកទេស* | *គ្រឿងសង្ហារឹម និងគ្រឿងបំពាក់* | *កុំព្យូទ័រ និងបរិក្ខារការិយាល័យ* | *យានយន្ត* | *បរិក្ខារកំពង់ផែសមុទ្រ* | *សំណង់កំពុងសាងសង់* | *ប៉ាឡែត* | *សរុប* |
|---|---|---|---|---|---|---|---|---|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ២៩៦.៧៣៥.៤០៩ | ៥៨.៨៥០.៩២២ | ៣៩៧.៥០៧.៦៩៥ | ៣៧.៥០៨.១០០ | ២.៤៧១.៧៧៦ | ១១.៧២៨.១២៦ | ៤៨.៨០៤.៦៥៩ | ២៧៦.៩៦៦.៩៦៩ | ២៥.៥២៤.៨០១ | ១.០២២.៧៦១ | ១.១០៧.១២១.២១៨ |
| ការទិញបន្ថែម | - | ១.៥១៧.៣០៦ | ១.៦៥០.៨០៥ | ២.២៣៤.២១៧ | ៣៨៥.៣៣៣ | ១.៤៥៩.១៥២ | ១២.៤៧៧.០៣៥ | ៥៨៧.៤០៨ | ១៦.០២០.៦៩៥ | ៩៤.០៩៤ | ៣៦.៤២៦.០៤៥ |
| ការលក់ | - | - | - | - | - | - | (៩៧៣.១០០) | - | - | - | (៩៧៣.១០០) |
| ការផ្ទេរ | - | - | ៩៩.៥៥៨ | - | - | - | - | - | (៩៩.៥៥៨) | - | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **២៩៦.៧៣៥.៤០៩** | **៦០.៣៦៨.២២៨** | **៣៩៩.២៥៨.០៥៨** | **៣៩.៧៤២.៣១៧** | **២.៨៥៧.១០៩** | **១៣.១៨៧.២៧៨** | **៦០.៣០៨.៥៩៤** | **២៧៧.៥៥៤.៣៧៧** | **៤១.៤៤៥.៩៣៨** | **១.១១៦.៨៥៥** | **១.១៤២.៥៧៤.១៦៣** |
| **រំលស់បង្គរ** | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | - | (៧.៣២២.៣៣៧) | (៣៩.៩២៣.១៩៣) | (១៣.៨២៧.៥៩១) | (១.៧៦៣.១២០) | (៧.៧១២.៦១១) | (១៣.២៥២.៣៣២) | (៥៦.១៣៦.៨៤៣) | - | (១.០១៧.៣៩៧) | (១៤០.៩៥៥.៣៧៤) |
| រំលស់ | - | (២.៩៦២.៥២១) | (៩.៧០៩.៩៤៦) | (៤.១០២.៤៨៣) | (៤៧០.៦០០) | (២.៧៤២.៣៥៤) | (៤.៣៨៦.៥២១) | (១៣.៩៥៨.៦២៥) | - | (១៩.៥២០) | (៣៨.៣៥២.៥៧០) |
| ការលក់ | - | - | - | - | - | - | ៤៤៦.៥៦២ | - | - | - | ៤៤៦.៥៦២ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **-** | **(១០.២៨៤.៨៥៨)** | **(៤៩.៦៣៣.១៣៩)** | **(១៧.៩៣០.០២៤)** | **(២.២៣៣.៧២០)** | **(១០.៤៥៤.៩៦៥)** | **(១៧.១៩២.២៩១)** | **(៧០.០៩៥.៤៦៨)** | **-** | **(១.០៣៦.៩១៧)** | **(១៧៨.៨៦១.៣៨២)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ** | | | | | | | | | | | |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **២៩៦.៧៣៥.៤០៩** | **៥០.០៨៣.៣៧០** | **២៤៩.៦២៤.៩១៩** | **២១.៨១២.២៩៣** | **៦២៣.៣៨៩** | **២.៧៣២.៣១៣** | **៤៣.១១៦.៣០៣** | **២០៧.៤៥៨.៩០៩** | **៤១.៤៤៥.៩៣៨** | **៧៩.៩៣៨** | **៩៦៣.៧១២.៧៨១** |

**ការទិញបន្ថែមនៃអគារ និងបរិក្ខារកំពង់ផែសមុទ្រ រួមមានស្ថានីយដឹកទំនិញកុងតឺន័រ និងរថលើកដាក់ចល័តនៅគែមផែមានចំនួន ៥.១៥៦.៣៣៩ ពាន់រៀល និង ៤៥.៦៤៥.៧៧៣ ពាន់រៀល (រៀងគ្នា) ដែលទទួលបានសម្បទានពីរាជរដ្ឋាភិបាល (យោងតាម កំណត់សម្គាល់លេខ ១៦)។*

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៦. **ទ្រព្យ និងបរិក្ខារ** (តពីទំព័រមុន)

ការផ្ទៀងផ្ទាត់ការទិញបន្ថែមជាសាច់ប្រាក់ និងមិនមែនជាសាច់ប្រាក់ (ការទិញទ្រព្យ និងបរិក្ខារ) ដូចខាងក្រោម៖

| | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|
| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* |
| ការទិញបន្ថែមក្នុងគ្រា (សាច់ប្រាក់ និងមិនមែនសាច់ប្រាក់) (មិនរាប់បញ្ចូលចំណាយការប្រាក់លើប្រាក់កម្ចីដែលត្រូវបានធ្វើមូលធនកម្ម) | ១៦៩.៩៤៧.៩៨១ | ៣៦.២៩១.៨៥៦ |
| សម្បទានពីរាជរដ្ឋាភិបាល *(កំណត់សម្គាល់លេខ ១៦)* | (៥០.៨០២.១១២) | - |
| កំណើនទឹកប្រាក់ត្រូវទូទាត់ទៅអ្នកផ្គត់ផ្គង់ | - | (១.៨៥៩.០៣០) |
| **សាច់ប្រាក់បានប្រើប្រាស់ក្នុងការទិញទ្រព្យ និងបរិក្ខារ** | **១១៩.១៤៥.៣៦៩** | **៣៤.៤៣២.៨២៦** |

ចំណាយការប្រាក់លើប្រាក់កម្ចី ដែលត្រូវបានធ្វើមូលធនកម្មលើទ្រព្យសកម្មដែលមានលក្ខណ: សម្បត្តិគ្រប់គ្រាន់ សម្រាប់ការិយបរិច្ឆេទដប់ពីរខែបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ មានចំនួន ២១៨.២៨១ ពាន់រៀល (នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២៖ ១៨៤.១៨៩ ពាន់រៀល)។

## ៧. **ទ្រព្យវិនិយោគ**

**២០២៣** *(មិនបានធ្វើសវនកម្ម)*

| | *ដីធ្លី* | *អគារ និងការកែលម្អដីធ្លី* | *សំណង់កំពុងសាងសង់* | *សរុប* |
|---|---|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ *(បានធ្វើសវនកម្ម)* | ១២២.៧១៥.៩៦៣ | ១៦៨.៧៧៤.៨៩៨ | - | ២៩១.៤៩០.៨៦១ |
| ការទិញបន្ថែម | ១.០៦៤.៧៦០ | ១.២៩៣.៧៤០ | ១.៣៥៩.០៩១ | ៣.៧១៧.៥៩១ |
| ការលក់ | - | (៦៤៣.៤៧១) | - | (៦៤៣.៤៧១) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | **១២៣.៧៨០.៧២៣** | **១៦៩.៤២៥.១៦៧** | **១.៣៥៩.០៩១** | **២៩៤.៥៦៤.៩៨១** |
| **រំលស់បង្គរ** | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ *(បានធ្វើសវនកម្ម)* | - | (៤៣.១៩៩.១៥៦) | - | (៤៣.១៩៩.១៥៦) |
| រំលស់ | - | (៦.៧៣៩.៧៩៩) | - | (៦.៧៣៩.៧៩៩) |
| ការលក់ | - | ៦៤៣.៤៧១ | - | ៦៤៣.៤៧១ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | - | **(៤៩.២៩០.៤៨៤)** | - | **(៤៩.២៩០.៤៨៤)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | **១២៣.៧៨០.៧២៣** | **១២០.១៣៤.៦៨៣** | **១.៣៥៩.០៩១** | **២៤៥.២៧៤.៤៩៧** |

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៧. **ទ្រព្យវិនិយោគ** (តពីទំព័រមុន)

**២០២២** *(បានធ្វើសវនកម្ម)*

| | *ដីធ្លី* | *អគារនិងការកែលម្អដីធ្លី* | *សំណង់កំពុងសាងសង់* | *សរុប* |
|---|---|---|---|---|
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ១២១.៦៣៣.៥៦៣ | ១៦៨.៥៧៩.៦៥៣ | - | ២៩០.២១៣.២១៦ |
| ការទិញបន្ថែម | - | ១៩៥.២៤៥ | ១.០៨២.៤០០ | ១.២៧៧.៦៤៥ |
| ការផ្ទេរ | ១.០៨២.៤០០ | - | (១.០៨២.៤០០) | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **១២២.៧១៥.៩៦៣** | **១៦៨.៧៧៤.៨៩៨** | **-** | **២៩១.៤៩០.៨៦១** |
| **រំលស់បង្គរ** | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | - | (៣៧.០១៧.៥១៧) | - | (៣៧.០១៧.៥១៧) |
| រំលស់ | - | (៦.១៧៦.៦៣៩) | - | (៦.១៧៦.៦៣៩) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **-** | **(៤៣.១៩៤.១៥៦)** | **-** | **(៤៣.១៩៤.១៥៦)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ** | | | | |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **១២២.៧១៥.៩៦៣** | **១២៥.៥៨០.៧៤២** | **-** | **២៤៨.២៩៦.៧០៥** |

ការទិញទ្រព្យវិនិយោគជាសាច់ប្រាក់៖

| | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|
| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* |
| ការទិញក្នុងគ្រា (សាច់ប្រាក់ និងមិនមែនសាច់ប្រាក់) | ៣.៧១៧.៥៩១ | ១.២៧៧.៦៤៥ |
| កំណើនទឹកប្រាក់ត្រូវទូទាត់ទៅអ្នកផ្គត់ផ្គង់ | (៨៨.៧៣០) | - |
| **សាច់ប្រាក់បានប្រើប្រាស់ក្នុងការទិញទ្រព្យវិនិយោគ** | **៣.៦២៨.៨៦១** | **១.២៧៧.៦៤៥** |

ចំនួនទឹកប្រាក់ទ្រព្យវិនិយោគខាងក្រោមនេះ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ប្រាក់ចំណេញពេញលេញសង្ខេបចន្លោះពេល ដែលពាក់ព័ន្ធលើអាជីវកម្មទ្រព្យវិនិយោគ៖

| | *ការិយបរិច្ឆេទបីខែបញ្ចប់* | | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|---|
| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | *មិនបានធ្វើសវនកម្ម* | *មិនបានធ្វើសវនកម្ម* | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| ចំណូលពីការជួល | ៧១១.៣៨២ | ៦២៣.២៩៥ | ២.២៩៧.៦១៦ | ២.៣៧៤.៦៨៦ |
| រំលស់ | (១.៦៩០.៦៦៥) | (១.៥៤៥.៧៦១) | (៦.៧៣៩.៧៩៩) | (៦.១៧៦.៦៣៩) |
| ចំណាយប្រតិបត្តិការផ្ទាល់ដែលកើតចេញពីទ្រព្យវិនិយោគដែលបង្កើតចំណូលពីការជួល | (៩៥៧.២៤៤) | (៧៩០.៣៩៧) | (៣.៣០៣.៨៧៥) | (២.៨៦៩.៥៨៥) |

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៨. ទ្រព្យសកម្មអរូបិយ

| | *២០២៣* | *២០២២* |
|---|---|---|
| | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* |
| **ថ្លៃដើម** | | |
| នាថ្ងៃទី១ ខែមករា *(បានធ្វើសវនកម្ម)* | ១១.៥៣៩.៣៨១ | ១១.២៨៨.០៨៣ |
| ទិញបន្ថែម | - | ២៥១.២៩៨ |
| **នាថ្ងៃទី៣១ ខែធ្នូ** | **១១.៥៣៩.៣៨១** | **១១.៥៣៩.៣៨១** |
| **រំលស់បង្គរ** | | |
| នាថ្ងៃទី១ ខែមករា *(បានធ្វើសវនកម្ម)* | (៧.៥២០.២៩០) | (៦.៣៥១.៧៥១) |
| រំលស់ | (១.១៨១.១០៤) | (១.១៦៨.៥៣៩) |
| **នាថ្ងៃទី៣១ ខែធ្នូ** | **(៨.៧០១.៣៩៤)** | **(៧.៥២០.២៩០)** |
| **តម្លៃក្នុងបញ្ជីសុទ្ធ** | | |
| **នាថ្ងៃទី៣១ ខែធ្នូ** | **២.៨៣៧.៩៨៧** | **៤.០១៩.០៩១** |

## ៩. សន្និធិ

| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
|---|---|---|
| | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* |
| សម្ភារៈផ្គត់ផ្គង់ប្រើប្រាស់ | ៣០.៤៧១.៧២១ | ២៥.៥០៧.៥៦៣ |
| វត្ថុធាតុដែលងាយឆេះ | ១.៧១២.៥២៤ | ២.០២១.៦៧៨ |
| ប្រេង និងប្រេងរំអិល | ២.៣៧៥.៤៩០ | ១.៦៤៩.៥២៧ |
| | **៣៤.៥៥៩.៧៣៥** | **២៩.១៧៨.៧៦៨** |
| សំវិធានធនលើអ៊ីមភែរមិននៃសន្និធិ | (៩៥.៤០៤) | (៩៥.៤០៤) |
| | **៣៤.៤៦៤.៣៣១** | **២៩.០៨៣.៣៦៤** |

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ១០. គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ

| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
|---|---|---|
| | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* |
| គណនីអតិថិជន | ៤៣.៣០៥.២៧៨ | ៣០.៥៦៧.៩១០ |
| សំវិធានធនលើការខាតបង់ឥណទានបានរំពឹងទុក *(កំណត់សម្គាល់ ក)* | (១៤៥.៨៩៨) | (២៣២.៩៥០) |
| **គណនីអតិថិជនសុទ្ធ** | **៤៣.១៥៩.៣៨០** | **៣០.៣៣៤.៩៦០** |
| បុរេប្រទានឲ្យក្រសួងសាធារណការ និងដឹកជញ្ជូន *(កំណត់សម្គាល់ ខ)* | ១.២២១.៣០៣ | ៧.២២១.៣០៣ |
| បុរេប្រទានទៅអ្នកផ្គត់ផ្គង់ | ៣.៦០៦.៩៣១ | ៣១៤.៤៨៨ |
| ចំណាយបង់មុន | ៨៥.៩០៣ | ៨៦.១១១ |
| **គណនីត្រូវទទួលផ្សេងៗ** | **៤.៩១៣.៧៣៧** | **៧.៦២១.៩០២** |
| | **៤៨.០៧៣.១១៧** | **៣៧.៩៥៦.៨៦២** |

អតិថិជនរបស់ ក.ស.ស មានភ្នាក់ងារដឹកជញ្ជូនក្នុងស្រុក និងអន្តរជាតិនានា។ គណនីអតិថិជន គឺជាគណនីមានរយៈពេលខ្លី។

(ក) បម្រែបម្រួលសំវិធានធនលើការខាតបង់ឥណទានបានរំពឹងទុក របស់គណនីអតិថិជនមានដូចខាងក្រោម៖

| | *២០២៣* | *២០២២* |
|---|---|---|
| | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា *(បានធ្វើសវនកម្ម)* | ២៣២.៩៥០ | ៣២៩.២៤១ |
| បញ្ច្រាស់ក្នុងគ្រា/ឆ្នាំ | (៨៧.០៥២) | (៩៦.២៩១) |
| **នាថ្ងៃទីថ្ងៃទី៣១ ខែធ្នូ** | **១៤៥.៨៩៨** | **២៣២.៩៥០** |

(ខ) គណនីនេះជាសមតុល្យបុរេប្រទានសាច់ប្រាក់ ទៅក្រសួងសាធារណការ និងដឹកជញ្ជូន ដែលមានចំនួន ១.២២១.៣០៣ ពាន់រៀល ដោយយោងទៅតាមលិខិតចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ និងត្រូវសងក្នុងឆ្នាំ២០១៩។ បុរេប្រទានសាច់ប្រាក់នេះត្រូវបានប្រើប្រាស់សម្រាប់ការសាងសង់អគារការិយាល័យរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។ រយៈពេលនៃការទូទាត់សងមិនត្រូវបានបញ្ជាក់។ សាច់ប្រាក់បុរេប្រទាន ទៅក្រសួងសាធារណការ និងដឹកជញ្ជូននៅមិនទាន់សងនៅឡើយ គិតចាប់ពីថ្ងៃនៃរបាយការណ៍នេះ។

ក្នុងឆ្នាំ២០២២ បុរេប្រទានសាច់ប្រាក់បន្ថែមចំនួន ៦ ពាន់លានរៀលត្រូវបានផ្តល់ទៅក្រសួងសាធារណការ និងដឹកជញ្ជូនដើម្បីប្រើប្រាស់សម្រាប់ការសាងសង់ផ្លូវ ដោយយោងទៅលិខិតស្នើសុំចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២។ នៅថ្ងៃទី១៤ ខែមីនា និងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ក្រសួងសាធារណការ និងដឹកជញ្ជូនបានសង ៥ ពាន់លានរៀល និង ១ ពាន់លានរៀល ដល់ ក.ស.ស (រៀងគ្នា)។

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ១១. ទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់

នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ ក.ស.ស បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយអតិថិជន ដើម្បីលក់ដីមួយកន្លែង (ទំហំ ១៣០ ហិកតា) មានទីតាំងស្ថិតនៅឃុំបិតត្រាង ដែលដីនេះត្រូវបានទិញក្នុងគោលបំណងដើម្បីទុកចំណេញ។ តម្លៃក្នុងកិច្ចសន្យាសរុបមានចំនួន ២៦ លានដុល្លារអាមេរិក ឬ ១០៥.៣០០ លានរៀល ដែលមានតម្លៃ ២០ ដុល្លារអាមេរិក ឬ ៨១.០០០ រៀលក្នុងមួយម៉ែត្រការ៉េ។ ក.ស.ស បានទទួលទឹកប្រាក់ចំនួន ២ លានដុល្លារអាមេរិក ជាប្រាក់កក់នៅថ្ងៃចុះកិច្ចសន្យា ហើយអ្នកទិញនឹងទូទាត់ប្រាក់ដែលនៅសល់នៅពេលបញ្ចប់ការផ្ទេរ។ ទំហំដីដែលបានផ្លាស់ប្តូរ ដោយផ្អែកលើការធានា ជាផ្នែកមួយនៃ ដំណើរការផ្ទេរកម្មសិទ្ធិ ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ អ្នកទិញនឹងទូទាត់តាមទំហំដីដែលបានបញ្ជាក់ក្នុងប្លង់ដាក់ស្តែងក្នុងតម្លៃ ២០ ដុល្លារអាមេរិក ឬ ៨១ ពាន់រៀល ក្នុងមួយម៉ែតការ៉េ។ ពីពេលនោះមក ទ្រព្យសកម្មនោះត្រូវបានចាត់ថ្នាក់ និងបង្ហាញជាទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់។

នៅខែមករា ឆ្នាំ២០២៣ ដំណើរការនៃការផ្ទេរប្លង់រឹង ត្រូវបានបញ្ចប់។ ទំហំដី ដែលបានបញ្ជាក់ គឺ ១.៣០៩.២៧៥ ម៉ែត្រការ៉េ ដែលយោងទៅតាមប្លង់រឹងដែលចេញដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ តម្លៃកិច្ចសន្យា ដែលនៅសល់ត្រូវបានទូទាត់ និងទទួលនៅខែកុម្ភៈ ឆ្នាំ២០២៣។ ប្រាក់ចំណេញទទួលបានពីការលក់ចំនួន ៨៤.៨១៥.៩៩៧ ពាន់រៀល ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញផ្សេងៗ - ប្រាក់ចំណេញ ឬ ខាតសុទ្ធក្នុងគ្រា។

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ១២. ដើមទុនបានបោះផ្សាយ និងបុព្វលាភភាគហ៊ុន

| | *ភាគហ៊ុនប្រភេទ "ក"* | | *ភាគហ៊ុនប្រភេទ "ខ"* | | *ភាគហ៊ុនប្រភេទ "គ"* | | *បុព្វលាភភាគហ៊ុន* | *សរុប* |
|---|---|---|---|---|---|---|---|---|
| | *ចំនួនភាគហ៊ុន* | *ពាន់រៀល* | *ចំនួនភាគហ៊ុន* | *ពាន់រៀល* | *ចំនួនភាគហ៊ុន* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ *(មិនបានធ្វើសវនកម្ម)* | **៣៦៩.៥៣០.៨៦១** | **៣៦៩.៥៣០.៨៦១** | **៦៩.៣២៨.៩៧៥** | **៦៩.៣២៨.៩៧៥** | **២១.៩៩២.៩៩២** | **២១.៩៩២.៩៩២** | **៦៧.៧១៥.២៣៥** | **៥១៨.០១៨.០៦៣** |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ *(បានធ្វើសវនកម្ម)* | **៣៦៩.៥៣០.៨៦១** | **៣៦៩.៥៣០.៨៦១** | **៦៩.៣២៨.៩៧៥** | **៦៩.៣២៨.៩៧៥** | **២១.៩៩២.៩៩២** | **២១.៩៩២.៩៩២** | **៦៧.៧១៥.២៣៥** | **៥១៨.០១៨.០៦៣** |

យោងតាមមាត្រា ១១ នៃលក្ខន្តិកៈ ក.ស.ស ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ ដើមទុនដែលមានស្រាប់ចំនួន ៩២៨.៨៥៩.៨៣៦.០០០ រៀល ត្រូវបានបែងចែកទៅជាភាគហ៊ុនប្រភេទ "ក" ចំនួន ៣៦៩.៥៣០.៨៦១ ហ៊ុន ដើមទុនប្រភេទ "ខ" ចំនួន ៦៩.៣២៨.៩៧៥ ហ៊ុន ដោយមានតម្លៃចារិក ១.០០០ រៀល ក្នុងមួយភាគហ៊ុន។ ទាំងភាគហ៊ុនប្រភេទ "ក" និងភាគហ៊ុនប្រភេទ "ខ" ត្រូវបានកាន់កាប់ដោយរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ភាគហ៊ុនប្រភេទ "ក" មិនទទួលបានភាគលាភទេ ហើយក៏មិនមានសិទ្ធិបោះឆ្នោតដែរ លើកលែងតែលក្ខខណ្ឌមួយចំនួនដូចបានលម្អិតក្នុងមាត្រា ៩ នៃលក្ខន្តិកៈ ក.ស.ស ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩។ ភាគហ៊ុនប្រភេទ "ខ" មានសិទ្ធិបោះឆ្នោត និងទទួលភាគលាភដែលត្រូវបានអនុម័តដោយ ក្រុមប្រឹក្សាភិបាល។ ចំនួនភាគហ៊ុន ប្រភេទ "គ" មានចំនួន ២១.៩៩២.៩៩២ ភាគហ៊ុនដែលមាន តម្លៃចារិក ១.០០០ រៀលក្នុងមួយភាគហ៊ុន។ ភាគហ៊ុនប្រភេទ "គ" ដែលបានបោះផ្សាយទាំងអស់ ត្រូវបានទូទាត់រួចរាល់ទាំងស្រុង។

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ១២. ដើមទុនបានបោះផ្សាយ និងបុព្វលាភភាគហ៊ុន (តពីទំព័រមុន)

សេចក្តីលម្អិតនៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត មានដូចខាងក្រោម៖

| | *ភាគរយ* | *ចំនួនភាគហ៊ុន* | *ពាន់រៀល* |
|---|---|---|---|
| **ភាគហ៊ុនិក** | | | |
| ភាគហ៊ុនប្រភេទ "ខ" | | | |
| រាជរដ្ឋាភិបាលកម្ពុជា | **៧៥%** | **៦៤.៣២៨.៩៧៥** | **៦៤.៣២៨.៩៧៥** |
| ភាគហ៊ុនប្រភេទ "គ" | | | |
| ក្រុមហ៊ុន Kamigumi Co.. Ltd | ១៣% | ១១.១៥០.៣២៤ | ១១.១៥០.៣២៤ |
| អ្នកវិនិយោគសាធារណៈ | ១២% | ១០.២៩២.៦៦៨ | ១០.២៩២.៦៦៨ |
| | **២៥%** | **២១.៤៤២.៩៩២** | **២១.៤៤២.៩៩២** |
| | **១០០%** | **៨៥.៧៧១.៩៦៧** | **៨៥.៧៧១.៩៦៧** |

## ១៣. ទុនបម្រុងផ្សេងៗ

| | *២០២៣* *មិនបានធ្វើសវនកម្ម* *ពាន់រៀល* | *២០២២* *បានធ្វើសវនកម្ម* *ពាន់រៀល* |
|---|---|---|
| នាថ្ងៃទី១ ខែមករា *(បានធ្វើសវនកម្ម)* | ៤១.០៩០.៥៧២ | ៣១.៧១៩.៨៣២ |
| បូក៖ ទុនបម្រុងទូទៅ | ៤.២០៧.៧៦១ | ៤.៦៨៥.៣៧០ |
| ទុនបម្រុងតាមច្បាប់ | ៤.២០៧.៧៦១ | ៤.៦៨៥.៣៧០ |
| **នាថ្ងៃទី៣១ ខែធ្នូ** | **៤៩.៥០៦.០៩៤** | **៤១.០៩០.៥៧២** |

មាត្រា ៦៥ នៃលក្ខន្តិកៈក.ស.ស ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ ចែងថា ប្រាក់ចំណេញប្រចាំឆ្នាំរបស់ ក.ស.ស បន្ទាប់ពីទូទាត់ការខាតយោងទៅមុខ (ប្រសិនបើមាន) ត្រូវបានបែងចែកទៅជាទុនបម្រុងទូទៅក្នុងអត្រា ៥ ភាគរយ និងទុនបម្រុងតាមច្បាប់នៅ អត្រា ៥ ភាគរយ។

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ១៤. ឥណទាន និងប្រាក់កម្ចី

| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
|---|---|---|
| | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* |
| ឥណទាន និងប្រាក់កម្ចីពី៖ | | |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៣ (i) | ៣៦.៣៨២.០៧៤ | ៤៤.៨១៨.៩០៣ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៤ (i) | ៨៣.១៨៩.៩៣២ | ៩១.៩៦៦.៩៧២ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៦ (i) | ៤.៦៦៧.៨៣៨ | ៥.៣៥៤.៣៨៦ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៨ (i) | ៨១.៩៨៨.០៥៧ | ៩០.៥៩០.០០៩ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - (JICA) - ឥណទានលេខ CP-P១០ (i) | ១៣៧.២៧៥.៣០៨ | ១៤៩.៥៨២.០៣៩ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - (JICA) - ឥណទានលេខ CP-P២១ (i) | ១៣.៥២៨.៥០១ | ១៣.៦៩៨.៧៥៨ |
| ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ("FTB") - ឥណទានវិបារូបន៍ (ii) | ៣០.១០៣.១២៥ | - |
| | **៣៨៧.០៩៤.៨៣៥** | **៣៩៥.១១០.៥៧៧** |

(i) ប្រាក់កម្ចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ – (JBIC) និង (JICA)

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចីជាមួយ Japan International Cooperation Agency ("JICA") និង Japan Bank for International Cooperation ("JBIC") ទាក់ទិនទៅនឹងប្រតិបត្តិការដែលពាក់ព័ន្ធនឹង ក.ស.ស។ ប្រាក់កម្ចីត្រូវបានបញ្ចេញដោយផ្ទាល់ពី JICA និង JBIC ទៅឲ្យអ្នកផ្គត់ផ្គង់របស់ ក.ស.ស។ ក.ស.ស នឹងសងប្រាក់កម្ចីដោយផ្ទាល់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមកាលវិភាគសងប្រាក់។

(ii) ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ("FTB")

នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ ក.ស.ស បានចុះកិច្ចព្រមព្រៀងជាមួយ FTB សម្រាប់ឥណទានវិបារូបន៍ ដែលមានកម្រិតឥណទាន ចំនួន ៣០.២២៩.០០០ ពាន់រៀល (ស្មើនឹង ៧.៤០០.០០០ ដុល្លារអាមេរិក)។ ឥណទានវិបារូបន៍នេះមានអត្រាការប្រាក់ ៧.៥០% ក្នុងមួយឆ្នាំ។ ឥណទានវិបារូបន៍ត្រូវបានធានាដោយប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លីរបស់ ក.ស.ស ជាមួយនឹង FTB ចំនួន ៣២.៦៨០.០០០ ពាន់រៀល (ស្មើនឹង ៨.០០០.០០០ ដុល្លារអាមេរិក)។

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ១៤. **ឥណទាន និងប្រាក់កម្ចី** (តពីទំព័រមុន)

កាលកំណត់របស់ឥណទាន និងប្រាក់កម្ចីទាំងនេះមានដូចខាងក្រោម៖

| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
|---|---|---|
| | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *បានធ្វើសវនកម្ម ពាន់រៀល* |
| រយៈពេលខ្លី | | |
| រហូតដល់មួយឆ្នាំ | **៥៩.០៣៥.២២៥** | **៣០.៤៣៣.៤៩០** |
| រយៈពេលវែង | | |
| លើសមួយឆ្នាំទៅពីរឆ្នាំ | ២៦.៨១៥.៧៣៨ | ២៨.០៧២.៧៥៣ |
| លើសពីរឆ្នាំទៅប្រាំឆ្នាំ | ៨០.៨៤៧.២១៥ | ៨៩.២១៨.២៦០ |
| លើសប្រាំឆ្នាំ | ២២០.៧៩៦.៦៥៧ | ២៥២.៣៨៦.០៧៤ |
| | **៣២៨.០៥៩.៦១០** | **៣៦៩.៦៧៧.០៨៧** |
| | **៣៨៧.០៩៤.៨៣៥** | **៣៩៥.១១០.៥៧៧** |

តម្លៃយោង និងតម្លៃសមស្របរបស់ឥណទាន និងប្រាក់កម្ចី មានដូចខាងក្រោម៖

| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
|---|---|---|
| | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *បានធ្វើសវនកម្ម ពាន់រៀល* |
| *តម្លៃយោង* | | |
| រយៈពេលខ្លី | ៥៩.០៣៥.២២៥ | ៣០.៤៣៣.៤៩០ |
| រយៈពេលវែង | ៣២៨.០៥៩.៦១០ | ៣៦៩.៦៧៧.០៨៧ |
| | **៣៨៧.០៩៤.៨៣៥** | **៣៩៥.១១០.៥៧៧** |
| *តម្លៃសមស្រប* | | |
| រយៈពេលខ្លី | ៥៩.០៣៥.២២៥ | ៣០.៤៣៣.៤៩០ |
| រយៈពេលវែង | ៣២៨.០៥៩.៦១០ | ៣៦៩.៦៧៧.០៨៧ |
| | **៣៨៧.០៩៤.៨៣៥** | **៣៩៥.១១០.៥៧៧** |

តម្លៃសមស្របត្រូវបានគណនាអាស្រ័យទៅតាម កិច្ចសន្យាលំហូរសាច់ប្រាក់អប្បហារនាពេលអនាគត ដោយប្រើអត្រាប្រាក់កម្ចីនាពេលបច្ចុប្បន្ន។ វាត្រូវបានចាត់ថ្នាក់ជាតម្លៃសមស្របកម្រិតទី៣ ក្នុងឋានានុក្រមតម្លៃសមស្រប ដោយសារមានការរួមបញ្ចូល នូវធាតុចូលដែលមិនអាចអង្កេតបាន រួមមានហានិភ័យឥណទានរបស់ភាគីដៃគូជាដើម។

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ១៤. **ឥណទាន និងប្រាក់កម្ចី** (តពីទំព័រមុន)

ឥណទាន និងប្រាក់កម្ចីជារូបិយប័ណ្ណផ្សេងៗក្រៅពីរូបិយប័ណ្ណមុខងារមានដូចខាងក្រោម៖

| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
|---|---|---|
| | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* |
| ប្រាក់យ៉េនជប៉ុន | ២៧៣.៨០១.៧៧៨ | ៣០៣.៦៤៤.១០៥ |
| ប្រាក់ដុល្លារអាមេរិក | ១១៣.២៩៣.០៥៧ | ៩១.៤៦៦.៤៧២ |
| | **៣៨៧.០៩៤.៨៣៥** | **៣៩៥.១១០.៥៧៧** |

អត្រាការប្រាក់ប្រចាំឆ្នាំនៃឥណទាន និងប្រាក់កម្ចីនីមួយៗ មានដូចខាងក្រោម៖

| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
|---|---|---|
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៣ | ៣,០០% | ៣,០០% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៤ | ៣,៧០% | ៣,៧០% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៦ | ៣,០០% | ៣,០០% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - (JBIC) - ឥណទានលេខ CP-P៨ | ២,៦៥% | ២,៦៥% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - (JICA) - ឥណទានលេខ CP-P១០ | ១,៦៥% | ១,៦៥% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - (JICA) - ឥណទានលេខ CP-P២១ | ១,២៦% | ១,២៦% |

## ១៥. **កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍**

ចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មានដូចខាងក្រោម៖

| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
|---|---|---|
| | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* |
| **តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍នាចុងការិយបរិច្ឆេទ/ឆ្នាំ** | **៧៧.៨៩០.៩២៥** | **៧៦.០៣៨.៤១៦** |

កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍នាចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ខាងលើមិនពាក់ព័ន្ធនិងការវិនិយោគ។

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ១៥. **កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍** (តពីទំព័រមុន)

បម្រែបម្រួលកាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ក្នុងការិយបរិច្ឆេទ/ឆ្នាំ មានដូចខាងក្រោម៖

| | *២០២៣* | *២០២២* |
|---|---|---|
| | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា *(បានធ្វើសវនកម្ម)* | ៧៦.០៣៨.៤១៦ | ៨៨.១៨០.៩៨៤ |
| ចំណាយលើសេវាកម្មក្នុងគ្រា | ១.៨១១.៩៩២ | ២.០៥៧.៧៥៩ |
| ចំណាយការប្រាក់ | ៤.៧៩៥.៦៣៩ | ៤.៦៣៨.៤៤៦ |
| អត្ថប្រយោជន៍បានបង់ | (៤.៧៥៤.៦២២) | (៤.០១៥.២២៤) |
| ចំណេញពីការវាយតម្លៃឡើងវិញនៃបម្រែបម្រួលការសន្មតនៃការវាយតម្លៃ | - | (១៤.៨២៣.៥៤៩) |
| **នាថ្ងៃទី៣១ ខែធ្នូ** | **៧៧.៨៩០.៩២៥** | **៧៦.០៣៨.៤១៦** |
| រយៈពេលខ្លី | ៥.០៦៨.៧៦៤ | ६.២១៤.៣៦៣ |
| រយៈពេលវែង | ៧២.៨២២.១៦១ | ៦៩.៨២៤.០៥៣ |
| | **៧៧.៨៩០.៩២៥** | **៧៦.០៣៨.៤១៦** |

ចំណាយអត្ថប្រយោជន៍សោធននិវត្តន៍ ត្រូវបានទទួលស្គាល់នៅក្នុងខ្ទង់ ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ និងការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តឡើងវិញ នៅក្នុងរបាយការណ៍ចំណេញពេញលេញចន្លោះពេល ដូចខាងក្រោម៖

| | *ការិយបរិច្ឆេទបីខែបញ្ចប់* | | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|---|
| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | *មិនបានធ្វើសវនកម្ម* | *មិនបានធ្វើសវនកម្ម* | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| ចំណាយលើសេវាកម្មក្នុងគ្រា | ៤៥២.៨៧៣ | ៥១៤.៤៤០ | ១.៨១១.៩៩២ | ២.០៥៧.៧៥៩ |
| ចំណាយការប្រាក់ | ១.១៩៨.៩១០ | ១.១៥៩.៦១១ | ៤.៧៩៥.៦៣៩ | ៤.៦៣៨.៤៤៦ |
| | **១.៦៥១.៧៨៣** | **១.៦៧៤.០៥១** | **៦.៦០៧.១៣១** | **៦.៦៩៦.២០៥** |

ការសន្មតសំខាន់ជាចម្បង មានដូចខាងក្រោម៖

| | *២០២៣* | *២០២២* |
|---|---|---|
| មធ្យមភាគនៃឆ្នាំបម្រើការងារ | ១៩,៩ | ១៩,៩ |
| អត្រាអប្បហារក្នុងមួយឆ្នាំ | ៦,៥% | ៦,៥% |
| អត្រាកំណើនប្រាក់បៀវត្សរ៍ក្នុងមួយឆ្នាំ | ៥,០% | ៥,០% |
| អត្រាបម្រែបម្រួលបុគ្គលិកក្នុងមួយឆ្នាំ | ០,៥% | ០,៥% |
| អត្រាមរណៈភាព | ១០០%នៃតារាងមរណភាពរបស់ប្រទេសថៃឆ្នាំ២០១៧ | ១០០%នៃតារាងមរណភាពរបស់ប្រទេសថៃឆ្នាំ២០១៧ |
| អត្រាពិការភាព | ១០%នៃអត្រាមរណៈសោធននិវត្តន៍មុនពេល | ១០%នៃអត្រាមរណៈសោធននិវត្តន៍មុនពេល |

## ១៦. សម្បទានពីរាជរដ្ឋាភិបាល

| | *២០២៣* |
|---|---|
| | *មិនបានធ្វើសវនកម្ម* |
| | *ពាន់រៀល* |
| នាថ្ងៃទី១ ខែមករា *(បានធ្វើសវនកម្ម)* | - |
| បានទទួលក្នុងគ្រា | ៥០.៨០២.១១២ |
| បានបញ្ចូលក្នុងប្រាក់ចំណេញ ឬ ខាត | (៤៧៥.៤៧៨) |
| **នាថ្ងៃទី៣១ ខែធ្នូ** | **៥០.៣២៦.៦៣៤** |
| រយៈពេលខ្លី | ៣.២១៤.៩៣០ |
| រយៈពេលវែង | ៤៧.១១១.៧០៤ |
| **នាថ្ងៃទី៣១ ខែធ្នូ** | **៥០.៣២៦.៦៣៤** |

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ ក.ស.ស បានទទួលសំណង់អគារនៃស្ថានីយដឹកទំនិញកុងតឺន័រជាមួយតម្លៃសំណង់ចំនួន ៥.១៥៦.៣៣៩ ពាន់រៀល (ស្មើនឹង ១.២៧១.៩១៤ ដុល្លារអាមេរិក) ពីរាជរដ្ឋាភិបាលជប៉ុន តាមរយៈរាជរដ្ឋាភិបាលកម្ពុជា ជាសម្បទានក្រោមគោលបំណងរួមចំណែកការអនុវត្តកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ ក.ស.ស បានទទួលស្គាល់សំណង់អគារនៃស្ថានីយដឹកទំនិញកុងតឺន័រ ជាអគារដែលស្ថិតក្រោមទ្រព្យ និងបរិក្ខារ និងសម្បទានពីរាជរដ្ឋាភិបាលពន្យារ ដែលពាក់ព័ន្ធតាមតម្លៃសំណង់។ រំលស់ស្ថានីយដឹកទំនិញកុងតឺន័រ និងចំណូលសម្បទានដែលពាក់ព័ន្ធ នឹងត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត នៃការប៉ាន់ស្មានអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មក្នុងរយៈពេល ៣០ឆ្នាំ។ មិនមានលក្ខខណ្ឌដែលមិនបានបំពេញ ឬ យថាភាព ភ្ជាប់ទៅនឹងសម្បទាននោះទេ។

នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ក.ស.ស បានទទួលបរិក្ខារកំពង់ផែសមុទ្រជារថលើកដាក់ចល័តនៅគែមផែចំនួន២ គ្រឿង ដែលមានតម្លៃ ៤៥.៦៤៥.៧៧៣ ពាន់រៀល (ស្មើនឹង ១១.០៧៩.០៧១ ដុល្លារអាមេរិក) ពីរាជរដ្ឋាភិបាលជប៉ុន តាមរយៈរាជរដ្ឋាភិបាលកម្ពុជា ដែលជាជំនួយឥតសំណងក្នុងគោលបំណងចូលរួមចំណែកក្នុងការអនុវត្តកម្មវិធី អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ក.ស.ស បានទទួលស្គាល់រថលើកដាក់ចល័តនៅគែមផែជាបរិក្ខារកំពង់ផែសមុទ្រដែលស្ថិតក្រោមទ្រព្យ និងបរិក្ខារ និងសម្បទានពីរាជរដ្ឋាភិបាលពន្យារ ដែលពាក់ព័ន្ធតាមតម្លៃឧបករណ៍។ រំលស់នៃរថលើកដាក់ចល័តនៅគែមផែ និងចំណូលសម្បទានដែលពាក់ព័ន្ធនឹងត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត នៃការប៉ាន់ស្មានអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មក្នុងរយៈពេល១៥ឆ្នាំ។ មិនមានលក្ខខណ្ឌដែលមិនបានបំពេញ ឬ យថាភាព ភ្ជាប់ទៅនឹងសម្បទាននោះទេ។

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ១៧. ចំណូលពីកិច្ចសន្យាជាមួយអតិថិជន

ការបែងចែកប្រាក់ចំណូលរបស់ ក.ស.ស ពីកិច្ចសន្យាជាមួយអតិថិជនមានដូចខាងក្រោម៖

| | *ការិយបរិច្ឆេទបីខែបញ្ចប់* | | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|---|
| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *បានធ្វើសវនកម្ម ពាន់រៀល* |
| ចំណូលលើកដាក់ពីនាវា | ៤៩.៤៨៩.៥៩២ | ៣៦.៨២៤.១៣២ | ១៧៧.៧៧៨.៨៩២ | ១៦៤.៨៧៣.៤៤៥ |
| ចំណូលលើកដាក់លើទីលាន (LO-LO) និងចំណូលពីការរក្សាទុកក្នុងតឺន័រ | ២៨.២៨២.៨២០ | ២៣.៧៦៧.០៦៧ | ១០៧.៤៥៥.០១៩ | ១១២.៤៣៧.១៧១ |
| ចំណូលពីសេវាកម្មផែ | ២០.៣០២.៤៧៩ | ១៥.៣២៩.១៦៥ | ៧៤.០៥៧.៧១៣ | ៦២.២៨៥.០៥០ |
| ផ្សេងៗ | ៨៩៦.៩៦៨ | ៤៦៩.១៧៩ | ២.៥៧៦.០៥៣ | ១.៧៧៣.១៨៣ |
| | **៩៨.៩៧១.៨៥៩** | **៧៦.៣៨៩.៥៤៣** | **៣៦១.៨៦៧.៦៧៧** | **៣៤១.៣៦៨.៨៤៩** |

ពេលវេលានៃការទទួលស្គាល់ចំណូល៖

| | *ការិយបរិច្ឆេទបីខែបញ្ចប់* | | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|---|
| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *បានធ្វើសវនកម្ម ពាន់រៀល* |
| ទទួលស្គាល់នៅពេលតែមួយ | ៩៤.២៥៧.៤៧១ | ៧២.៧២៩.៣៨២ | ៣៤៥.៨៦៤.៥៤៤ | ៣២៤.៤៦៦.៣២០ |
| ទទួលស្គាល់តាមដំណាក់កាល | ៤.៧១៤.៣៨៨ | ៣.៦៦០.១៦១ | ១៦.០០៣.១៣៣ | ១៦.៩០២.៥២៩ |
| | **៩៨.៩៧១.៨៥៩** | **៧៦.៣៨៩.៥៤៣** | **៣៦១.៨៦៧.៦៧៧** | **៣៤១.៣៦៨.៨៤៩** |

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ១៨. ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ

| | *ការិយបរិច្ឆេទបីខែបញ្ចប់* | | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|---|
| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *បានធ្វើសវនកម្ម ពាន់រៀល* |
| ប្រាក់បៀវត្សរ៍បុគ្គលិក | ១៩.៦០១.១៨០ | ១៥.៧០៦.៨២០ | ៧៣.៦៩៨.៩០០ | ៧០.៨៩០.៨៨៩ |
| ប្រាក់រង្វាន់ | ៦.២២៣.៤១៧ | ២.២៧៥.២២៨ | ២១.១៩៥.២៨២ | ១៦.៤២០.៤៣៧ |
| ចំណាយអត្ថប្រយោជន៍ | | | | |
| ប្រាក់សោធននិវត្តន៍ | ១.៦៥១.៧៨៣ | ១.៦៧៤.០៥១ | ៦.៦០៧.១៣១ | ៦.៦៩៦.២០៥ |
| ប្រាក់រំលឹកអតីតភាពការងារ | ១.១១៣.១៦០ | ៨៤៣.៦៨៨ | ៤.២៨៩.៣៤២ | ៤.០៣១.៧២៩ |
| ចំណាយសន្តិសុខសង្គម | ៤២០.៦៦៣ | ៤១៧.៦៨៨ | ១.៥០៦.៣៤៩ | ១.៥៤៦.៥៣១ |
| លាភការរបស់ក្រុមប្រឹក្សាភិបាល | ៣៤៩.២០០ | ៣៤៩.២០០ | ១.៣៩៦.៨០០ | ១.៥៤៦.៨០០ |
| ប្រាក់ឈ្នួលសម្រាប់អ្នកមៅការ | ៤២.៤១៥ | ៥៦.៩៦៥ | ១៨៣.៦៦០ | ១៩៦.៨១៥ |
| ផ្សេងៗ | ១.៦១៧.៧១៧ | ៩៣៨.១៦៦ | ៥.៤១៣.១៧០ | ៤.៣៤២.៦៩១ |
| | **៣១.០១៩.៥៣៥** | **២២.២៦១.៨០៦** | **១១៤.២៩០.៦៣៤** | **១០៥.៦៧២.០៩៧** |

## ១៩. សម្ភារៈផ្គត់ផ្គង់ការប្រើប្រាស់

| | *ការិយបរិច្ឆេទបីខែបញ្ចប់* | | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|---|
| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *បានធ្វើសវនកម្ម ពាន់រៀល* |
| ចំណាយលើសម្ភារៈងាយឆេះ | ១១.៦៧១.៩០៩ | ១២.១៣៩.១១៧ | ៤៣.៧១០.៦៨៤ | ៥៥.៣៧៧.២៩៥ |
| គ្រឿងបន្លាស់ | ៧.១៩៤.១៧៩ | ១១.១៣៦.៨៧៧ | ៤៩.៤២៥.៥៩២ | ៣៦.៥៨៥.២៧៨ |
| សម្ភារៈផ្គត់ផ្គង់ឃ្លាំង | ៥.៤៧៦.៨៩១ | ៦៩៦.០១១ | ១៤.០៥៣.៨៥៥ | ៦.៦៤៧.០៧៨ |
| សម្ភារៈផ្គត់ផ្គង់ការិយាល័យ | ១.៥៧៧.៦១១ | ៦០១.២៣៦ | ៤.៣៦០.៦៩៥ | ២.១៧៩.៦៧០ |
| ប្រេងរំអិល និងប្រេងម៉ាស៊ីន | ៨៤១.៦២៥ | ៧៩១.៨៣៨ | ៣.៣៥៥.៦៧៨ | ៣.៧២៦.៧៣៤ |
| ផ្សេងៗ | ៩០៥.៧៨២ | ៨២៥.៨៧១ | ២.៧០៣.៥៧១ | ១.៨៤៨.៨០៦ |
| | **២៧.៦១៧.៩៩៧** | **២៦.១៩០.៩៥០** | **១១២.៦១០.០៧៥** | **១០៦.៣៦៤.៨៦១** |

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២០. ចំណាយរំលស់ទ្រព្យសកម្មរូបិយ និងអរូបិយ

| | *ការិយបរិច្ឆេទបីខែបញ្ចប់* | | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|---|
| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *បានធ្វើសវនកម្ម ពាន់រៀល* |
| ទ្រព្យ និងបរិក្ខារ *(កំណត់សម្គាល់លេខ ៦)* | ១០.៦៤៨.២០១ | ៩.៨៥១.៩៧៧ | ៣៩.៩៣០.៨៧៥ | ៣៨.៣៥២.៥៧០ |
| ទ្រព្យវិនិយោគ *(កំណត់សម្គាល់លេខ ៧)* | ១.៦៩០.៦៦៥ | ១.៥៤៥.៧៦០ | ៦.៧៣៩.៧៩៩ | ៦.១៧៦.៦៣៩ |
| ទ្រព្យសកម្មអរូបិយ *(កំណត់សម្គាល់លេខ ៨)* | ២៩៥.២៧៦ | ២៩៥.២៧៦ | ១.១៨១.១០៤ | ១.១៦៨.៥៣៩ |
| | **១២.៦៣៤.១៤២** | **១១.៦៩៣.០១៣** | **៤៧.៨៥១.៧៧៨** | **៤៥.៦៩៧.៧៤៨** |

## ២១. (ចំណាយ)/ចំណូលហិរញ្ញវត្ថុ - សុទ្ធ

| | *ការិយបរិច្ឆេទបីខែបញ្ចប់* | | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|---|
| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *បានធ្វើសវនកម្ម ពាន់រៀល* |
| *ចំណូលហិរញ្ញវត្ថុ ៖* | | | | |
| ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ *(កំណត់សម្គាល់ ក)* | ២.១៥៧.៦០៩ | ១.២០២.៧០៧ | ៧.៩៨៥.២៩៧ | ៤.២៧៧.៤៨៩ |
| ចំណេញសុទ្ធពីការប្តូររូបិយវត្ថុរបស់ប្រាក់កម្ចី *(កំណត់សម្គាល់ ខ)* និងផ្សេងៗ | - | - | ១៤.៨០៩.៣២៩ | ៤៦.៥១៥.៩៧៥ |
| | **២.១៥៧.៦០៩** | **១.២០២.៧០៧** | **២២.៧៩៤.៦២៦** | **៥០.៧៩៣.៤៦៤** |
| *ចំណាយហិរញ្ញវត្ថុ៖* | | | | |
| ចំណាយការប្រាក់លើប្រាក់កម្ចីពី កសហវ *(កំណត់សម្គាល់ គ)* | (២.២៤៣.០២៤) | (២.៤៥៧.៦១៨) | (៨.៩៦០.១០៧) | (៩.៩៣៩.៧៩៣) |
| ចំណាយសុទ្ធពីការប្តូររូបិយវត្ថុរបស់ប្រាក់កម្ចី *(កំណត់សម្គាល់ ខ)* និងផ្សេងៗ | (១២.៦៥៥.៣៦៣) | (២១.៩៦២.៤៨៥) | - | - |
| | **(១៤.៨៩៨.៣៨៧)** | **(២៤.៤២០.១០៣)** | **(៨.៩៦០.១០៧)** | **(៩.៩៣៩.៧៩៣)** |
| **(ចំណាយ)/ចំណូលហិរញ្ញវត្ថុ - សុទ្ធ** | **(១២.៧៤០.៧៧៨)** | **(២៣.២១៧.៣៩៦)** | **១៣.៨៣៤.៥១៩** | **៤០.៨៥៣.៦៧១** |

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២១. (**ចំណាយ**)/**ចំណូលហិរញ្ញវត្ថុ - សុទ្ធ** (តពីទំព័រមុន)

(ក) ចំណូលការប្រាក់គឺជាចំណូលពីគណនីប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើមានកាលកំណត់នៅក្នុងធនាគារក្នុងស្រុក ក្នុងការិយបរិច្ឆេទ។

(ខ) ក.ស.ស មានប្រាក់កម្ចី *(កំណត់សម្គាល់លេខ ១៤)* ជាប្រាក់យ៉េនជប៉ុន និងជាប្រាក់ដុល្លារអាមេរិក។ ដោយសារតែការឡើងចុះនៃតម្លៃ ប្រាក់រៀល ធៀបនឹងប្រាក់យ៉េនជប៉ុន បណ្តាលឲ្យមានការចំណេញជាសារវន្តលើការប្តូររូបិយប័ណ្ណលើប្រាក់កម្ចីរបស់ ក.ស.ស។ អត្រាប្តូររូបិយប័ណ្ណ គឺយោងទៅលើអត្រាប្តូររូបិយប័ណ្ណដែលបានបោះផ្សាយដោយធនាគារជាតិនៃកម្ពុជា នាចុងការិយបរិច្ឆេទនៃការរាយការណ៍។

| | *ថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២២* |
|---|---|---|
| ប្រាក់យ៉េន/ប្រាក់រៀល | ២៩,១៣៥ | ៣០,៩៤៥ |
| ប្រាក់ដុល្លារអាមេរិក/ប្រាក់រៀល | ៤.០៨៥ | ៤.១១៧ |

(គ) ចំណាយការប្រាក់ គឺជាការប្រាក់លើប្រាក់កម្ចីដែលទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈការធ្វើហិរញ្ញប្បទានដោយ JICA និង JBIC *(កំណត់សម្គាល់លេខ ១៤ និង ២៦)*។

## ២២. ពន្ធលើប្រាក់ចំណូល

ពន្ធត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយបទប្បញ្ញត្តិពន្ធដារនាពេលបច្ចុប្បន្ន ដែលត្រូវបានអនុម័តនាកាលបរិច្ឆេទរាយការណ៍។ គណៈគ្រប់គ្រងវាយតម្លៃអំពីស្ថានភាពដែលបានប្រកាសពន្ធជាមួយនឹងស្ថានភាពនៃបទប្បញ្ញត្តិពន្ធដារដែលជាកម្មវត្ថុនៃការបកស្រាយ។ ក.ស.ស កត់ត្រាសំវិធានធនទៅតាមភាពសមស្រប អាស្រ័យទៅតាមមូលដ្ឋាននៃចំនួនប្រាក់ពន្ធ ដែលក.ស.ស រំពឹងថាត្រូវបង់ជូនអាជ្ញាធរពន្ធដារ។

ទោះជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិពន្ធទាំងនេះមានការប្រែប្រួលពីមួយគ្រាទៅមួយគ្រា ហើយការកំណត់ចុងក្រោយលើចំនួនបំណុលពន្ធ នឹងធ្វើឡើងបន្ទាប់ពីមានការពិនិត្យរបស់អាជ្ញាធរពន្ធដារ។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយមានភាពខុសគ្នាពីការកត់ត្រាដំបូង ភាពខុសគ្នានេះនឹងធ្វើឲ្យប៉ះពាល់ដល់ចំនួនបំណុលពន្ធ និងសមតុល្យទឹកប្រាក់ ក្នុងការិយបរិច្ឆេទដែលការកំណត់ពន្ធនោះត្រូវបានធ្វើឡើង។

ក.ស.ស គណនាចំណាយពន្ធលើប្រាក់ចំណូលសម្រាប់ការិយបរិច្ឆេទ ដោយប្រើប្រាស់អត្រាពន្ធដែលនឹងអាចអនុវត្តបាន តាមចំណូលសរុបប្រចាំឆ្នាំដែលបានរំពឹងទុក។

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២២. ចំណាយពន្ធលើប្រាក់ចំណូល (តពីទំព័រមុន)

ធាតុសំខាន់ៗនៃចំណាយពន្ធលើប្រាក់ចំណូល នៅក្នុងរបាយការណ៍ប្រាក់ចំណេញពេញលេញសង្ខេបចន្លោះពេលដែលមិនបានធ្វើសវនកម្មមានដូចជា៖

| | *ការិយបរិច្ឆេទបីខែបញ្ចប់* | | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|---|
| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *បានធ្វើសវនកម្ម ពាន់រៀល* |
| ចំណាយពន្ធលើប្រាក់ចំណូលដែលទទួលស្គាល់ក្នុងប្រាក់ចំណេញក្នុងគ្រា | | | | |
| ពន្ធលើប្រាក់ចំណូល | ៨៥៦.៦៨៧ | ៨០៧.០៣០ | ២៤.៤១៩.៦១៥ | ១១.៩៩២.៦៣៤ |
| កង្វះសំវិធានធនពន្ធលើប្រាក់ចំណូលពីឆ្នាំមុន | - | - | - | ១.៦២៩.៦០០ |
| ពន្ធពន្យារ | ៩.០៩១.៨៤៩ | ១.១៥៩.៤៩១ | ៨.០០៧.៤៣៩ | ៦១៩.៦៣១ |
| | **៩.៩៤៨.៥៣៦** | **១.៩៦៦.៥២១** | **៣២.៤២៧.០៥៤** | **១៣.៧៤១.៨៦៥** |
| ចំណាយពន្ធលើប្រាក់ចំណូលដែលទទួលស្គាល់ក្នុងលទ្ធផលពេញលេញផ្សេងៗ | | | | |
| ពន្ធពន្យារទាក់ទងនឹងការវាស់វែងឡើងវិញលើការកំណត់កាតព្វកិច្ចអត្ថប្រយោជន៍ | - | - | - | ២.៩៦៤.៧០៩ |

## ២៣. ចំណេញក្នុងមួយភាគហ៊ុន

### *(i) មូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន* (Basic earnings per share)

មូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន ត្រូវបានគណនាដោយយកប្រាក់ចំណេញរបស់ម្ចាស់ភាគហ៊ុនរបស់ ក.ស.ស ចែកនឹងចំនួនជាមធ្យមនៃភាគហ៊ុនធម្មតា មានបោះផ្សាយក្នុងការិយបរិច្ឆេទ។

| | *ការិយបរិច្ឆេទបីខែបញ្ចប់* | | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|---|
| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *បានធ្វើសវនកម្ម ពាន់រៀល* |
| ចំណេញ/(ខាត) របស់ភាគហ៊ុនិក | ៤.០៣២.២២០ | (១៤.០០៥.០៨១) | ១២១.៩៦៥.៤៩០ | ៨៤.១៥៥.២១៥ |
| ចំនួនជាមធ្យមនៃភាគហ៊ុន | ៨៥.៧៧១.៩៦៧ | ៨៥.៧៧១.៩៦៧ | ៨៥.៧៧១.៩៦៧ | ៨៥.៧៧១.៩៦៧ |
| **មូលដ្ឋានចំណេញ/(ខាត) ក្នុងមួយភាគហ៊ុន** *(រៀល)* | **៤៧,០១** | **(១៦៣,២៨)** | **១.៤២១,៩៧** | **៩៨១,១៥** |

## ២៣. **ចំណេញក្នុងមួយភាគហ៊ុន** (តពីទំព័រមុន)

*(ii) ចំណេញក្នុងមួយភាគហ៊ុនដែលត្រូវបានបន្ថយ* ( Diluted earnings per share )

ចំណេញក្នុងមួយភាគហ៊ុនដែលត្រូវបានបន្ថយ ត្រូវបានគណនាដោយកែប្រែចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមាន ដោយសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។ ក.ស.ស មិនមានភាគហ៊ុនដែលមានសក្តានុពលអាចផ្ទេរទៅជាភាគហ៊ុនធម្មតានោះទេ នាចុងការិយបរិច្ឆេទនេះ។ ដូចនេះ ចំណេញក្នុងមួយភាគហ៊ុនដែលត្រូវបានបន្ថយ គឺមានតម្លៃស្មើនឹងមូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន។

## ២៤. **ភាគលាភ**

នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ និងថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាលបានអនុម័តចែកភាគលាភ ទាក់ទងនឹងប្រាក់ចំណេញនៃឆ្នាំសារពើពន្ធ សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ (រៀងគ្នា) ដូចខាងក្រោម៖

| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
|---|---|---|
| | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* |
| ភាគហ៊ុនប្រភេទ "ខ" | ៣.៩៨៦.៤៤២ | ៥.៣០០.០០០ |
| ភាគហ៊ុនប្រភេទ "គ" | ៩.៧៣៥.១១៨ | ១០.៨០៧.២៦៨ |
| | **១៣.៧២១.៥៦០** | **១៦.១០៧.២៦៨** |

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ភាគលាភដែលបានប្រកាស សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ត្រូវបានបង់រួចពេញលេញ។

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២៥. សាច់ប្រាក់បានពីប្រតិបត្តិការ

| | *កំណត់សម្គាល់* | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|
| | | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | | *ពាន់រៀល* | *ពាន់រៀល* |
| ចំណេញមុនគិតពន្ធលើប្រាក់ចំណូល | | ១៥៤.៣៩២.៥៤៤ | ៩៧.៨៩៧.០៨០ |
| និយ័តកម្មលើ៖ | | | |
| ចំណូលហិរញ្ញវត្ថុ - សុទ្ធ | ២១ | (១៣.៨៣៤.៥១៩) | (៤០.៨៥៣.៦៧១) |
| រំលស់ទ្រព្យសកម្មរូបិយ និងអរូបិយ | ២០ | ៤៧.៨៥១.៧៧៨ | ៤៥.៦៩៧.៧៤៨ |
| ខាតពីការលុបចោលទ្រព្យ និងបរិក្ខារ | ៦ | ១.៣៤៦ | - |
| ចំណេញពីការលក់ទ្រព្យសកម្មចាត់ថ្នាក់ជាទ្រព្យសម្រាប់លក់ | ១១ | (៨៤.៨១៥.៩៩៧) | - |
| កាតព្វកិច្ចលើប្រាក់បំណាច់អតីតភាពការងារ | | ៤.២៨៩.៣៩២ | ៤.០៣១.៧២៩ |
| កាតព្វកិច្ចអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ | ១៨ | ៦.៦០៧.១៣១ | ៦.៦៩៦.២០៥ |
| ចំណូលសម្បទានពីរាជរដ្ឋាភិបាល | ១៦ | (៤៧៥.៤៧៨) | - |
| ការកត់ត្រាបញ្ច្រាស់លើសន្និធិដែលមានចលនាយឺត | | - | (៦៤៧.៥៩០) |
| សំវិធានធនលើការខាតឥណទានរំពឹងទុកលើប្រាក់បញ្ញើនៅធនាគារមានរយៈពេលខ្លី | | ៧.៥៥៩ | ១៩.១១៨ |
| ការកត់ត្រាបញ្ច្រាស់សម្រាប់អ៊ីមភែរមិនលើគណនីអតិថិជន | | (៨៧.០៥២) | (៩៦.២៩១) |
| បម្រែបម្រួលដើមទុនបង្វិល៖ | | | |
| សន្និធិ | | (៥.៣៨០.៩៦៧) | (១.២១០.៧៦៨) |
| គណនីអតិថិជន និងគណនីត្រូវសងផ្សេងៗ | | (១២.៨៨៣.១៥៧) | (១.៩០២.៧៩៨) |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | | (៤.៨៧២.៥៤៥) | (១៨.០៤៥.៤០៥) |
| ចំណូលពន្យារ | | ២.១៤២.៣៩៥ | ៦.៩២៩.៩៧៨ |
| សាច់ប្រាក់បានពីប្រតិបត្តិការ | | **៩២.៩៤២.៣៨០** | **៩៨.៥១៥.៣៣៥** |

## ២៦. ប្រតិបត្តិការភាគីពាក់ព័ន្ធ

ក.ស.ស ស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ("កសហវ") និងស្ថិតនៅក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេស ដោយក្រសួងសាធារណការ និងដឹកជញ្ជូន។ ប្រតិបត្តិការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបានចាត់ទុកថាជាប្រតិបត្តិការភាគីពាក់ព័ន្ធ។

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២៦. ប្រតិបត្តិការភាគីពាក់ព័ន្ធ (តពីទំព័រមុន)

### *(ក) សមតុល្យភាគីពាក់ព័ន្ធ*

(i) ទឹកប្រាក់ជំពាក់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
|---|---|---|
| | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* |
| ប្រាក់កម្ចីពី៖ | | |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JICA) *(កំណត់សម្គាល់លេខ ១៨)* | ១៥០.៨០៣.៨០៩ | ១៦៣.២៨០.៧៩៧ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - (JBIC) *(កំណត់សម្គាល់លេខ ១៨)* | ២០៦.១៨៧.៩០១ | ២៣១.៨២៩.៧៨០ |
| | **៣៥៦.៩៩១.៧១០** | **៣៩៥.១១០.៥៧៧** |

(ii) ទឹកប្រាក់ត្រូវទទួលពីក្រសួងសាធារណការ និងដឹកជញ្ជូន

| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
|---|---|---|
| | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* |
| បុរេប្រទានទៅឲ្យក្រសួងសាធារណការ និងដឹកជញ្ជូន *(កំណត់សម្គាល់លេខ ១០)* | **១.២២១.៣០៣** | **៧.២២១.៣០៣** |

### *(ខ) ប្រតិបត្តិការភាគីពាក់ព័ន្ធ*

| | *ការិយបរិច្ឆេទបីខែបញ្ចប់* | | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|---|
| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | *មិនបានធ្វើសវនកម្ម* | *មិនបានធ្វើសវនកម្ម* | *មិនបានធ្វើសវនកម្ម* | *បានធ្វើសវនកម្ម* |
| | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* | *ពាន់រៀល* |
| ថ្លៃដើមនៃកម្ចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | | | |
| ចំណាយការប្រាក់ *(កំណត់សម្គាល់លេខ ២១)* | ២.២៥៣.០២៤ | ២.៤៥៧.៦១៨ | ៨.៩៦០.១០៧ | ៩.៩៣៩.៧៩៣ |
| ថ្លៃដើមការប្រាក់ *(កំណត់សម្គាល់លេខ ៦)* | ៧៣.០០៦ | ៥៩.៥៨៩ | ២១៨.២៨១ | ១៨៨.១៨៩ |
| បុរេប្រទាន ទៅក្រសួងសាធារណការ និងដឹកជញ្ជូន *(កំណត់សម្គាល់លេខ ១០)* | - | - | - | ៦.០០០.០០០ |
| បុរេប្រទានទូទាត់បានមកពីក្រសួងសាធារណការ និងដឹកជញ្ជូន *(កំណត់សម្គាល់លេខ ១០)* | - | - | (៦.០០០.០០០) | - |

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២៦. ប្រតិបត្តិការភាគីពាក់ព័ន្ធ (តពីទំព័រមុន)

### *(គ) ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ*

ចំណាយលើគណៈគ្រប់គ្រងសំខាន់ៗ សម្រាប់ដំណាច់ការិយបរិច្ឆេទបីខែ និងដប់ពីរខែបញ្ចប់ មានដូចខាងក្រោម៖

| | *ការិយបរិច្ឆេទបីខែបញ្ចប់* | | *ការិយបរិច្ឆេទដប់ពីរខែបញ្ចប់* | |
|---|---|---|---|---|
| | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣* | *ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២* |
| | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *មិនបានធ្វើសវនកម្ម ពាន់រៀល* | *បានធ្វើសវនកម្ម ពាន់រៀល* |
| ក្រុមប្រឹក្សាភិបាល | | | | |
| កម្រៃ និងចំណាយពាក់ព័ន្ធផ្សេងៗ | ៣៤៩.២០០ | ៣៤៩.២០០ | ១.៣៩៦.៨០០ | ១.៣៩៦.៨០០ |
| គណៈគ្រប់គ្រងសំខាន់ៗ | | | | |
| ប្រាក់បៀវត្សរ៍ និងចំណាយផ្សេងៗ | ៧៨១.៨៨៨ | ៥៩៨.៣៩១ | ៣.៣៧៧.៣៩៧ | ៣.២៦៨.១៩៧ |
| ចំណាយអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ (*) | ៨៩.៦៣៧ | ៦៨.៤៥១ | ២៦៥.១៩៦ | ២៣៥.៣៦៦ |

គណៈគ្រប់គ្រងសំខាន់ៗ រួមមានអគ្គនាយក និងនាយកប្រតិបត្តិដែលជាអ្នកសម្រេចចិត្តជាយុទ្ធសាស្ត្រ លើការដឹកនាំ លើផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ ក.ស.ស។

(*) គម្រោងអត្ថប្រយោជន៍ប្រាក់សោធននិវត្តន៍ ត្រូវបានផ្តល់ជូនបុគ្គលិក ក.ស.ស ព្រមទាំងបុគ្គលិកគ្រប់គ្រងសំខាន់ៗដទៃទៀតផងដែរ។

## ២៧. ការសន្យា

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ក.ស.ស មានសមតុល្យកិច្ចសន្យាចំណាយមូលធនទៅក្រុមហ៊ុន តូអា ខបភើរេសិន និងក្រុមហ៊ុន Mitsui E&S Machinery Co., Ltd ចំនួន ៣៣.៥២៨.៦៤៤ ពាន់រៀល និង ២៥.៧៨០.៨៤៤ ពាន់រៀល (រៀងគ្នា) សម្រាប់ការទិញសេវាកម្មសំណង់ ទ្រព្យ និងបរិក្ខាររបស់ក្រុមហ៊ុន (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២៖ គ្មាន)។

## ២៨. ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទរបាយការណ៍

ក្រៅពីអ្វីដែលបានបង្ហាញខាងលើ មិនមានព្រឹត្តិការណ៍គួរឲ្យកត់សម្គាល់ណាមួយកើតឡើងបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ដែលតម្រូវឲ្យមានការកែតម្រូវ ឬ បង្ហាញនៅក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនោះទេ។

# ផ្នែកទី ៤

# ការពិភាក្សា និងការវិភាគ
# របស់គណៈគ្រប់គ្រង

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

កសស គឺជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់ នៃព្រះរាជាណាចក្រកម្ពុជាដែលកំពុងធ្វើអាជីវកម្ម លើផ្ទៃដីទំហំប្រមាណ ១២៥ ហិកតា ដែលមានទីតាំងនៅសង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ហើយត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះ។ កំណត់ក្នុង អនុក្រឹត្យលេខ ៥០ អនក្រ/បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ១៩៩៨ កសស មានតួនាទីជាប្រតិបត្តិករផែ ដូចមានលម្អិតនូវអាជីវកម្ម និងសេវាកម្មក្នុងផ្នែកទី១ ចំណុច-ខ ខាងលើនៃរបាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣ នេះ ។

សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ បរិមាណកុងតែន័ររបស់ កសស មានការកើនឡើងចំនួន ៥០.៨១១ TEUs ស្មើនឹង ៣១,៩៤% បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២២។ បរិមាណទំនិញឆ្លងកាត់គិតជាតោនក៏មានការកើនឡើង ៣០,០១% ស្មើនឹង ៤៧៨.៧៨៨ តោន ដែលក្នុងនោះទំនិញជាកុងតែន័រគិតជាតោនកើនឡើង ៣៤,៦៨% ស្មើនឹង ៣៩៧.៣៤៤ តោន និងទំនិញរាយកើន ៧៤.៤២៧ តោន ស្មើនឹង ៣០២,០៦%។ ចំណែកសម្រាប់បរិមាណប្រេងកើនឡើងចំនួន ៧.១៣២ តោន ស្មើនឹង ១,៨១% ហើយហ្គាសមានការថយចុះ ១១៥ តោន ស្មើនឹង ០,៣៧%។ ចំពោះនាវាឆ្លងកាត់ កសស សរុបមានការកើនឡើងចំនួន ៣៦ នាវា ប្រមាណជា ១០,៥៩% ហើយចំណុះផ្ទុកនាវាសរុបកើនឡើងប្រមាណ ៥០,៧១% ស្មើនឹង ១.៧៣២.៩២១ តោន សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២២ ។

ការពិភាក្សា និងការវិភាគរបស់ថ្នាក់ដឹកនាំលើស្ថានភាពហិរញ្ញវត្ថុរបស់ កសស និងលទ្ធផលប្រតិបត្តិការខាងក្រោមនេះ ធ្វើឡើងផ្អែកលើរបាយការណ៍ព័ត៌មានហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួចរាល់ដោយសវនករឯករាជ្យសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ និងត្រីមាសទី៤ ឆ្នាំ២០២២ ដូចបង្ហាញក្នុងផ្នែកទី៤ នៃរបាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣ នេះ ។

កសស មានប្រភពចំណូលសំខាន់ដូចខាងក្រោម ៖

- ចំណូលពីសេវាកម្មនាវាចរ (Port Charges for Vessel Services)៖ គឺជាចំណូលដែលបានមកពីសេវាកម្មនាវាចរណ៍ និងការចូលចតនាវា រួមមាន ចំណូលលើចំណុះផ្ទុក សំចតផែ ប្រឡាយ ថ្លៃឈ្នួលកណ្តាជារកិច្ច ថ្លៃឈ្នួលនាវាសណ្តោង ថ្លៃឈ្នួលពាក់-ដោះពួរ ថ្លៃឈ្នួលបើក-បិទឃ្លប់នាវា និងថ្លៃឈ្នួលប្រមូលសំរាម ។
- ចំណូលពីសេវាកម្មលើកដាក់កុងតែន័រ ពីនាវាទៅទីលានកុងតែន័រ (Stevedoring Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញរាយ ឬកុងតែន័រ ចូល-ចេញពីនាវានៅលើស្ពានផែ ។
- ចំណូលពីសេវាកម្មលើកដាក់កុងតែន័រនៅលើទីលាន (LOLO Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញរាយ ឬកុងតែន័រ ចូល-ចេញនៅលើទីលាន ។
- ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ ឬកុងតែន័រ (Storage Fees)៖ គឺជាចំណូលដែលបានមកពីការស្តុកទំនិញរាយ ឬកុងតែន័រនៅក្នុងឃ្លាំង និងលើទីលាន ។
- ចំណូលដឹកជញ្ជូន (Transportation Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មដឹកជញ្ជូនទំនិញ ឬកុងតែន័រក្នុងបរិវេណផែ ។
- ចំណូលពីតំបន់សេដ្ឋកិច្ចពិសេស (Special Economic Zone)៖ គឺជាចំណូលដែលទទួលបានពីការជួលដីធ្វើរោងចក្រ អគារ ពីតំបន់សេដ្ឋកិច្ចពិសេសរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ។

កសស កត់ត្រាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុជាប្រាក់រៀល ដែលជារូបិយប័ណ្ណជាតិរបស់ខ្លួន ចំណែកប្រតិបត្តិការដែលជារូបិយប័ណ្ណអន្តរជាតិផ្សេងៗ ត្រូវបានបង្ហាញជាប្រាក់រៀល ដោយប្រើអត្រាប្តូរផ្លូវការជាមធ្យមប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា តាមកាលបរិច្ឆេទនៃប្រតិបត្តិការនីមួយៗ ។

## ១. ការវិភាគចំណូល

### សម្រាប់ដំណាច់ការិយបរិច្ឆេទត្រីមាសទី៤ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ប្រៀបធៀបនឹងការិយបរិច្ឆេទត្រីមាសទី៤ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| បរិយាយ | ការិយបរិច្ឆេទបញ្ចប់ត្រឹម ត្រីមាសទី៤ ឆ្នាំ២០២៣ | ការិយបរិច្ឆេទបញ្ចប់ត្រឹម ត្រីមាសទី៤ ឆ្នាំ២០២២ | បំរែបំរួល | |
|---|---|---|---|---|
| | | | ពាន់រៀល | % |
| ចំណូល (ពាន់រៀល) | ១០០.០៧២.៧៨០ | ៧៧.០១២.៨៣៨ | ២៣.០៥៩.៩៤២ | ២៩,៩៤% |

សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ ចំណូលរបស់ កសស មានការកើនឡើងចំនួន ២៣.០៥៩.៩៤២.០០០ រៀល ស្មើនឹង ២៩,៩៤% ដោយកើនឡើងពី ៧៧.០១២.៨៣៨.០០០ រៀល សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២២ ដល់ ១០០.០៧២.៧៨០.០០០ រៀល សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣។ ការកើននៃចំណូលសរុបនេះមកពីការកើននៃចំណូលសេវាកម្មលើកដាក់កុងតែន័រពីនាវាទៅទីលាន (Stevedoring Charges) ចំណូលលើកដាក់លើទីលាន (LOLO) ចំណូលពីសេវាកម្មនាវាចរ និងចំណូលស្តុក ឃ្លាំង និងទីលាន។

## ១.១. ការវិភាគចំណូលតាមផ្នែក

### តារាងប្រៀបធៀបប្រាក់ចំណូលតាមផ្នែកទៅនឹងប្រាក់ចំណូលសរុប សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ និងត្រីមាសទី៤ ឆ្នាំ២០២២

| បរិយាយ | ការិយបរិច្ឆេទបញ្ចប់ត្រឹម ត្រីមាសទី៤ ឆ្នាំ២០២៣ | | ការិយបរិច្ឆេទបញ្ចប់ត្រឹម ត្រីមាសទី៤ ឆ្នាំ២០២២ | |
|---|---|---|---|---|
| | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) | ៤៩.៤៨៩.៥៩២ | ៤៩,៤៥% | ៣៦.៨២៤.១៣២ | ៤៧,៨២% |
| ចំណូលលើកដាក់លើទីលាន (LOLO) | ២៤.២៦៥.៧៩៣ | ២៤,២៥% | ២០.៤៨៤.៩៤៥ | ២៦,៦០% |
| ចំណូលពីសេវាកម្មនាវាចរ | ២០.៣០២.៤៧៩ | ២០,២៩% | ១៥.៣២៩.១៦៥ | ១៩,៩០% |
| ចំណូលស្តុក ឃ្លាំង និងទីលាន | ៤.០១៧.០២៧ | ៤,០១% | ៣.២៨២.១២២ | ៤,២៦% |
| ចំណូលដឹកជញ្ជូន | ២៧.៩៥៧ | ០,០៣% | ៧.៥៦៦ | ០,០១% |
| ចំណូលនាវាទេសចរណ៍ | ១០១.២៧៩ | ០,១០% | ០ | ០,០០% |
| ចំណូលពីតំបន់ សេដ្ឋកិច្ចពិសេស | ៧១១.៣៨២ | ០,៧១% | ៦២៣.២៩៥ | ០,៨១% |
| ចំណូលជួលទីតាំង | ៦៩៧.៣៦២ | ០,៧០% | ៣៧៨.០៣៨ | ០,៤៩% |
| ចំណូលផ្សេងៗទៀត | ៤៥៩.៩១០ | ០,៤៦% | ៨៣.៥៧៥ | ០,១១% |
| **ចំណូលសរុប** | **១០០.០៧២.៧៨០** | **១០០,០០%** | **៧៧.០១២.៨៣៨** | **១០០,០០%** |

សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ ក៏ដូចជាត្រីមាសទី៤ ឆ្នាំ២០២២ មានចំណូលសំខាន់ ៤ ប្រភេទដែលមានចំនួនប្រមាណ ៩៨% នៃចំណូលអាជីវកម្ម និងសេវាកម្មសរុបរបស់ កសស។ ចំណូលទាំងនោះរួមមានៈ ចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) ចំណូលលើកដាក់លើទីលាន (LOLO) ចំណូលពីសេវាកម្មនាវាចរ (Port Charges for Vessel Services) និងចំណូលស្តុកឃ្លាំង និងទីលាន ។

**សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ធៀបនឹងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២**

| បរិយាយ | ការិយបរិច្ឆេទបញ្ចប់ត្រឹមត្រីមាសទី៤ ឆ្នាំ២០២៣ | ការិយបរិច្ឆេទបញ្ចប់ត្រឹមត្រីមាសទី៤ ឆ្នាំ២០២២ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) | ៤៩.៤៨៩.៥៩២ | ៣៦.៨២៤.១៣២ | ១២.៦៦៥.៤៦០ | ៣៤,៣៩% |
| ចំណូលលើកដាក់លើទីលាន (LOLO) | ២៤.២៦៥.៧៩៣ | ២០.៤៨៤.៩៤៥ | ៣.៧៨០.៨៤៨ | ១៨,៤៦% |
| ចំណូលពីសេវាកម្មនាវាចរ | ២០.៣០២.៤៧៩ | ១៥.៣២៩.១៦៥ | ៤.៩៧៣.៣១៤ | ៣២,៤៤% |
| ចំណូលស្តុក ឃ្លាំង និងទីលាន | ៤.០១៧.០២៧ | ៣.២៨២.១២២ | ៧៣៤.៩០៥ | ២២,៣៩% |

ចំណូលពីការលើកដាក់ពីនាវាទៅទីលាន (Stevedoring) មានការកើនឡើងចំនួន ១២.៦៦៥.៤៦០.០០០ រៀល ស្មើនឹង ៣៤,៣៩% សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២២ និងចំណូលពីការលើកដាក់នៅលើទីលាន (LOLO) មានការកើនឡើង ១៨,៤៦% ស្មើនឹង ៣.៧៨០.៨៤៨.០០០ រៀល បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២។ ការកើនឡើងលើចំណូលលើកដាក់ពីនាវាទៅទីលាន គឺបណ្តាលមកពីការការកើនឡើងនៃបរិមាណកុងតែន័រឆ្លងកាត់ កសស មានចំនួន ៥០.៨១១ TEUs ស្មើនឹង ៣១,៩៤% និងបរិមាណទំនិញលើករៀបកើនឡើង ១.៩០៨.៤០៣ តោន ស្មើនឹង ៧៤,៧៧% សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ នេះ ។

ចំពោះចំណូលសេវាកម្មនាវាចរ (Port Charges for Vessel Services) គឺអាស្រ័យលើចំនួននាវា និងចំណុះផ្ទុកនាវាដែលឆ្លងកាត់ កសស ហើយសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ នេះ នាវាសរុបដែលឆ្លងកាត់ កសស មានការកើនឡើង ៣៦ នាវា ស្មើនឹង ១០,៥៩% ហើយចំណុះផ្ទុកនាវាសរុបមានការកើនឡើង ៥០,៧១% ស្មើនឹង ១.៧៣២.៩២១ តោន ហើយយើងសង្កេតឃើញថា ចំណូលពីសេវាកម្មនាវាចរ មានការកើនឡើងពី ១៥.៣២៩.១៦៥.០០០ រៀល សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២២ មក ២០.៣០២.៤៧៩.០០០ រៀល សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ ពោលគឺកើនប្រមាណ ៣២,៤៤% ស្មើនឹង ៤.៩៧៣.៣១៤.០០០ រៀល។ ដោយនៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ នេះ នាវាដឹកកុងតែន័រមានការកើនឡើង ២០,៤៧% ស្មើនឹង ៣៥ នាវា បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២ ។

ចំណូលពីសេវាកម្មស្តុកឃ្លាំង និងទីលានមានការកើនឡើងចំនួន ៧៣៤.៩០៥.០០០ រៀល ស្មើនឹង ២២,៣៩% បើប្រៀបធៀបចំណូលត្រីមាសទី៤ ឆ្នាំ២០២៣ មានចំណូល ៤.០១៧.០២៧.០០០ រៀល និងត្រីមាសទី៤ ឆ្នាំ២០២២ មានចំណូល ៣.២៨២.១២២.០០០ រៀល។ ការកើនឡើងនេះបណ្តាលមកពីបរិមាណទំនិញឆ្លងកាត់ និងកុងតែន័រមានការកើនក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំ២០២២។

## ២- ការវិភាគគំលាតចំណេញដុល

កសស បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួន ក្នុងទម្រង់ជារបាយការណ៍លទ្ធផលតាមយថាប្រភេទ ដូចនេះពុំមានការបង្ហាញឱ្យឃើញនៅចំណេញដុលនោះទេ។ ប៉ុន្តែក្នុងទម្រង់របាយការណ៍នេះអាចឱ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញប្រតិបត្តិការបានដោយទទួលបានពីចំណូលសរុប ដកនឹងចំណាយប្រតិបត្តិការ។

ចំណាយប្រតិបត្តិការនឹងលើកមកពិភាក្សា និងវិភាគនៅផ្នែកខាងក្រោមគឺ ចំណុច គ-ការវិភាគចំណេញមុនបង់ពន្ធ ។

## ៣- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

ចំណេញ/(ខាត) មុនបង់ពន្ធគឺជាលទ្ធផលដែលទទួលបានពីចំណូលសរុប ដកនឹងចំណាយប្រតិបត្តិ និងចំណូល ឬចំណាយហិរញ្ញវត្ថុ-សុទ្ធ។ ក្នុងការវិភាគនៃចំណាយប្រតិបត្តិការ យើងនឹងលើកយកចំណាយសម្ភារៈផ្គត់ផ្គង់ ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ ចំណាយរំលស់ (ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី) ចំណាយជួសជុល និងថែទាំ ចំណាយផ្សេងៗ ខាតផ្សេងៗ-សុទ្ធ និងចំណាយហិរញ្ញវត្ថុ-សុទ្ធ ដូចខាងក្រោម៖

**សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ធៀបនឹងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២**

| បរិយាយ | ការិយបរិច្ឆេទបញ្ចប់ ត្រឹមត្រីមាសទី៤ ឆ្នាំ២០២៣ | ការិយបរិច្ឆេទបញ្ចប់ ត្រឹមត្រីមាសទី៤ ឆ្នាំ២០២២ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| **ចំណូលសរុប** | **១០០.០៧២.៧៨០** | **៧៧.០១២.៨៣៨** | **២៣.០៥៩.៩៤២** | **២៩,៩៤%** |
| ចំណាយសម្ភារៈផ្គត់ផ្គង់ | (២៧.៦១៧.៩៩៧) | (២៦.១៤០.៩៥០) | ១.៤៧៧.០៤៧ | ៥,៦៥% |
| ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | (៣១.០១៩.៥៣៥) | (២២.២៦១.៨០៦) | ៨.៧៥៧.៧២៩ | ៣៩,៣៤% |
| ចំណាយរំលស់(ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី) | (១២.៦៣៤.១៤២) | (១១.៦៩៣.០១៣) | ៩៤១.១២៩ | ៨,០៥% |
| ចំណាយជួសជុល និងថែទាំ | (៥១៩.១១៤) | (១.០៥១.៩៧២) | (៥៣២.៨៥៨) | -៥០,៦៥% |
| ចំណាយផ្សេងៗ | (៤.៦៩៦.០៤០) | (៤.២៧៥.៤៧៤) | ៤២០.៥៦៦ | ៩,៨៤% |
| ខាតផ្សេងៗ-សុទ្ធ | (១.៨៦៤.៤១៨) | (៤១០.៧៨៧) | ១.៤៥៣.៦៣១ | ៣៥៣,៨៦% |
| ចំណាយហិរញ្ញវត្ថុ-សុទ្ធ | (១២.៧៤០.៧៧៨) | (២៣.២១៧.៣៩៦) | (១០.៤៧៦.៦១៨) | -៤៥,១២% |
| **ចំណេញ/(ខាត) មុនបង់ពន្ធ** | **៨.៩៨០.៧៥៦** | **(១២.០៣៨.៥៦០)** | **២១.០១៩.៣១៦** | **១៧៤,៦០%** |

សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ កសស មានចំណាយសម្ភារៈផ្គត់ផ្គង់សរុប ២៧.៦១៧.៩៩៧.០០០ រៀល ដែលមានការឡើងចំនួន ១.៤៧៧.០៤៧.០០០ រៀល ស្មើនឹង ៥,៦៥% បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២២ ដែលមានចំណាយ ២៦.១៤០.៩៥០.០០០ រៀល។ កត្តាចម្បងដែលបណ្តាលឱ្យមានការកើនឡើងនេះគឺដោយសារចំណាយលើសម្ភារៈឃ្លាំង មានការកើនឡើង ៧៤៧,៨០% ស្មើនឹង ៤.៨៣០.៨៨០.០០០ រៀល និងការកើនឡើងនៃចំណាយលើសម្ភារៈការិយាល័យប្រមាណ ១៦២,៣៩% ស្មើនឹង ៩៧៦.៣៧៥.០០០ រៀល។

មូលដ្ឋានក្នុងការគណនាប្រាក់បៀវត្សរបស់ កសស គឺយោងទៅលើទិន្នផល (ចំណូលពីការលើកដាក់) ពោលគឺ នៅពេលចំណូលពីការលើកដាក់កើនឡើង ចំណាយបៀវត្សនឹងកើនឡើង ផ្ទុយទៅវិញបើចំណូលពីការលើកដាក់មានការថយចុះ ចំណាយលើប្រាក់បៀវត្សនឹងត្រូវថយចុះដូចគ្នា ហើយយើងសង្កេតឃើញថាចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) មានការកើនប្រមាណ ៣៤,៣៩% និងចំណូលលើកដាក់លើទីលាន (LOLO) កើនប្រមាណ ១៨,៤៦% សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ នេះ។ ចំពោះចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ មានការកើនឡើងប្រមាណ ៣៩,៣៤% ស្មើនឹង ៨.៧៥៧.៧២៩.០០០ រៀល បើប្រៀបធៀបចំណាយសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ ដែលមានចំនួន ៣១.០១៩.៥៣៥.០០០ រៀល និងត្រីមាសទី៤ ឆ្នាំ២០២២ ដែលមានចំណាយ ២២.២៦១.៨០៦.០០០ រៀល។ ជារួមកត្តាដែលធ្វើអោយមានការកើនឡើងនៃចំណាយនេះ គឺបណ្តាលមកពីប្រាក់បៀវត្សបុគ្គលិក មានការកើនឡើងប្រមាណ ២៤,៧៩% ស្មើនឹង ៣.៨៩៤.៣៦០.០០០ រៀល និងការកើននៃប្រាក់រង្វាន់សរសើរចំនួន ១៧៣,៥៣% ស្មើនឹង ៣.៩៤៨.១៨៩.០០០ រៀល ។

ចំណាយរំលស់រួមមាន រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបីនៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ មានចំនួន ១២.៦៣៤.១៤២.០០០ រៀល មានកំណើន ៩៤១.១២៩.០០០ រៀល ស្មើនឹង ៨,០៥% បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២២ ដែលមានចំនួន ១១.៦៩៣.០១៣.០០០ រៀល។ កត្តាដែលធ្វើឱ្យមានការកើនឡើងនេះ គឺដោយសារចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារមានកំណើន ៧៩៦.២២៤.០០០ រៀល ស្មើនឹង ៨,០៨% ។

ចំណែកចំណាយជួសជុល និងថែទាំ មានការថយចុះឡើង ៥៣២.៨៥៨.០០០ រៀល ស្មើនឹង ៥០,៦៥% ដោយមានចំណាយសរុបស្មើនឹង ៥១៩.១១៤.០០០ រៀល សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ និង ១.០៥១.៩៧២.០០០ រៀល សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២២ ។

ចំពោះចំណាយផ្សេងៗសរុប មានការកើនប្រមាណ ៩,៨៤% ស្មើនឹង ៤២០.៥៦៦.០០០ រៀល គឺកើនពី ៤.២៧៥.៤៧៤.០០០ រៀល សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២២ មក ៤.៦៩៦.០៤០.០០០ រៀល សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣។ ការកើននៃចំណាយនេះបណ្តាលមកពី ចំណាយលើទឹកនិងភ្លើង ក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ មានការកើនឡើង ៣៤៨.៥៥៥.០០០ រៀល ស្មើនឹង ៤៧,០៨% ។

ខាតផ្សេងៗ-សុទ្ធ (Realized Foreign Exchange Gain-Loss) គឺសំដៅលើការចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណក្នុងការិយបរិច្ឆេទសម្រេច ដែលសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ នេះមានការខាតចំនួន ១.៨៦៤.៤១៨.០០០ រៀល បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២២ មានការខាតចំនួន ៤១០.៧៨៧.០០០ រៀល ធ្វើឱ្យការខាតកើនប្រមាណ ៣៥៣,៨៦% ស្មើនឹង ១.៤៥៣.៦៣១.០០០ រៀល ។

ចំណែកចំណាយហិរញ្ញវត្ថុ-សុទ្ធ (Unrealized Foreign Exchange Gain-Loss) គឺសំដៅលើការចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណក្នុងការិយបរិច្ឆេទមិនទាន់សម្រេច ដោយត្រីមាសទី៤ ឆ្នាំ២០២៣ មានចំណាយហិរញ្ញវត្ថុ-សុទ្ធ ចំនួន ១២.៧៤០.៧៧៨.០០០ រៀល ដែលមានការថយចុះនៃចំណាយហិរញ្ញវត្ថុ-សុទ្ធប្រមាណ ៤៥,១២% ស្មើនឹង ១០.៤៧៦.៦១៨.០០០ រៀល បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២២ ដែលមាន

ចំណាយហិរញ្ញវត្ថុ-សុទ្ធវិញ ចំនួន ២៣.២១៧.៣៩៦.០០០ រៀល។ កត្តាសំខាន់ដែលបណ្តាលឱ្យមានបម្រែបម្រួលលើចំណាយហិរញ្ញវត្ថុ-សុទ្ធ គឺដោយសារនៅក្នុងត្រីមាសទី៤ ឆ្នាំ២០២២ មានការខាតពីការប្តូររូបិយវត្ថុមិនទាន់សម្រេចរបស់ប្រាក់កម្ចី (ប្រាក់យ៉េន) ចំនួន ២១.៩៦២.៤៨៤.០០០ រៀល បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២៣ ដែលបានខាតពីការប្តូររូបិយវត្ថុមិនទាន់សម្រេចរបស់ប្រាក់កម្ចី (ប្រាក់យ៉េន) វិញចំនួន ៣៤៩.២៨៦.០០០ រៀល ។

ជាសរុប ចំណេញមុនបង់ពន្ធសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ របស់ កសស ចំនួន ៨.៩៨០.៧៥៦.០០០ រៀល កើនឡើងចំនួន ២១.០១៩.៣១៦.០០០ រៀល ស្មើនឹង ១៧៤,៦០% បើធៀបនឹង ត្រីមាសទី៤ ឆ្នាំ២០២២ ដែលមានខាតមុនបង់ពន្ធចំនួន ១២.០៣៨.៥៦០.០០០ រៀល ។

## ៤- ការវិភាគចំណេញ/(ខាត) ក្រោយបង់ពន្ធ

កសស ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ហេតុដូចនេះ កសស មានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំក្នុងអត្រា ២០%។ ចាប់តាំងពីឆ្នាំ២០២០ កសស បានបំពេញកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំរបស់ខ្លួន ក្នុងអត្រា ២០% វិញ ក្រោយពីទទួលបានការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រចំនួនបីឆ្នាំកន្លងមក (ឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៩) ។

**សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ធៀបនឹងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២**

| បរិយាយ | ការិយបរិច្ឆេទបញ្ចប់ត្រឹមត្រីមាសទី៤ ឆ្នាំ២០២៣ | ការិយបរិច្ឆេទបញ្ចប់ត្រឹមត្រីមាសទី៤ ឆ្នាំ២០២២ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណេញ/(ខាត)មុនបង់ពន្ធ (ក) | ៨.៩៨០.៧៥៦ | (១២.០៣៨.៥៦០) | ២១.០១៩.៣១៦ | ១៧៤,៦០% |
| ចំណាយពន្ធលើប្រាក់ចំណេញ (ខ) | (៤.៩៤៨.៥៣៦) | (១.៩៦៦.៥២១) | ២.៩៨២.០១៥ | ១៥១,៦៤% |
| **ចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ** | **៤.០៣២.២២០** | **(១៤.០០៥.០៨១)** | **១៨.០៣៧.៣០១** | **១២៨,៧៩%** |
| ការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ឡើងវិញ | - | - | - | - |
| លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិក | ៤.០៣២.២២០ | (១៤.០០៥.០៨១) | ១៨.០៣៧.៣០១ | ១២៨,៧៩% |
| **អត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញ (ខ)/(ក)** | **៥៥,១០%** | **-១៦,៣៤%** | | |

កសស ចំណេញក្នុងការិយបរិច្ឆេទចំនួន ៤.០៣២.២២០.០០០ រៀល សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ មានការកើនឡើងចំនួន ១៨.០៣៧.៣០១.០០០ រៀល ស្មើនឹង ១២៨,៧៩% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២២ ខាតក្នុងការិយបរិច្ឆេទចំនួន ១៤.០០៥.០៨១.០០០ រៀល។ កត្តាដែលធ្វើឱ្យចំណេញក្នុងការិយបរិច្ឆេទត្រីមាសទី៤ ឆ្នាំ២០២៣ មានការកើនឡើងនេះ គឺបណ្តាលមកពីមានការកើនឡើងនូវបរិមាណទំនិញ និងបរិមាណកុងតែន័រឆ្លងកាត់ បន្ថែមពីនេះទៀតគឺ ការថយចុះនៃការខាតពីការប្តូររូបិយវត្ថុមិនទាន់សម្រេចរបស់ប្រាក់កម្ចី (ប្រាក់យ៉េន) ថយចុះប្រមាណ ៦,១៨៨ % បើប្រៀបធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២។

បើសង្កេតទៅលើអត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញមានការកើនឡើងពី (១៦,៣៤)% សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២២ មក ៥៥,១០% សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ ដោយសារមានការកើនឡើងចំណេញមុនបង់ពន្ធសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ នេះ ។

## ៥- ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

កត្តាមួយចំនួនអាចមានឥទ្ធិពលលើស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់ កសស ដូចជា៖

- កត្តានានាដែលធ្វើឱ្យមានកំរិតលើការធ្វើពាណិជ្ជកម្មអន្តរជាតិ ដោយសារប្រភពចំណូលចម្បងរបស់ កសស បានមកពីចរាចរណ៍ទំនិញឆ្លងកាត់ធ្វើពាណិជ្ជកម្មអន្តរជាតិ ដូចនេះកត្តានានាដែលមានផលប៉ះពាល់ដល់ពាណិជ្ជកម្មអន្តរជាតិ និងមានឥទ្ធិពលលើអាជីវកម្មរបស់ កសស កត្តាទាំងនោះមានដូចជាស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក ក្នុងតំបន់ និងសាកលលោក ស្ថេរភាពសង្គម បញ្ហាសន្តិសុខ ឬកិច្ចសហប្រតិបត្តិការនាវាចរតាមសមុទ្រ។ យោងតាមមូលនិធិរូបិយប័ណ្ណអន្តរជាតិ (IMF) សេដ្ឋកិច្ចពិភពលោកនឹងមានកំណើនក្នុងអត្រាប្រមាណ ៣,០% សម្រាប់ឆ្នាំ២០២៣ ចំណែកសេដ្ឋកិច្ចកម្ពុជានឹងមានកំណើនប្រមាណ ៦,២% យោងតាម ASIAN DEVELOPMENT BANK (ADB) នេះបង្ហាញថាស្ថានភាពសេដ្ឋកិច្ចកម្ពុជានៅតែមានភាពរឹងមាំ ដែលជាកត្តាវិជ្ជមានចំពោះអាជីវកម្មកំពង់ផែ ។
- សមត្ថភាព និងប្រសិទ្ធភាពបំពេញការងាររបស់ កសស សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ កសស អាចមានសមត្ថភាពលើកដាក់កុងតែន័ររហូតដល់ ៨០០.០០០ TEUs បន្ទាប់ពីបានបំពាក់គ្រឿងចក្រលើកដាក់កុងតែន័រធុនធ្ងន់ ប្រភេទ QC ចំនួន ០១ គ្រឿង RTG ចំនួន ០២ គ្រឿង និង Empty Reach Stacker ចំនួន ០៤ គ្រឿង បន្ថែមទៀតកាលពីឆ្នាំ២០២១។ កត្តានេះធ្វើឱ្យសមត្ថភាព និងប្រសិទ្ធភាពការងារមានការកើនឡើងក្នុងការបំពេញសេវាកម្មរបស់ខ្លួន ស្របទៅនឹងកំណើនទំនិញឆ្លងកាត់របស់ កសស ។
- ស្ថានភាពបណ្តាញដឹកជញ្ជូនក្នុងស្រុក សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ នេះ បណ្តាញដឹកជញ្ជូនក្នុងស្រុក ពិសេសផ្លូវជាតិលេខ៤ ដែលតភ្ជាប់ពី កសស ទៅរាជធានីភ្នំពេញ ពុំមានឧបសគ្គដល់ការដឹកជញ្ជូនទំនិញឡើយនៅបន្តមធ្យតា។ រីឯការដឹកជញ្ជូនតាមផ្លូវដែកបច្ចុប្បន្នក្រុមហ៊ុន Royal Railway ឆ្លងកាត់ កសស មានចំនួន ៦ជើង ទៅ ៧ជើង ក្នុងមួយសប្តាហ៍ ក្នុងការនាំទំនិញចេញ-ចូល ហើយការដឹកជញ្ជូនតាមផ្លូវដែកនេះ ក៏ប្រព្រឹត្តទៅដោយរលូនតាមធម្មតាមិនមានបញ្ហាធ្វើឱ្យខកខានដំណើរនោះទេ ។
- កិច្ចសហប្រតិបត្តិការរវាងផែក្នុងតំបន់ ពិសេសគឺការតភ្ជាប់ជាមួយកំពង់ផែមេក្នុងតំបន់ មានសារៈសំខាន់ក្នុងការសំរួលចរាចរណ៍ទំនិញរវាង កសស និងទីផ្សារអន្តរជាតិសំខាន់ៗ ដោយមានឥទ្ធិពលលើចំណាយ និងរយៈពេលដឹកជញ្ជូន ដែលជាលទ្ធផលធ្វើឱ្យមានផលប៉ះពាល់លើភាពប្រកួតប្រជែង

របស់ឧស្សាហកម្មនានា។ ក្នុងករណីនេះ កសស បានខិតខំរក្សាទំនាក់ទំនងល្អជាមួយបណ្ដាកំពង់ផែសំខាន់ៗ ក្នុងតំបន់ដើម្បីធានាឱ្យប្រតិបត្តិការមានភាពរលូន ។

- រំលស់៖ ដោយអាជីវកម្មរបស់ កសស មានការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធច្រើន ចំណាយលើរំលស់លើហេដ្ឋារចនាសម្ព័ន្ធផែដូចជា ចំណតនាវា គ្រឿងចក្រ អគារ មានទំហំធំដែលអាចប៉ះពាល់ដល់អាជីវកម្មរបស់ កសស។ ដូចនេះ កសស ចាំបាច់ត្រូវមានការត្រួតពិនិត្យលើគោលនយោបាយរំលស់ឱ្យបានសមស្រប និងធ្វើការកែតម្រូវ តាមការចាំបាច់រៀងរាល់ការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុ។ សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣នេះ ពុំមានការកែសម្រួល ឬការស្នើឱ្យមានការកែសម្រួលគោលនយោបាយរំលស់នេះពីសវនករឯករាជ្យឡើយ ។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

សកម្មភាពអាជីវកម្មរបស់ កសស មានទំនាក់ទំនងដោយផ្ទាល់ជាមួយសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចសាកលលោក។ ជាពិសេសនៅពេលសេដ្ឋកិច្ចជាតិមានបម្រែបម្រួលនឹងមានឥទ្ធិពលដោយផ្ទាល់ទៅលើអាជីវកម្ម សេវាកម្មកំពង់ផែ ពោលគឺនៅពេលសេដ្ឋកិច្ចជាតិកើនឡើងនាំឱ្យអាជីវកម្ម សេវាកម្ម កំពង់ផែក៏កើនឡើងស្របនឹងនេះផលចំណូលរបស់ កសស ក៏មានកំណើនដូចគ្នា ផ្ទុយទៅវិញ បើសេដ្ឋកិច្ចជាតិថយចុះនឹងមានផលអវិជ្ជមានទៅលើផលចំណូល កសស ផងដែរ។ យោងតាម ASIAN DEVELOPMENT BANK (ADB) សេដ្ឋកិច្ចកម្ពុជានឹងមានកំណើនក្នុងអត្រារំពឹងទុកប្រមាណ ៦,២% ចំណែកសេដ្ឋកិច្ចពិភពលោកនឹងមានកំណើនក្នុងអត្រាប្រមាណ ៣,០% (IMF) សម្រាប់ឆ្នាំ២០២៣ នេះ។ ទោះយ៉ាងណាក៏ដោយ កសស អាចមានកត្តាផលប៉ះពាល់ទៅដល់តម្រូវការ និងការផ្គត់ផ្គង់ដោយសារស្ថានភាពសង្គ្រាម រុស្ស៊ីនិងអ៊ុយក្រែន និងសង្គ្រាមរវាងអ៊ីស្រាអែល និងប៉ាលេស្ទីនបច្ចុប្បន្ន។

### ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ប្រេងឥន្ធនៈ ជាវត្ថុធាតុដើមចម្បងបំផុតក្នុងការបម្រើសេវាកម្មកំពង់ផែ ដោយជាតម្រូវការសំខាន់សម្រាប់ប្រតិបត្តិការគ្រឿងចក្រ។ កសស នៅតែរក្សាតម្លៃសេវារបស់ខ្លួនដដែល បើទោះជាតម្លៃប្រេងឥន្ធនៈមានការកើនឡើង ឬថយចុះក៏ដោយ។ ហេតុដូចនេះ កសស បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនីតិវិធីលទ្ធកម្ម ដើម្បីធានាឱ្យបាននូវតម្លៃរបស់វត្ថុធាតុដើមទាំងនេះមានភាពសមស្រប និងប្រកួតប្រជែងក្នុងតម្លៃទីផ្សារ ។

### ៣- ការវិភាគលើពន្ធ

កសស ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ហេតុដូចនេះ កសស មានកាតព្វកិច្ចត្រូវបង់ពន្ធអាករទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។ កសស ត្រូវបង់ពន្ធអាករទៅតាមរបរពិត និងជាសហគ្រាសជាប់ពន្ធធំ ដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។ ចំពោះពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ចាប់តាំងពីឆ្នាំ២០២០ កសស បានបំពេញកាតព្វកិច្ចបង់ពន្ធក្នុងអត្រា ២០% វិញក្រោយពីទទួលបានការលើកទឹកចិត្តក្នុងវិស័យមូលបត្ររយៈពេលបីឆ្នាំកន្លងមក ចំណែកពន្ធផ្សេងៗ កសស បានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់ពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា ។

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ កសស មានចំណូលលើកដាក់ និងចំណូលពីសេវាកម្មផែដែលរួមចំណែកប្រមាណ ៩៨% នៃចំណូលសរុបសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ ហើយកត្តាចម្បងដែលជំរុញឱ្យមានការកើនឡើងនៃប្រាក់ចំណូល គឺកំណើននៃនាវា និងទំនិញឆ្លងកាត់កំពង់ផែ ជាពិសេសទំនិញកុងតែន័រដែលជាប្រភពចំណូលដ៏សំខាន់របស់ កសស។ ការលូតលាស់ក្នុងវិស័យកសិកម្ម វិស័យពាណិជ្ជកម្ម វិស័យសំណង់ និងវិស័យឧស្សាហកម្ម គឺបានឆ្លុះបញ្ចាំងនូវស្ថានភាពសេដ្ឋកិច្ចជាតិរបស់ប្រទេសកម្ពុជា ហើយស្របនឹងនេះក៏មានឥទ្ធិពលជាផលវិជ្ជមានលើអាជីវកម្ម សេវាកម្ម និងផលចំណូលរបស់ កសស ផងដែរ ។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ (Commodity)

### ១- ផលប៉ះពាល់ពីអត្រាប្តូរប្រាក់

កសស បានទទួលប្រាក់កម្ចីបន្តតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពី JICA និង JBIC ដោយតម្រូវឱ្យ កសស សងប្រាក់ដើម និងការប្រាក់ជាប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក នៅពេលដែលរូបិយវត្ថុមុខងាររបស់ កសស គឺជាប្រាក់រៀល។ ដូចនេះ បំរែបំរួលអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ប្រាក់រៀលធៀបនឹងប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារធៀបនឹងប្រាក់យ៉េនជប៉ុន មានផលប៉ះពាល់ដល់កម្រិតប្រាក់ចំណេញរបស់ កសស ។

### ២- ផលប៉ះពាល់ពីអត្រាការប្រាក់

បច្ចុប្បន្ន កសស មិនមានកម្ចីណាដែលមានអត្រាការប្រាក់ប្រែប្រួលនោះទេ។ កសស បានទទួលប្រាក់កម្ចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាកម្ចីបន្តពី JICA និង JBIC ក្នុងអត្រាការប្រាក់ចាប់ពី ២,៦៥% ដល់ ៣,៧០%។ ហេតុដូចនេះ សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ នេះ មិនមានផលប៉ះពាល់ពីបម្រែបម្រួលអត្រាការប្រាក់នេះទេ ។

### ៣- ផលប៉ះពាល់ពីការប្រែប្រួលតម្លៃប្រេងឥន្ធនៈ

ការប្រែប្រួលតម្លៃប្រេងឥន្ធនៈនឹងមានផលប៉ះពាល់ដល់ផលចំណេញរបស់ កសស ដោយប្រតិបត្តិការកំពង់ផែពឹងផ្អែកយ៉ាងខ្លាំងទៅលើគ្រឿងចក្រដែលប្រើប្រាស់ប្រេងឥន្ធនៈ។ ហេតុដូចនេះ កសស បានពង្រឹងប្រសិទ្ធភាពលើកដាក់ និងការគ្រប់គ្រងទីលានកុងតែន័រ ដើម្បីកាត់បន្ថយការរើ ឬការបំលាស់ទីកុងតែន័រដែលមិនចាំបាច់ ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការ និងលើកកំពស់សេវាកម្មរបស់ខ្លួន ។

## ង- ផលប៉ះពាល់នៃអតិផរណា

កសស បានរក្សានូវតម្លៃសេវាកម្មរបស់ខ្លួនថេរ ដោយមិនធ្វើការប្រែប្រួល ឬកែសម្រួលទៅតាមការប្រែប្រួលនៃអតិផរណាឡើយ ហើយនៅតែរក្សាបាននូវស្ថេរភាពហិរញ្ញវត្ថុបានយ៉ាងប្រសើរ ។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រដ្ឋាភិបាល

គោលនយោបាយ សេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រដ្ឋាភិបាលមានឥទ្ធិពលយ៉ាងខ្លាំងលើអាជីវកម្មរបស់ កសស ដោយសារគោលនយោបាយនេះមានទិសដៅគាំទ្រ និងលើកស្ទួយវិស័យពាណិជ្ជកម្មអន្តរជាតិ ដែលផ្តល់ផលវិជ្ជមានដល់អាជីវកម្មរបស់ កសស។ គោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលរួមមាន៖

- គោលនយោបាយលើកស្ទួយវិស័យឧស្សាហកម្ម រាជរដ្ឋាភិបាលមានគម្រោងប្រែក្លាយខេត្តព្រះសីហនុឱ្យទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ឡូជីស្ទីក និងផលិតកម្ម តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធផែពង្រីកផ្លូវជាតិលេខ៤ និងហេដ្ឋារចនាសម្ព័ន្ធព្រលានយន្តហោះអន្តរជាតិ ខេត្តព្រះសីហនុផងដែរ ។
- គោលនយោបាយជម្រុញការដឹកជញ្ជូនតាមផ្លូវល្បឿនលឿនពី ភ្នំពេញ-ខេត្តព្រះសីហនុ ចំណេញពេលវេលា
- គោលនយោបាយជម្រុញការដឹកជញ្ជូនតាមផ្លូវទឹក
- គោលនយោបាយនាំចេញអង្ករចេញទៅទីផ្សារក្រៅប្រទេស កំពុងផ្តល់ផលវិជ្ជមានដល់ កសស
- គោលនយោបាយលើកស្ទួយពាណិជ្ជកម្មអន្តរជាតិ ដោយខិតខំកាត់បន្ថយឧបសគ្គនានា ចំពោះការធ្វើពាណិជ្ជកម្មរវាងកម្ពុជា និងបណ្តាប្រទេសជាដៃគូក្នុងសាកលលោក
- រាជរដ្ឋាភិបាលតាមរយៈធនាគារជាតិ បានអនុវត្តគោលនយោបាយរូបិយវត្ថុតាមរយៈយន្តការទីផ្សារប្តូរប្រាក់សេរី តែស្ថិតនៅក្រោមអន្តរាគមន៍ ដើម្បីរក្សាស្ថេរភាពរូបិយប័ណ្ណជាតិ ហើយលំនឹងរូបិយវត្ថុនេះបានរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ដែលបានកសាងទំនុកចិត្តចំពោះវិនិយោគិន និងជម្រុញការធ្វើអាជីវកម្មវិស័យឯកជន
- ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដល់សហគ្រាសបោះផ្សាយលក់មូលបត្រនៅកម្ពុជា បាននឹងកំពុងជម្រុញឱ្យសហគ្រាសរដ្ឋ និងក្រុមហ៊ុនឯកជនចូលទីផ្សារមូលបត្រកាន់តែច្រើន ដែលចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

# ផ្នែកទី ៥

# ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ នេះ កសស មានព័ត៌មានចាំបាច់សម្រាប់ការពារវិនិយោគិនដូចខាងក្រោម៖

- បានអនុម័តឯកភាពលើ របាយការណ៍ស្តីពី វឌ្ឍនភាពនៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រ ដែលកំពុងដំណើរការ (១.គម្រោងកែសម្រួលផែទំនិញទូទៅ ជាផែកុងតែន័រប្រវែង ២៥៣ ម៉ែត្រ និង ២. គម្រោងអភិវឌ្ឍន៍ចំណតផែកុងតែន័រ ថ្មី-ដំហានទី១, ដំហានទី២ និងដំហានទី៣) ។
- បានអនុម័តដោយឯកភាពលើ របាយការណ៍ហិរញ្ញវត្ថុត្រីមាសទី៣ ឆ្នាំ២០២៣ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young (Cambodia) Ltd (Financial Performance Review) ។
- បានអនុម័តឯកភាពគាំទ្រ គម្រោងផែនការ អាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ កសស ឆ្នាំ២០២៤ ដូចខាងក្រោម ៖

១) ផែនការ អាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ ៖

ក). បរិមាណផលិតផល ៖

| | | |
|---|---|---|
| - បរិមាណទំនិញឆ្លងកាត់ផែ | ចំនួន ៨,០៦៩,000 តោន | និទស្សន៍កំណើន ៤% |
| - បរិមាណប្រេងឆ្លងកាត់ | ចំនួន ២,២៨២,000 តោន | និទស្សន៍កំណើន ៤% |
| - បរិមាណតោនលើករៀប | ចំនួន ១៧,៦១២,000 តោន | និទស្សន៍កំណើន ៤% |
| - បរិមាណកុងតែន័រឆ្លងកាត់ | ចំនួន ៨២៣,000 TEUs | និទស្សន៍កំណើន ៥% |
| - ចំនួននាវាឆ្លងកាត់ | ចំនួន ១,៥៥២ គ្រឿង | និទស្សន៍កំណើន ៣% |
| - ចំណុះផ្ទុកនាវា | ចំនួន ១៩,៤១៧,000 តោន | និទស្សន៍កំណើន ៤% |
| ខ). សរុបចំណូលសេវាកម្ម | ៣៧៧,០៩២,000 ពាន់រៀល | និទស្សន៍កំណើន ៥% |
| គ). សរុបចំណាយសេវាកម្ម | ៣០៣,១០៧,000 ពាន់រៀល | និទស្សន៍កំណើន ១% |
| ឃ). ចំណេញប្រតិបត្តិការ | ៧៣,៩៨៥,000 ពាន់រៀល | និទស្សន៍កំណើន២០% |
| ង). ចំណេញ/ខាតហិរញ្ញវត្ថុសុទ្ធ | (១,១៥១,000) ពាន់រៀល | និទស្សន៍ថយចុះ ៤% |
| ច). លទ្ធផលពិតមុនបង់ពន្ធ | ៧២,៨៣៤,000 ពាន់រៀល | និទស្សន៍កំណើន២០% |
| ឆ). ពន្ធលើប្រាក់ចំណេញ | ១៤,៥៦៧,000 ពាន់រៀល | និទស្សន៍កំណើន២០% |
| ជ). ចំណេញពិតក្នុងការិយបរិច្ឆេទ | ៥៨,២៦៧,000 ពាន់រៀល | និទស្សន៍កំណើន២០% |

២) ផែនការវិនិយោគ ៖ គម្រោងវិនិយោគឆ្នាំ ២០២៤ របស់ កសស រួមមាន៖

- ការដ្ឋានប្រើឥណទានកម្ចី ODA ជប៉ុន ២៧៥,៧២៥,១០២ ពាន់រៀល
- ការដ្ឋានប្រើឥណទានកំពង់ផែ ៨៩,៨១១,៥២៥ ពាន់រៀល (ចំណាយក្នុងឆ្នាំ២០២៤ = ៤៧,៤៩៩,៥២៥ ព.រ និងបន្តចំណាយក្នុងឆ្នាំ២០២៥ = ៤២,៣១២,000 ព.រ)
- បំពាក់ឧបករណ៍ និងមធ្យោបាយគ្រឿងចក្រ ៦៧,៤៥៧,៣០០ ពាន់រៀល (ចំណាយក្នុងឆ្នាំ២០២៤ = ១៨,៩៧៤,៨00 ព.រ និងបន្តចំណាយក្នុងឆ្នាំ២០២៥ = ៤៨,៤៨២,៥00 ព.រ)
- បំពាក់ឧបករណ៍ការិយាល័យ និងសង្ហារឹម ៣,៣៤៥,៩៩២ ពាន់រៀល

- បានអនុម័តឯកភាពឯកភាពទៅលើរបាយការណ៍ និងរក្សាការឯកភាពស្របតាមស្មារតីអង្គប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៨ លើកទី៩ ដោយអនុញ្ញាតិអោយ កសស ជួលដីទៅអោយ ក្រុមហ៊ុន រ៉ូយ៉ាល់

រេលវេ (Royal Railway Plc) សម្រាប់រយៈពេល ១០ឆ្នាំ បន្តទៀត ក្នុងតម្លៃចាប់ផ្តើមពី ១០០,០០០ ដុល្លារអាមេរិក ក្នុងមួយឆ្នាំ ជាមួយនឹងការកើនឡើង ៥% ជារៀងរាល់ឆ្នាំ ដោយកំណត់ត្រឹមទំហំដីដែលក្រុមហ៊ុនបានកំពុងអភិវឌ្ឍ និងកំពុងធ្វើអាជីវកម្ម ហើយ កសស នឹងធ្វើការអភិវឌ្ឍដីដែលនៅសល់ ដើម្បីបម្រើអោយប្រតិបត្តិការអាជីវកម្ម និងការងារលើកដាក់ កសស ។

- បានអនុម័តឯកភាពលើ ទៅលើរបាយការណ៍ស្តីពី ករណីក្រុមហ៊ុន ជី.ធី.វី.ស៊ី ស្ពីដប៊ូត (G.T.V.C SPEEDBOAT CAMBODIA) អភិវឌ្ឍន៍ចំណតកំពង់ផែទេសចរណ៍ នៅមុខឃ្លាំងលេខ១ និងឃ្លាំងលេខ២ ដោយ កសស ត្រូវរៀបចំខណ្ឌរបង កំណត់ព្រំប្រទល់រវាង កសស (តំបន់កំពង់ផែអន្តរជាតិ) និងតំបន់ទេសចរណ៍ក្នុងស្រុក (តំបន់សាធារណៈ) ក្នុងគោលបំណងអោយមានអនុលោមភាពស្របតាម ISPS Code និង SOLAS និងត្រូវរក្សាទុកឃ្លាំងលេខ២ និងចន្លោះទីធ្លានៅមុខឃ្លាំងដើម្បីជានាការបត់ចេញ-ចូលរបស់រថយន្តដឹកកុងតែន័រ សម្រាប់ការងារអាជីវកម្ម កសស និងបម្រើអោយការនាំចេញផលិតផលកសិ-ឧស្សាហកម្ម ដូចជា អង្ករ និងដំឡូងមីជាដើម ។

# ហត្ថលេខាអភិបាលរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤

បានអាន និងឯកភាព



ហត្ថលេខា

**លូ គីមឈន់**

ប្រធានអគ្គនាយក

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ








**អាសយដ្ឋាន**

តិរវិថីសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ព្រះរាជាណាចក្រកម្ពុជា

**ទំនាក់ទំនង**

០៣៤ ៩៣៣ ៤១៦
០៣៤ ៩៣៣ ៥១១
០៧៨ ៤៩៦ ៧៨៩

pas.gov.kh
pasinfo@pas.gov.kh
Sihanoukville Autonomous Port